01392965

E1/388.1/Corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Feb-2017, 11:25
CMS/CFO: Sann Rada

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| **កែលើឯកសារលេខ៖** | **ERN(s):** | **កាលបរិច្ឆេទ៖** | **ប្រភេទកំណែ៖** |
|---|---|---|---|
| E1/388.1 | 01203775 -01203852 | 17 Feb 2017 | ☒ កែលើឯកសារដើម<br>☐ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

**មូលហេតុនៃការកែតម្រូវ៖**

កំណែប្រែដូចបង្ហាញក្នុងប្រតិចារិកនេះគឺជាលទ្ធផលនៃការត្រួតពិនិត្យប្រកបដោយគុណភាព ដែលធ្វើឡើងដោយអង្គភាពប្រតិចារិក ដោយមានការចង្អុលបង្ហាញពីការិយាល័យរដ្ឋបាល ហើយដែលបានជូនដំណឹងដល់ភាគីកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។ កំណែប្រែនេះបង្ហាញប្រាប់អំពីចំណុចខ្វះខាតលើខ្លឹមសារ ឬភាពមិនត្រឹមត្រូវដែលត្រូវបានកែសម្រួល ដោយធ្វើការប្រៀបធៀបទៅនឹងភាសាដើមដែលភាគីបានថ្លែងនៅក្នុងសវនាការ និងអ្វីដែលត្រូវបានបកប្រែដោយអ្នកបកប្រែ។

**សេចក្តីលម្អិតនៃការកែតម្រូវ៖**

ការកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ស្នើដោយ៖ អង្គភាពប្រតិចារឹក — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ — ហត្ថលេខា៖ [signature]

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ — ហត្ថលេខា៖

01392966



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី៣៦៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម ធូ មណី
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ា
លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
កញ្ញា សុង ឆវ័ន្ត
លោក ស្រ៊ា រតនៈ

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*
លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី អេលេអូន័រ ហ្វែណាង់ដេស្ស
*(Ms. Eleonor FERNANDEZ )*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គិសសេ | បារាំង |
| លោក អ៊ុំសា ឧស្មាន (2-TCE-95) | ខ្មែរ |
| លោកស្រី ហ្សូលី បាដេស | បារាំង |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ:- អ៊ីសា ឧស្មាន** (2-TCE-95)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ..........ទំព័រ ៣

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី ..........ទំព័រ ២៧

# **កិច្ចដំណើរការនីតិវិធី**

[០៩:០៥:០០]

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ដែលមានរហស្សនាម 2-TCE-95 ពាក់ព័ន្ធនឹងអង្គហេតុនៃការប្រព្រឹត្តចំពោះក្រុមមនុស្សគោលដៅជាក់លាក់ចំពោះជនជាតិចាម ហើយសវនាការស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញរូបនេះ គ្រោងធ្វើនៅក្នុងរយៈពេលបីថ្ងៃ។

មុននឹងដំណើរការសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-95 នៅថ្ងៃនេះ អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីថា នៅក្នុងកិច្ចដំណើរការនៅថ្ងៃនេះ និងអាចនៅថ្ងៃស្អែកផងដែរ លោកចៅក្រម យូរ ឧត្តរា ដែលជាចៅក្រមជាតិលោកអវត្តមាន ដោយលោកមានបញ្ហាសុខភាពមិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ ហើយបន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងបណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងបានសម្រេចតែងតាំងលោកចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងនៃភាគីជាតិ ជំនួសកន្លែងចៅក្រម យូរ ឧត្តរា ដែលបានអវត្តមាននៅថ្ងៃនេះ។ ហើយអាចនៅថ្ងៃបន្តបន្ទាប់រហូតដល់ពេលចៅក្រម យូរ ឧត្តរា មានវត្តមាន និងមានលទ្ធភាពអាចចូលរួមបំពេញការងារនៅក្នុងកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងវិញបាន។ ការសម្រេចនេះ ផ្អែកលើបទប្បញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍ពីស្ថានភាពវត្តមាន អវត្តមានបុគ្គលភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៧:៥០]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

01392971





ទាំងអស់នេះរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ អ្នកជំនាញដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCE-95 អ្នកជំនាញបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ អ្នកជំនាញ និងអ្នកច្បាប់ អមអ្នកជំនាញមកពីការិយាល័យសហចៅក្រមស៊ើបអង្កេតមានវត្តមានរួចហើយនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ឯម ហ៊ុយ។ អង្គជំនុំជម្រះបាន -- ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់ពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទ នៅអ.វ.ត.ក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថា លោក នួន ជា មានអាការៈឈឺ ចង្កេះខ្លាំងមិនអាចអង្គុយយូរបាន និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការ ពីបន្ទប់ស្ថិតនៅក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះ អនុញ្ញាតឲ្យជន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសម្រាប់ថ្ងៃនេះ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញអ្នកជំនាញ 2-TCE-95 និង មន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចូលមកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការ។

[០៩:១២:០៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ សួស្តីលោកអ្នកជំនាញ តើលោកអាចប្រាប់នាមត្រកូល និងនាមខ្លួនលោក ដល់អង្គជំនុំជម្រះបានដែរៗឬទេ? តើលោកមាននាមត្រកូលនិងនាមខ្លួនអីដែរ? សូមបង្អង់បន្តិច លោកៗអ្នកជំនាញ ចាំៗក្បាលមីក្រូហ្វូនប្រតិបត្តិការសិនណា។ អង់បន្តិច ជាធម្មតា យើងអង់រហូតដល់ក្បាលមីក្រូហ្វូនប្រតិបត្តិឱ្យដល់ភ្លើងសញ្ញាក្រហម សូមលោកឆ្លើយ ដើម្បីឱ្យប្រព័ន្ធនៃការចែកចាយសំឡេង ការបកប្រែហ្នឹងបានពេញលេញ។ វាមានការបកប្រែប្រដេញមែន ប៉ុន្តែការបកប្រែហ្នឹង មានការយឺតបន្តិចបើធៀបជាមួយនឹងការនិយាយផ្ទាល់ណា៎!

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ សូមជម្រាបសួរលោកប្រធាន និងអង្គសវនាការទាំងមូល។ ខ្ញុំឈ្មោះ អ៊ីសា ឧស្មាន។

**ស៖** បាទ អរគុណលោក អ៊ីសា ឧស្មាន។ ហើយតើលោកកើតនៅថ្ងៃខែឆ្នាំណា លោកចាំទេ?

**ឆ៖** ខ្ញុំបាទ កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧១។

**ស៖** បាទ អរគុណ។ ហើយលោកមានសញ្ជាតិអ្វីដែរ ហើយជនជាតិអ្វីដែរ?

[០៩:១៣:៣៦]

**ឆ៖** ខ្ញុំកាន់អត្តសញ្ញាណប័ណ្ណខ្មែរ ប៉ុន្តែជាតិសាសន៍ពូជអំបូររបស់ខ្ញុំ គឺជនជាតិចាម។

**ស៖** បាទ អរគុណ។ ហើយទីលំនៅអចិន្ត្រៃយ៍របស់លោកសព្វថ្ងៃនៅៗទីកន្លែងណា?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** ង

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**ឆ៖** ខ្ញុំរស់នៅភ្នំពេញ។ ផ្ទះរបស់ខ្ញុំលេខ១៧៤ ផ្លូវលេខ០២ ក្នុងបុរីពិភពថ្មីឡាសែនសុខ តាមបណ្ដោយផ្លូវម៉ុងឫទ្ធី សង្កាត់សែនសុខ -- ខណ្ឌសែនសុខ សុំទោស សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ។

**ស៖** បាទ លោកប្រកបមុខរបរអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំ គឺជាបុគ្គលិកម្នាក់នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតនៃតុលាការខ្មែរក្រហមនេះ។

**ស៖** អរគុណ ហើយតើលោកគោរពសាសនាអ្វីដែរ?

**ឆ៖** ខ្ញុំជាអ្នកប្រតិបត្តិសាសនាអ៊ីស្លាម។

**ស៖** បាទ អរគុណ។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះ មុនលោកអញ្ជើញចូលមកនេះ តាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬក៏បុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ។ តើពិតមែនដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ លោកប្រធាន។

**ស៖** បាទ អរុណសួស្ដី លោកស្រីដែលអង្គុយអមកៀកក្បែរលោក អ៊ីស្លាម -- អ៊ីសា ឧស្មាន តើលោកស្រីឈ្មោះអី?

**លោកស្រី ហ្សូលី បាដេស៖**

សូមជម្រាបសួ លោកប្រធាន។ ខ្ញុំឈ្មោះ ហ្សូលី បាដេស។

**ប្រធានអង្គជំនុំ៖**

បាទ តើលោកស្រីជាមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអន្តរជាតិនៃ អ.វ.ត.ក នេះពិតមែនដែរទេ?

**លោកស្រី ហ្សូលី បាដេស៖**

ពិតហើយ លោកប្រធាន។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក អ៊ីសា ឧស្មាន ដោយអនុវត្តតាមវិធាននៃ៣១ អនុប្រធាន២ នៃវិធានផ្ទៃក្នុង អ.វ.ត.ក នៅក្នុងនាមលោកជាអ្នកជំនាញ លោកត្រូវធ្វើសម្បថ ឬសច្ចាប្រណិធានជាមុន មុននឹងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ តើលោកយល់ព្រមដែរទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទៗ ខ្ញុំយល់ព្រម។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ាយ សូមលោកណែនាំអំពីនីតិវិធីសម្បថដល់អ្នកជំនាញចំពោះមុខអង្គជំនុំជម្រះ។

[០៩:១៦:៤៤]

**ក្រឡាបញ្ជី៖**

ជម្រាបសួរលោកអ្នកជំនាញ។ ជាបន្តទៅនេះ ខ្ញុំនឹងរៀបចំវិធីសម្បថដល់លោក។ សូមលោកដាក់បាតដៃស្ដាំនៅលើគម្ពីរអាល់គួរ៉ានដែលនៅពីមុខលោក រួចខ្ញុំនឹងអានពាក្យសម្បថនេះ បន្ទាប់មកលោកនឹងនិយាយនូវពាក្យសម្បថតាមខ្ញុំ៖ "ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ ក្នុងនាមខ្ញុំជាអ្នកកាន់សាសនាអ៊ីស្លាម ដែលមានអល់ឡោះជាម្ចាស់តែមួយ និងមហាម៉ាត់ជាបម្រើរបស់អល់ឡោះ និងមានគម្ពីរអាល់គួរ៉ាន ជាសម្ពីរបស់អល់ឡោះ ដែលជាគោលសម្រាប់យើងខ្ញុំអនុវត្តតាម ខ្ញុំសូមស្បថដោយមានគម្ពីរអាល់គួរ៉ាននៅពីមុខស្រាប់។ វល់-ឡ-ហ៊ី ពិល-ឡា-ហ៊ី បញ្ជាក់ថា អ្វីៗដែលខ្ញុំនិយាយសុទ្ធតែជាការពិតទាំងអស់។"

**លោក អ៊ីសា ឧស្មាន៖**

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។ ក្នុងនាមខ្ញុំជាអ្នកកាន់សាសនាអ៊ីស្លាម ដែលមានអល់ឡោះជាម្ចាស់តែមួយ និងមហាម៉ាត់ជាបម្រើរបស់អល់ឡោះ និងមានគម្ពីរអាល់គួរ៉ាន ជាសម្ពីរបស់អល់ឡោះ ដែលជាគោលសម្រាប់យើងខ្ញុំអនុវត្តតាម ខ្ញុំសូមស្បថដោយមានគម្ពីរអាល់គួរ៉ាននៅពីមុខស្រាប់។ វល់-ឡ-ហ៊ី ពិល-ឡា-ហ៊ី ហើយសូមបញ្ជាក់ថា អ្វីៗដែលខ្ញុំនិយាយសុទ្ធតែការពិតទាំងអស់។

**ក្រឡាបញ្ជី៖**

សូមគោរព លោកប្រធាន វិធីសម្បថបានធ្វើរួចហើយ។ បាទ សូមអរគុណ លោកប្រធាន។

**សួរដោយប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដើម្បីធានាតម្លាភាពនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសូមរំឭកថា នៅថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានតាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួន បានជូន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ដំណឹងដល់ភាគីតាមរយៈសារអេឡិចត្រូនិកថា អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មអ្នកជំនាញ អ៊ីសា ឧស្មាន លើអង្គហេតុស្តីពីការប្រព្រឹត្តទៅលើជនជាតិចាម។ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួន តែងតាំងអ្នកជំនាញ អ៊ីសា ឧស្មាន ដោយផ្អែកលើចំណេះជំនាញរបស់គាត់ដែលមានតាមរយៈការនិពន្ធសៀវភៅចំនួនពីរក្បាល ក្នុងអំឡុងពេលគាត់បំពេញការងារជាអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារE367។ អ្នកជំនាញរូបនេះ បច្ចុប្បន្នមានតួនាទីជាអ្នកវិភាគទិន្នន័យរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ នៅក្រោយមកទៀត នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេត អន្តរជាតិបានលើកឡើងពីក្តីបារម្ភរបស់ខ្លួនចំពោះទម្រង់ដែលអ្នកជំនាញរូបនេះ នឹងត្រូវចោទសួរនៅចំពោះមុខអង្គជំនុំជម្រះ ហើយបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមួយជូនដំណឹងដល់ភាគីទាំងអស់ជាមុនថា អ្នកជំនាញអាចមិនត្រូវបានចោទសួរ ជាពិសេសអំពីព័ត៌មានដែលប្រមូលបាននៅក្នុងអំឡុងស៊ើបសួរក្នុងសំណុំរឿង០០៤ និងពីរ អនុញ្ញាតឱ្យមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតម្នាក់មានវត្តមាននៅក្នុងសាលសវនាការនៅក្នុងអំឡុងពេលដែលអ្នកជំនាញផ្តល់សក្ខីកម្ម។ ហេតុដូច្នេះហើយប្រសិនបើមានការចោទសួរសំណួរណាមួយកើតឡើងទាក់ទិនទៅនឹងវិសាលភាពត្រឹមត្រូវនៃសក្ខីកម្មរបស់ខ្លួន អ្នកជំនាញអាចពិគ្រោះយោបល់ជាមួយនឹងមន្ត្រីច្បាប់នោះនូវចំពោះអង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់ ឯកសារ E367/1 ទំព័រទី២។

[០៩:២០:៣៣]

អង្គជំនុំជម្រះបានស្នើឱ្យភាគីនានាធ្វើសារណាផ្ទាល់មាត់ អំពីវិធានការដែលបានស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ បន្ទាប់ពីបានពិចារណាមតិយោបល់របស់ភាគីនៅថ្ងៃទី០៥ កុម្ភៈ ឆ្នាំ២០១៦ អង្គជំនុំជម្រះបានចេញអនុស្សរណៈមួយបញ្ជាក់ពីទម្រង់ការនៃការផ្តល់សក្ខីកម្មរបស់អ្នកជំនាញ វិសាលភាពនៃសំណួរដែលភាគីអាចត្រូវបានអនុញ្ញាតឱ្យសួរដេញដោលចំពោះអ្នកជំនាញ និងតួនាទីរបស់មន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលមានវត្តមានអមអ្នកជំនាញ ឯកសារ E367/6-Correct1។

អង្គជំនុំជម្រះបានណែនាំឱ្យភាគីផ្ញើជូនបញ្ជីឯកសារជាមុន ដែលពួកគេមានបំណងសួរដេញដោលចំពោះអ្នកជំនាញ ហើយភាគីបានដាក់ឯកសារសរុបចំនួនប្រហែល២៥០ឯកសារ ដើម្បីសួរដេញដោលអ្នកជំនាញរូបនេះ។ អង្គជំនុំជម្រះក៏សូមសួរបញ្ជាក់ផងដែរថា -- ក៏សូមបញ្ជាក់ផងដែរថា វត្តមាន

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

មន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅក្នុងសវនាការនេះ គឺដើម្បីតំណាងឲ្យផលប្រយោជន៍របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការរក្សាការសម្ងាត់ដល់ការស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ គាត់មិនមែនជាអ្នកតំណាងផ្លូវច្បាប់របស់អ្នកជំនាញឡើយ ដោយពិចារណាពីសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ការព្រួយបារម្ភរបស់ក្រុមមេធាវីការពារក្តី និងលក្ខខណ្ឌរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ថា មន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនត្រូវធ្វើអន្តរាគមន៍ណាមួយឡើយនៅក្នុងពេលដែលអ្នកជំនាញផ្តល់សក្ខីកម្ម លើកលែងតែពាក់ព័ន្ធទៅនឹងបញ្ហាសម្ងាត់នៃការស៊ើបអង្កេតក្នុងសំណុំរឿង០០៤ តែប៉ុណ្ណោះ។

[០៩:២២:៣១]

មួយវិញទៀត នៅក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ អ៊ីសា ឧស្មាន អាចមានករណីភាគីមានបំណងប្រើប្រាស់នូវឯកសារមួយចំនួនដែលមានតែមួយភាសា ដោយឯកសារនោះមិនមានការបកប្រែផ្លូវការដោយអង្គភាពបកប្រែភាសា អ.វ.ត.ក ភាគីមិនគប្បីប្រើប្រាស់ឯកសារដែលត្រូវបានបកប្រែក្រៅផ្លូវការដោយសមាជិកក្រុមការងាររបស់ខ្លួនទេ ហើយវិធីដែលសមស្រប គឺគប្បីស្នើសុំការបកប្រែឯកសារផ្លូវការជាមុន។

ប្រសិនបើករណីបែបនេះកើតមាន និងដើម្បីជៀសវាងការពន្យារពេលស្តាប់សក្ខីកម្មសាក្សី អ្នកជំនាញ អ៊ីសា ឧស្មាន អង្គជំនុំជម្រះណែនាំភាគីនានាដែលមានបំណងដកស្រង់ផ្នែកណាមួយនៃឯកសារដែលមានតែមួយភាសាដូចបានបញ្ជាក់ខាងលើនេះ សមាជិកណាម្នាក់ ដែលចេះអាននិងនិយាយភាសានោះគប្បីអានឯកសារដើម ដើម្បីទទួលបានការបកប្រែដោយផ្ទាល់នៅក្នុងសវនាការ។ ជាឧទាហរណ៍ ប្រសិនបើឯកសារហ្នឹងមានតែភាសាអង់គ្លេសដែលជាភាសាដើម សមាជិកម្នាក់នៅក្នុងក្រុមនិយាយភាសាអង់គ្លេសត្រូវអានឯកសារនោះ ដើម្បីអាចបកប្រែដោយផ្ទាល់ទៅជាភាសាខ្មែរ និងជាភាសាបារាំង។ ជាការល្អ សេចក្តីដកស្រង់ដែលនឹងត្រូវអានគប្បីបញ្ជូនទៅអង្គភាពបកប្រែភាសាផ្ទាល់មាត់ជាមុន ដើម្បីសម្រួលដល់ការបកប្រែភាសាបានល្អ និងត្រឹមត្រូវ។

ជាចុងក្រោយ ចំពោះអ្នកជំនាញ អ៊ីសា ឧស្មាន អង្គជំនុំជម្រះសូមជម្រាបលោកថា នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលេខ E367 ដែលតែងតាំងលោកធ្វើជាអ្នកជំនាញ អង្គជំនុំជម្រះសូមបញ្ជាក់ថា លោកអាចត្រូវបានសួរដេញដោលទៅលើបញ្ហាទាំងអស់ដែលជាចំណេះដឹង ឬជំនាញរបស់



Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

លោកពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាមនៅក្នុងសំណុំរឿង០០២/០២។ ករណីនេះ ការវាយតម្លៃភាពពាក់ព័ន្ធនៃសំណួរ និងសក្ខីកម្មរបស់លោក គឺជាបន្ទុករបស់អង្គជំនុំជម្រះ អាស្រ័យហេតុនេះការកំណត់ពិសេសថា តើភស្តុតាងបង្ហាញឲ្យឃើញនូវភាពផ្សាំផ្គុំច្បាប់ អំពីអំពើប្រល័យពូជសាសន៍ ឬការធ្វើទុក្ខបុកម្នេញ ឬមួយជាឧក្រិដ្ឋកម្មផ្សេងៗទៀតនោះ ឬយ៉ាងណានោះ គឺជាភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូងមិនមែនជាបន្ទុករបស់អ្នកជំនាញទេ។

**សៈ** តើលោកយល់បញ្ហានេះដែរឬទេ លោកអ្នកជំនាញ លោក អ៊ីសា ឧស្មាន?

[០៩:២៤:៥៦]

**លោក អ៊ីសា ឧស្មាន៖**

**ឆៈ** បាទ ខ្ញុំយល់បាទ។

**សៈ** បាទ ជាបន្តទៅនេះ យើងមានសំណួរមួយចំនួនដើម្បីមានការពាក់ព័ន្ធបឋមទៅលើភាពជំនាញរបស់លោក។ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ អំពីប្រវត្តិនិងកម្រិតនៃការសិក្សារបស់លោក?

**ឆៈ** ខ្ញុំរៀននៅបានកម្រិតបរិញ្ញាប័ត្រភាសាអង់គ្លេសនៅទីក្រុងភ្នំពេញសកលវិទ្យាល័យបៀលប្រាយ។

**សៈ** ហើយបច្ចុប្បន្ននេះ តើលោកបម្រើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេតពិតមែនដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវហើយបាទ។

**សៈ** គាត់ចាំទេ -- លោកចាំទេ ថាតើលោកបម្រើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹងចាប់ពីពេលណាមកដែរនៅ អ.វ.ត.ក នេះ?

**ឆៈ** ខ្ញុំចាប់ធ្វើការពីឆ្នាំ២០០៧ មកដល់បច្ចុប្បន្ននេះ។

**សៈ** បាទ អរគុណ ហើយលោកអំមិញបានឆ្លើយរួចហើយថាលោកជាបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃតុលាការខ្មែរក្រហម ឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ តើតួនាទីពិតប្រាកដរបស់លោកនៅទីនោះ តើលោកមានតួនាទីអ្វីពិតប្រាកដនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត?

[០៩:២៧:១៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**ឆ៖** ខ្ញុំគឺជាអ្នកវិភាគនៅក្នុងការិយាល័យនេះ។

**ស៖** បាទ អរគុណ។ ចុះរយៈពេលកន្លងមក តើលោកធ្លាប់បានឆ្លងកាត់នៅជា ធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**ឆ៖** បាទ នេះគឺជាការងាររបស់ខ្ញុំមុនពេលដែលខ្ញុំចូលមកក្នុងសាលាក្ដីខ្មែរក្រហម គឺខ្ញុំធ្វើនៅមជ្ឈមណ្ឌលឯកសារពីឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០០៦។

**ស៖** ហើយលោកមានតួនាទី ឬក៏ភារកិច្ចអ្វីដែរនៅក្នុង -- នៅពេលនៅជាបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា?

**ឆ៖** ខ្ញុំគឺជាអ្នកស្រាវជ្រាវខាងផ្នែកជនជាតិចាមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា។

**ស៖** បាទ អរគុណ។ ហើយតើលោកធ្លាប់មានបទពិសោធន៍ ឬក៏ធ្វើការជាអ្នកសារព័ត៌មានដែរឬទេ?

**ឆ៖** ខ្ញុំមិនមានជំនាញ ឬក៏អាជីពជាអ្នកសារព័ត៌មានទេ ប៉ុន្តែខ្ញុំធ្លាប់បានសរសេរជាអត្ថបទខ្លះសម្រាប់ចុះផ្សាយនៅតាមសារព័ត៌មានក្នុងស្រុកមួយចំនួន។

**ស៖** តើលោកជាអ្នកសិក្សាស្រាវជ្រាវទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំគឺមានតួនាទីជាអ្នកស្រាវជ្រាវជនជាតិចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ស៖** តើលោកដែលបាននិពន្ធ ឬក៏សរសេរសៀវភៅ ឬអត្ថបទអ្វីផ្សេងពិសេសទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[០៩:២៩:៤៣]

**ឆ៖** បាទ មាន។ ខ្ញុំបានសរសេរសៀវភៅពីរក្បាល ទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំសូមបង្ហាញជូនលោកប្រធាន នេះសៀវភៅទី១របស់ខ្ញុំ មានចំណងជើងថា "អ៊ូគូបះ" ដែលបកប្រែជាភាសាខ្មែរថា "យុត្តិធម៌" ហើយសៀវភៅទី២ មានចំណងជើងជាភាសាអង់គ្លេសថា "*ឌឹ ចាម រីបេលលាន*" បានន័យថា "ការបះបោររបស់ជនជាតិចាម"។ ហើយក្រៅពីសៀវភៅ ខ្ញុំក៏ធ្លាប់បានសរសេរអត្ថបទមួយចំនួនដែលទាក់ទងពីរឿងរបបកម្ពុជាប្រជាធិបតេយ្យនេះ ដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្ដី "ស្វែងរកការពិត" ហើយនិងសារព័ត៌មានក្នុងស្រុកមួយចំនួន ហើយក៏បានសរសេរ និយាយពីរឿងការស្រាវជ្រាវរបស់ខ្ញុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងនៅក្រៅប្រទេសផងដែរ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**ស៖** បាទ អរគុណ ហើយលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ ហេតុអ្វីបានជាលោកមានការចាប់អារម្មណ៍ក្នុងការរៀបចំ និងសរសេរបានសៀវភៅដែលមានចំណងជើងថា "អ៊ូគូបះ" ហើយនិង "ការបះបោរជនជាតិចាម" ចំនួនពីរក្បាលដែលលោកបង្ហាញយើងអម្បាញ់មិញនេះ។ ហេតុអីបានមានលោកមានចំណាប់អារម្មណ៍នៅក្នុងវិស័យនេះ ហើយទៅសម្រេចចិត្តសរសេរសៀវភៅពីរក្បាលនេះឡើង?

**ឆ៖** បាទ សូមជម្រាបលោកប្រធាន ខ្ញុំក្នុងនាមជាជាតិសាសន៍ចាមមួយរូបដែលបានរងគ្រោះឪពុកម្តាយបងប្អូន ហើយជាពិសេស បងប្អូនរបស់ខ្ញុំមួយចំនួនច្រើនដែលបានស្លាប់បាត់បង់នៅក្នុង ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយឃើញថាអ្នកស្រុកអ្នកភូមិ របស់ខ្ញុំគឺស្លាប់រាប់ពាន់នៅក្នុងរបបហ្នឹង អ៊ីចឹងហើយខ្ញុំតែងតែមានអារម្មណ៍ថា ខ្ញុំត្រូវតែធ្វើការស្រាវជ្រាវដើម្បីបង្ហាញការពិត ថា ហេតុអីបានជារបបនោះមានការកាប់សម្លាប់ជនជាតិរបស់ខ្ញុំ ហើយការសរសេរសៀវភៅនេះ គឺជាផ្នែកមួយចងក្រងប្រវត្តិសាស្ត្រដើម្បីកុំឱ្យមានប្រវត្តិសាស្ត្រនៃការកាប់សម្លាប់នេះកើតឡើងនៅលើទឹកដីកម្ពុជាម្តងទៀត។

**ស៖** បាទ អរគុណ ហើយឥឡូវនេះ យើងសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងសៀវភៅរបស់លោកទាំងពីរ។ ដំបូងនេះគឺ "អ៊ូគូបះ" តើលោកអាចពន្យល់បានដែរទេ ថាពាក្យ "អ៊ូគូបះ" ដែលៗលោកបង្ហាញអំមិញនេះមានន័យច្បាស់លាស់ពិតប្រាកដថាយ៉ាងម៉េច? លោកអំមិញថា "យុត្តិធម៌" តើមានត្រឹមតែន័យប៉ុណ្ណឹង ឬក៏ន័យទូលំទូលាយប្រាកដច្បាស់លាស់ជាងហ្នឹង?

[០៩:៣២:៤៧]

**ឆ៖** ពាក្យថា "អ៊ូគូបះ" នេះ គឺជាពាក្យរបស់អារ៉ាប់ ពីព្រោះប្រជាជនចាម អ្នកកាន់សាសនាអ៊ីស្លាម ហើយសាសនាអ៊ីស្លាម កំណើតនៃសាសនាអ៊ីស្លាម កើតលើទឹកដីអារ៉ាប់។ អ៊ីចឹងយើងប្រើពាក្យអារ៉ាប់ធ្វើជាចំណងជើងនៃសៀវភៅ។ ហើយពាក្យ "អ៊ូគូបះ" នេះ បើបកប្រែជាភាសាខ្មែរតាមដែលខ្ញុំបានពិភាក្សាជាមួយអ្នកជំនាញខាងអក្សរសាស្ត្រអារ៉ាប់ គឺមានន័យថា មានន័យពីរ។ ទី១ មានន័យថា ទណ្ឌកម្ម, ទីពីរ មានន័យថាយុត្តិធម៌។ នៅក្នុងបរិបទ ខ្លះមានន័យថាយុត្តិធម៌ ដូច្នេះខ្ញុំសូមបកប្រែពាក្យ "អ៊ូគូបះ" តាមន័យដែលខ្ញុំចង់បាន បរិបទដែលខ្ញុំសរសេរនេះ គឺមានន័យថា យុត្តិធម៌។

**ស៖** ហើយក្នុងស្នាដៃរបស់លោកដែលមានចំណងជើង "អ៊ូគូបះ" ហ្នឹង តើខ្លឹមសារចម្បងៗនៃសៀវភៅនេះ វារៀបរាប់អំពីអ្វីខ្លះដែរ លោកចងចាំនូវស្នាដៃរបស់លោកដែរ បានដែរទេ? លោកអាច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

01392980



រៀបរាប់បានដែរទេ នូវខ្លឹមសារចម្បងៗនៃសៀវភៅ ដែលជាស្នាដៃនិពន្ធរបស់លោក?

**ឆ៖** សៀវភៅ "អ៊ុំគូបះ" នេះគឺជាសៀវភៅទី១របស់ខ្ញុំ នៅពេលដែលខ្ញុំចាប់ផ្តើមចូលធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខាងមជ្ឈមណ្ឌលនេះមិនទាន់ឲ្យខ្ញុំចុះទៅរកឯកសារនៅកន្លែងណាក្រៅពីបណ្ណាល័យទាំងឡាយនៅទីក្រុងភ្នំពេញ ដូចជានៅទួលស្លែង នៅសារមន្ទី នៅបណ្ណសារដ្ឋានជាតិ នៅមជ្ឈមណ្ឌលឯកសារផ្ទាល់។ អ៊ីចឹងហើយខ្ញុំធ្វើម៉េចស្រាវជ្រាវដើម្បីចងក្រង ប្រមែប្រមូលឯកសារទាំងឡាយដែលទាក់ទងពីរឿងជនជាតិចាម។ ហើយខ្ញុំបានមកធ្វើការស្រាវជ្រាវឯកសារនេះនៅទួលស្លែង ខ្ញុំក៏ឃើញថានៅទួលស្លែងក៏មានការសម្លាប់ជនជាតិចាមរបស់ខ្ញុំដែរ។ អ៊ីចឹងហើយបានជាខ្ញុំចាប់ផ្តើមអានចម្លើយសារភាព ប្រវត្តិរូប និងឯកសារមួយចំនួន ដូចជាទូរលេខដែលទាក់ទងពីរឿងជនជាតិរបស់ខ្ញុំ ហើយខ្ញុំបានប្រមែលប្រមូលទៅ ចងក្រង បន្ថែមពីលើឯកសារដែលខ្ញុំរកបាន គឺយើងបានធ្វើការសម្ភាសសាក្សី អ្នកដែលដឹងរឿង ចាស់ទុំ អ្នកដែលរងគ្រោះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ គឺខ្ញុំបានសម្ភាសមួយចំនួនច្រើន ហើយលទ្ធផល ការសម្ភាសរបស់ខ្ញុំ បូកបញ្ចូលជាមួយនឹងឯកសារដែលខ្ញុំរកបានទាំងប៉ុន្មានហ្នឹង ខ្ញុំបានចងក្រងបានកើតចេញជាសៀវភៅ "អ៊ុំគូបះ" នេះ ហើយខ្ញុំចាំថា ផ្នែកដំបូងក៏មានការបញ្ជាក់អំពីតួលេខប្រជាជនចាម ដែលបានបាត់បង់នៅក្នុងសម័យនោះដែរ។ ហើយជាបន្តបន្ទាប់មកមានករណីដែលខ្ញុំបានស្រាវជ្រាវអំពីការស្លាប់របស់អ្នកទោសម្នាក់ៗ ដែលបានចាប់យកមកមន្ទីរស-២១ ហើយនិងមានការវិភាគនៅផ្នែកចុងក្រោយ។

[០៩:៣៦:៣៧]

**សៈ** បាទ អរគុណ ហើយសៀវភៅ "អ៊ុំគូបះ"របស់លោក ដែលជាថាដែលនិពន្ធរបស់លោកហ្នឹង លោកបានបោះពុម្ពផ្សាយលើកដំបូងនៅពេលណា? ហើយសៀវភៅសរសេរហ្នឹង គឺជាភាសាអង់គ្លេស ឬក៏ជាភាសាខ្មែរ ដែលលោកសរសេរដើមដំបូងហ្នឹង ជាភាសាអង់គ្លេស ឬក៏ជាភាសាខ្មែរ?

**ឆ៖** សៀវភៅបោះពុម្ពជាផ្លូវការនៅឆ្នាំ២០០២ ហើយពេលនុ៎ងគឺ ភាសាអង់គ្លេសខ្ញុំមានកម្រិតទាបនៅឡើយ ដូច្នេះខ្ញុំសរសេរជាភាសាខ្មែរ។ ហើយក៏មានបកប្រែរបស់មជ្ឈមណ្ឌលឯកសារហ្នឹង គាត់បកប្រែចេញជាភាសាអង់គ្លេស ហើយយើងបានបោះពុម្ពផ្សាយជាភាសាអង់គ្លេសតែមួយមុខទេ ខាងភាសាខ្មែរ យើងអត់បានបោះជាផ្លូវការទេ។

**សៈ** បាទ អរគុណ។ ហើយតើសៀវភៅ "អ៊ុំគូបះ" នេះ ដោយកើតឡើង ដោយមានការគាំទ្រពីស្ថាប័ន ឬក៏ពីអង្គការណាមួយ ឬបុគ្គលណាមួយ ឬក៏លោករៀបចំហ្នឹង ត្រូវដោយជា ដោយបុគ្គលខ្លួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ឯងផ្ទាល់តែម្នាក់ឯងទេ?

**ឆ៖** ខ្ញុំធ្វើកិច្ចការនៃការស្រាវជ្រាវសរសេរជាសៀវភៅនេះ គឺក្នុងនាមជាបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះ ថវិកានៃការគាំទ្រឱ្យមានការស្រាវជ្រាវនេះ ហើយនិងការបោះពុម្ពនេះ គឺជាការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

**សៈ** បាទ អរគុណ។ ហើយតើលោកបានធ្វើការស្រាវជ្រាវអ្វីខ្លះ ដើម្បីសរសេរសៀវភៅនេះឡើង ហើយលោកបានប្រើប្រាស់នូវវិធីសាស្ត្រអ្វីខ្លះដែរក្នុងការស្រាវជ្រាវសរសេរសៀវភៅនេះឡើង?

**ឆ៖** បាទ លោកប្រធាន ដូចខ្ញុំជម្រាបជូនអម្បាញ់មិញហ្នឹង គឺសៀវភៅនេះ គឺទី១ផ្អែកទៅលើឯកសារ។ ឯកសារគឺវាមានពីរ មានឯកសារដែលកើត ដែលធ្វើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយនិងឯកសារទី២ គឺឯកសាររបស់អ្នកនិពន្ធ អ្នកជំនាញ អ្នកស្រាវជ្រាវមុនៗខ្ញុំ។ ហើយប្រភពមួយទៀតគឺចេញពីការសម្ភាសផ្ទាល់របស់ខ្ញុំជាមួយជនរងគ្រោះដែលធ្លាប់ឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យ។

**សៈ** បាទ ហើយនៅក្នុងស្រាវជ្រាវ ដើម្បីសរសេរសៀវភៅ "អ៊ំគូបះ" នេះ តើលោកបានជួបសម្ភាសជាមួយនឹងបុគ្គលប្រភេទណាខ្លះ ហើយមានចំនួនប៉ុន្មាននាក់ ដែលតាមការលោក តាមដែលលោកចងចាំ?

[០៩:៤០:១២]

**ឆ៖** បាទ ចំនួនសាក្សី ចំនួនអ្នកដែលខ្ញុំសម្ភាស ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនបានចាំប្រាកដថា ប៉ុន្មានទេ ទាល់តែអង្គុយរាប់ឡើងវិញ ពីព្រោះការសម្ភាសមួយចំនួនយើងយកមកសរសេរ សម្ភាសមួយចំនួនទៀតដែលមិនទាក់ទងពីរឿងប្រធានបទរបស់យើង យើងអត់បានយកមកសរសេរទេ។ អានេះ -- សូមបញ្ជាក់ជូនលោកប្រធានអ៊ីចឹង។

**សៈ** ចុះប្រភេទបុគ្គលដែលលោកបានធ្វើសម្ភាសន៍ដើម្បីរៀបចំសៀវភៅនេះឡើង ដែលជាមូលដ្ឋានក្នុងការរៀបចំសៀវភៅនេះឡើង ក្រុមមនុស្ស បុគ្គលណាខ្លះទៅ ដូចជា -- លោកមិញបានរៀបរាប់ហើយ ជាជនរងគ្រោះ ជាអ្នកដឹងឮ។ តើមានលោកបានសម្ភាសចំពោះមនុស្សដែល កាលនោះ កាលនៅក្នុងរបបនោះ គាត់ជាអ្នកដឹកនាំដូចជាកម្មាភិបាលថ្នាក់ដឹកនាំភូមិឃុំ មូលដ្ឋាន រហូតដល់ថ្នាក់ជាន់ខ្ពស់ ឬក៏កងទ័ព អីដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយលោកប្រធានគឺ អ្នកដែលខ្ញុំសម្ភាសហ្នឹង គឺមានទាំងជនរងគ្រោះ និង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ជនដែដល់។ ជនរងគ្រោះ គឺអ្នកដែលបានឆ្លងកាត់នៅក្នុងរបបនោះ អ្នកដឹងឮពីរឿងរបបនោះ ហើយជនដៃដល់គឺសំដៅទៅលើអតីតមនុស្សមួយចំនួន ដែលធ្លាប់បម្រើការងារនៅក្នុងរបបនោះ តាំងពីថ្នាក់ភូមិ ជាកងឈ្លប ថ្នាក់ឃុំ ថ្នាក់ស្រុក ហើយនិងមនុស្សមួយចំនួនទៀតបាទ។

**សៈ** បាទ តាមការសិក្សាស្រាវជ្រាវរបស់លោក តើលោកអាចបញ្ជាក់អំពីស្ថិតិនៃប្រជាជនចាមក្នុងរបប -- នៅក្នុងប្រទេសកម្ពុជា នៅក្នុងអំឡុងប្រហែលជាពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ? លោកអាចសិក្សាដល់កម្រិតថា អាចមានតួលេខរកឃើញ មានតួលេខប្រជាពលរដ្ឋ ប្រជាជនចាមនៅកម្ពុជាហ្នឹងគឺនៅក្នុងអំឡុងប្រហែលជាពាក់កណ្តាល បានន័យថានៅក្នុងអំឡុងមុន ឬក៏ក្រោយបន្តិចនៃការថ្ងៃ១៧ មេសា ឆ្នាំ៧៥ ដែរឬទេ?

[០៩:៤៣:១៧]

**ឆៈ** ខ្ញុំបញ្ជាក់ពីរឿងទូរលេខនេះ គឺ តាមការស្រាវជ្រាវរបស់ខ្ញុំ គឺអត់ទាន់មានឯកសារដែលសរសេរចងក្រងឱ្យច្បាស់ថាមានប៉ុន្មានទេ។ ប៉ុន្តែផ្អែកទៅលើការសម្ភាសរបស់ខ្ញុំជាមួយអ្នកដែលបានឃើញឯកសារ ពីព្រោះឯកសារហ្នឹងត្រូវបានខ្មែរក្រហមបំផ្លាញអស់ អត់មានសល់ទេ បើសិនជាខ្មែរក្រហមអត់បានបំផ្លាញឯកសារទេ គឺប្រាកដជាមាន។ អ៊ីចឹងចំនួន ផ្អែកទៅលើសាក្សីដែលបានឃើញឯកសារ។ សាក្សីដែលធ្លាប់បានដឹង បានឮពីចំនួនប្រជាជនចាមនៅ មិនថានៅក្នុងខែមេសា ៧៥ ទេមុនរបបខ្មែរក្រហមចូលកាន់កាប់។ អ៊ីចឹងគឺនៅក្នុងរបបលន់នល់នៅឡើយ។ អាចថាមុនខែមេសា ៧៥បន្តិចគឺចំនួនប្រហាក់ប្រហែលជា ៧០០.០០០នាក់។

**សៈ** បាទ អរគុណ។ ហើយនៅក្នុងអំឡុងពេលមុនថ្ងៃ១៧ មេសា ៧៥ តើប្រជាជនចាមរស់នៅទីតំបន់ណាច្រើនជាងគេនៅ បើនិយាយក្នុងក្របខ័ណ្ឌទូទាំងប្រទេសកម្ពុជា តើរស់នៅតំបន់ណា ឬក៏ទីមូលដ្ឋានណាមានចំនួនច្រើនជាងគេជនជាតិចាម លោកស្រាវជ្រាវរបស់លោកដឹងដែរទេ? លោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេ?

**ឆៈ** បាទ ប្រជាជនចាមដែលមានចំនួនច្រើនជាងគេ គឺនៅខេត្តកំពង់ចាម ប៉ុន្តែបច្ចុប្បន្ន កាត់ទៅចូលខេត្តត្បូងឃ្មុំ ពីព្រោះកន្លែងនេះវាជិតមកអតីតចម្ប៉ា គឺប្រជាជនចាម គឺជាច្រកចូលដែលប្រជាជនចាមនាំគ្នាភៀសខ្លួនពីអំពើប្រល័យពូជសាសន៍កើតឡើងនៅចម្ប៉ាហ្នឹង គឺច្រកចូលតែមួយ គឺតាមៗព្រំដែនផ្លូវកំពង់ចាមនេះឯង។ អ៊ីចឹងហើយបានថា មកភាគច្រើនត្រូវបានស្នាក់នៅខេត្តកំពង់ចាមភាគខាងកើតនេះ គឺសព្វថ្ងៃមាននៅដូចជាស្រុកត្បូងឃ្មុំ ស្រុកពញាក្រែក ស្រុកមេមត់ ស្រុកដំបែ និងស្រុក

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ក្រុចឆ្មារ។ ហើយចំនួននេះ គឺច្រើនជាង៥០ភាគរយនៃប្រជាជនចាម ដែលបានរស់ទូទាំងប្រទេស ច្រើនជាង៥០ភាគរយនៅក្នុងភាគខាងកើតកំពង់ចាមនេះ។

**ស៖** បាទ អរគុណ។ ហើយតាមការស្រាវជ្រាវរបស់លោក ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើការចេញ និងការអនុវត្តនូវគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាមានគោលនយោបាយអ្វីខ្លះចំពោះជនជាតិចាម លោកអាចរៀបរាប់អំពីមូលដ្ឋានដែលចម្បងៗនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលចេញ និងអនុវត្តចំពោះជនជាតិចាម ដែលមានលក្ខចរិតពិសេសហ្នឹង លក្ខណៈពិសេសតែចំពោះជនជាតិចាមហ្នឹង មានអ្វីខ្លះទៅតាមការស្រាវជ្រាវរបស់លោក?

[០៩:៤៧:០៧]

**ឆ៖** បើនិយាយពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ យើងរកជាក្រដាសស្នាមក៏អត់ឃើញដែរ អត់ឃើញក្រដាសស្នាមណាមួយដែលថា សរសេរតាំងពីថ្នាក់មជ្ឈិមមក មកបោសសម្អាតតែចាមទេ ប៉ុន្តែផ្អែកទៅលើអ្នកដែលបានឃើញឯកសារ ផ្អែកទៅលើអ្នកដែលបានចូលរួមប្រព្រឹត្តបម្រើនៅក្នុងរបបនោះ។ សាក្សីដែលៗបម្រើការនៅក្នុងរបបនោះ ហើយផ្អែកទៅលើសកម្មភាពជាក់ស្តែងសកម្មភាពនៃការរងគ្រោះរបស់ជនជាតិចាម គឺបង្ហាញថា ចាម ជនជាតិចាមត្រូវបានប្រមូលផ្តុំ ដើម្បីធ្វើការកាប់សម្លាប់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំសូមស្នើថា ឲ្យសាក្សីបញ្ជាក់ឲ្យបានច្បាស់អំពីកាលបរិច្ឆេទនៅពេលដែលគាត់និយាយអំពីគោលនយោបាយ ព្រោះថាគោលនយោបាយមានការផ្លាស់ប្តូរ។ ដូច្នេះចង់ឲ្យគាត់បញ្ជាក់ឲ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទ។ ខ្ញុំចង់និយាយនេះ គឺនិយាយអំពីកាលបរិច្ឆេទថ្ងៃខែឆ្នាំប្រហាក់ប្រហែល។

[០៩:៤៨:៤៥]

**ប្រធានអង្គជំនុំ៖**

បាទ ហើយលោកនៅមានពេលសួរក្រោយយើង យើងសួរជាមូលដ្ឋានបឋម។ សំណួរបឋមហើយបើបានយល់ដឹងអំពីស្ថានភាពទូទៅប៉ុណ្ណោះ។ ហើយបញ្ហាជាក់លាក់ ទុកដល់ពេលលោក ពេល

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01392984



វេលាដែលលោកសួរ លោកអាចសួរបញ្ជាក់ចំណុចទាំងឡាយបំពេញបន្ថែមតាមបំណងរបស់លោកទៅចុះ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ហើយតាមការសិក្សាស្រាវជ្រាវរបស់លោក តើហេតុអ្វីលោកអាចបង្ហាញបញ្ជាក់បានដែរទេថា ហេតុអ្វីបានជាបក្សកុម្មុយនីស្តកម្ពុជា មានចេតនាកម្ទេចជន ក្រុមជនជាតិចាម?

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ ជម្រាបជូនលោកប្រធាន។ មកដល់សព្វថ្ងៃនេះ ខ្ញុំនៅតែមានការងឿងឆ្ងល់នៅឡើយថាហេតុអីបានជាគេនាំគ្នាសម្លាប់ចាមអ៊ីចឹង ពីព្រោះបើនិយាយទៅ កាលពី៧៥ ប្រជាជនចាមរស់នៅជាសហគមន៍។ ប្រជាជនចាមមានភាពរឹងទទឹង មិនព្រមលះបង់សាសនា មិនព្រមលះបង់ប្រពៃណី ដូចជាការបង្ខំឲ្យឈប់និយាយចាម។ គេនាំគ្នាឈប់ហើយ គេខ្លាចស្លាប់ បង្ខំឲ្យហូបសាចជ្រូក ក៏នាំគ្នាហូបដែរ ខ្លាចស្លាប់។ ប៉ុន្តែខ្ញុំនូវតែឆ្ងល់ថា ហេតុអីដល់ពេលឆ្នាំ៧៧ លែងមានសហគមន៍ចាម។ ចាមទៅរស់នៅក្នុងសហគមន៍ខ្មែរអស់ទៅហើយ និយាយជាភាសាខ្មែរ ហូបដូចខ្មែរ ធ្វើតាមរបៀបរបបខ្មែរអស់ទៅហើយ នាំគ្នាទៅសម្លាប់ចាមទៀត។ ហ្នឹងទាល់តែសួរខាង អ្នកដែលគ្រប់គ្រងរបបហ្នឹងវិញ ប្រហែលជាដឹងជាងខ្ញុំ។

**ស៖** បាទ អរគុណ។ ហើយតើលោកអាចការសិក្សាស្រាវជ្រាវរបស់លោក លោកដឹងអំពីចំនួន -- អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួលោក លោកស្រីចៅក្រម។ ខ្ញុំបានពិនិត្យមើលម្តងទៀតលើឯកសារ E215 របស់អង្គជំនុំជម្រះ ជាពិសេសនៅកថាខណ្ឌ១៦ ដែលអង្គជំនុំជម្រះបានពិចារណាដូចតទៅនេះ។ ខ្ញុំសូមដកស្រង់ -- ស្តាប់ទៅដូចជាអត់មានការបកប្រែ តើមានបញ្ហាអ្វីឬទេ?

[០៩:៥២:០៧]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញម្តងទៀត។ ដូចមិនមានបញ្ហាអីទេ គ្រាន់តែមានការបកប្រែហ្នឹង យឺតជាងធម្មតាបន្តិចប៉ុណ្ណោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមានបំណងជំទាស់ទេ គ្រាន់តែចង់ឲ្យមានការបញ្ជាក់បំភ្លឺចំពោះការពិចារណារបស់អង្គជំនុំជម្រះនៅក្នុងឯកសារ E215 ជាពិសេសនៅត្រង់កថាខណ្ឌ១៦។ ហើយខ្ញុំសូមអានដូចតទៅនេះ សូមដកស្រង់៖ "អ្នកសាក្សី អ្នកជំនាញ មិនអាចបញ្ចេញមតិយោបល់ទាក់ទងទៅនឹងបញ្ហា<សំខាន់បំផុតនៃអង្គហេតុបានទេ ហើយមានតែ>អង្គជំនុំជម្រះ<ប៉ុណ្ណោះទើបអាចធ្វើការសម្រេចប្រកបដោយសុភវិនិច្ឆ័យលើបញ្ហាសំណុំរឿងនេះ>។" <ហើយអង្គជំនុំជម្រះនិយាយយោងទៅដល់សេចក្ដីសម្រេចរបស់តុលាការ អាយ.ស៊ី.ធី.អ័រ។ លោកបានស្នើសុំឲ្យអ្នកជំនាញបញ្ចេញមតិយោបល់របស់គាត់ ទៅលើអ្វីដែលអាចជាបញ្ហាសំខាន់បំផុតនៃអង្គហេតុ អាចជាគោលនយោបាយមួយក្នុងការកម្ទេច ឬសម្លាប់ ឬបំផ្លាញ ក្រុមមួយដែលបានកើតឡើង។>

ខ្ញុំហាក់បីដូចជាភ្ញាក់ផ្អើលបន្តិចចំពោះកថាខណ្ឌមួយនេះ ដែលអង្គជំនុំជម្រះបានសម្រេចខ្លួនឯងហើយនិងសំណួរពីចុងក្រោយដែលអង្គជំនុំជម្រះបានសួរទៅសាក្សីនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ពិតណាស់ថា មេធាវីការពារក្ដីបានលើកនូវចំណុចដែលត្រឹម -- ដែលល្អ ហើយ<ការសម្រេចរបស់>ខាងអង្គជំនុំជម្រះក៏លើកយកចំណុចល្អ <ថាអ្នកជំនាញមួយរូបមិនអាចបញ្ចេញមតិយោបល់លើបញ្ហាសំខាន់ ដែល>អង្គជំនុំជម្រះ<ត្រូវ>សម្រេច<នោះទេ ហើយ>បញ្ហាសំខាន់<នៃ>អង្គហេតុ <ឬក៏>ថាតើភស្ដុតាងវាបង្ហាញហួសពីវិមតិសង្ស័យ ឬក៏អត់។ ដូច្នេះការដែលឲ្យសាក្សី អ្នកជំនាញផ្ដល់មតិ<ដែលមិនមែនជាការសម្រេចចុងក្រោយបំផុត ថាតើភស្ដុតាងហួសពីវិមតិសង្ស័យឬអត់នោះ ឧទាហរណ៍ដូចជាសួរអ្នកជំនាញ ដូចដែលលោកប្រធានទើបតែបានសួររួចមកហើយថា តើគាត់មានព័ត៌មាន>អំពីមូលហេតុនៅពីក្រោយ<គោលនយោបាយនៃ>ការសម្លាប់<ឬទេ គឺជាបញ្ហាដែលអង្គជំនុំជម្រះអាចពិចារណាក្នុងការធ្វើសេចក្ដីសម្រេចស្ថាពរ>។ ដូច្នេះហើយ វាមិនមែនជាការសួរ<សាក្សី ឧទាហរណ៍>ថា <">តើ<ភស្ដុតាងបង្ហាញពីចេតនាមួយក្នុងការបំផ្លាញក្រុមមួយទាំងមូល ឬក៏ដោយផ្នែក?" នេះជាបញ្ហាសំខាន់ដែលមិនគួរណាអនុញ្ញាត>ឲ្យសាក្សីអ្នកជំនាញគាត់បញ្ចេញយោបល់ទៅលើបញ្ហាទាំងអស់នេះ<ទេ>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**Deleted:** ន

**Deleted:** -- សាក្សីជំនាញជួយបញ្ជាក់បំភ្លឺនិយាយជាបរិបទរួម ឬផ្ដល់ការជឿជ្រាមជ្រែងបន្ថែម សម្រាប់ឲ្យ

**Deleted:** វាយតម្លៃលើភស្ដុតាង។ ដូច្នេះ សាក្សីអ្នកជំនាញ មិនអាចផ្ដល់យកមតិយោបល់លើបញ្ហាអង្គហេតុស្នូលនានានោះឡើយ

**Deleted:** ា

**Deleted:** នៅ

**Deleted:** ។

**Deleted:** បាន

**Deleted:** ។ ប៉ុន្តែ

**Deleted:** គឺថា តើ

**Deleted:** ហ្នឹង វា

**Deleted:** អំពីអង្គហេតុ គឺហាក់ដូចជាមិនមែនជាគោលដៅចុងក្រោយនៃការសាកសួរអ្នកជំនាញ នោះឡើយ។ ដូច្នេះ ដូចដែលលោកប្រធានទើបតែបានធ្វើ គឺថាសាក្សីគាត់មានមូលហេតុនៅ -- គាត់មានទស្សនៈ

**Deleted:** ។ ដូច្នេះហើយ នេះគឺជាសម្រេច

**Deleted:** សាក្សីយល់ឃើញយ៉ាងណា ... [1]

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**សួរដោយប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយយើងបានផ្តែកលើការសិក្សា ស្រាវជ្រាវរបស់លោកជាមូលដ្ឋានប៉ុណ្ណោះ យើងមិនមានបំណងអ្វីនិយាយឲ្យលើសពីស្នាដៃនិពន្ធ និងចំណេះដឹងរបស់លោកដែលលោកមានទេ បើលោកមិនមាន ក៏លោកឆ្លើយថាមិនមានទៅ។ ហើយគ្រាន់តែរំឭកអ្នកជំនាញលោក អ៊ីសា ឧស្មាន ថា ករណីដែលលោកអាចឆ្លើយបានគឺលោកឆ្លើយ លោកឆ្លើយមិនបានគឺលោកអាចមិនបាច់ មិនឆ្លើយថាលោកមិនអាចយល់បាន ឬក៏លោកអាចក្តាប់បញ្ហានោះមិនបានប៉ុណ្ណឹងទៅបានហើយ លោកជៀសវាងជំរុញឲ្យអង្គជំនុំជម្រះហ្នឹងទៅសួរគោលដៅបុគ្គលផ្សេងទៀត អង្គជំនុំជម្រះយល់ថាតើត្រូវធ្វើយ៉ាងម៉េច ហើយនៅក្នុងសំណុំរឿងក្តីដ៏ស្មុគស្មាញនេះ។ អង្គជំនុំជម្រះសិក្សាជាបន្តបន្ទាប់ក្នុងការស្វែងយល់អំពីភស្តុតាងនានាដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ដើម្បីស្វែងរកការពិត ថាតើត្រូវស្តាប់សក្ខីកម្មសាក្សីរូបណា អ្នកជំនាញណា ដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះដែលមានភាពពាក់ព័ន្ធខ្លាំងទៅក្នុងសំណុំរឿង។

**ស៖** តាមការសិក្សាស្រាវជ្រាវរបស់លោក តើលោកអាចដឹងដែរទេ ជនជាតិចាមដែលរស់នៅក្នុងកម្ពុជាដែលនៅរស់រានមានជីវិត ក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរំលំទៅ គឺថ្ងៃ០៧ មករា ៧៩ ក្នុងអំឡុងពេលនេះ តើការសិក្សាស្រាវជ្រាវរបស់លោកជនជាតិចាមនៅទូទាំងប្រទេសហ្នឹង សរុបនៅសល់ប្រហែលប៉ុន្មានដែរ?

[០៩:៥៦:៤៩]

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បើតាមប្រភពនៃការស្រាវជ្រាវរបស់ខ្ញុំបង្ហាញថា ជនជាតិចាមដែលនៅសេសសល់ពីការស្លាប់ គឺមានចំនួនមិនប្រាកដទេ ប៉ុន្តែប្រហាក់ប្រហែល២០០.០០០នាក់។

**ស៖** បាទ អរគុណ។ យើងតនេះយើងចូលក្នុងទៅសៀវភៅមួយទៀតពាក់ព័ន្ធនឹងការសៀវភៅដែលមានចំណងជើងថា "ការបះបោររបស់ជនជាតិចាម"។ ហើយនៅចំពោះសៀវភៅមួយនេះ "ការបះបោរជនជាតិចាម" តើរឿងរ៉ាវរបស់អ្នករស់នៅក្នុងភូមិត្រូវរៀបចំចងក្រងឡើងនៅឆ្នាំណាដែរ? ពីឆ្នាំណាដល់ឆ្នាំណា ទើបបានរៀបចំនិពន្ធបានស្នាដៃសៀវភៅ "ការបះបោររបស់ជនជាតិចាម" នេះ?

**ឆ៖** សៀវភៅទី២របស់ខ្ញុំ "ការបះបោររបស់ជនជាតិចាម" បានបោះពុម្ពជាផ្លូវការ ជាភាសាអង់គ្លេសនៅឆ្នាំ២០០៦ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាដូចគ្នា។

**ស៖** ការដែលលោករៀបចំសរសេរជាសៀវភៅនេះឡើង តើលោកសរសេរជាភាសាអង់គ្លេស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងឌូបកប្រែ និងឌូបកប្រែបន្ទ។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

01392987



ឬក៏ជាភាសាខ្មែរ?

**ឆ៖** បាទ ដូចសៀវភៅទី១ដែរ គឺខ្ញុំសរសេរដើមជាភាសាខ្មែរ ហើយក្រោយមកបានត្រូវបានបកប្រែជាភាសាអង់គ្លេស ហើយបោះពុម្ពផ្សាយជាភាសាអង់គ្លេស។

**ស៖** បាទ អរគុណ។ ហើយតើលោកមានផ្អែកលើប្រភពណាខ្លះដែលលោកយកមកធ្វើជាមូលដ្ឋានសំអាងក្នុងការរៀបចំសរសេរសៀវភៅនេះឡើង?

**ឆ៖** សៀវភៅនេះគឺភាគច្រើន ប្រភពដែលខ្ញុំបានដកស្រង់ សរសេរចេញជាសៀវភៅនេះគឺតាមរយៈនៃការសម្ភាសរបស់ខ្ញុំផ្ទាល់ជាមួយជនរងគ្រោះដែលភាគច្រើនជាជនជាតិចាម ហើយនិងមួយចំនួនក៏ជាជនដែលដល់នៃរបបនោះដែរ។ ហើយជនរងគ្រោះគឺភាគច្រើនអ្នកដែលសេសសល់មានជីវិតពីការបះបោរប្រឆាំងជាមួយនឹងរបបខ្មែរក្រហមចេញពីភូមិពីរ នៅក្នុងស្រុកក្រូចឆ្មារ។

[០៩:៥៩:៤៨]

**ស៖** បាទ ហើយដូចសំណួរដូចមុនដែរ តើលោកបានជួបសម្ភាសជាមួយនឹងបុគ្គលប្រភេទណាខ្លះក្នុងការរៀបចំសៀវភៅនេះ? ហើយមានចំនួនប្រហែលប៉ុន្មាននាក់ដែរ?

**ឆ៖** បាទ លោកប្រធាន ខ្ញុំសារភាពថា ខ្ញុំមិនចាំចំនួនប្រាកដប្រជាទេ ពីព្រោះស្រាវជ្រាវតាំងពីមុន២០០៦ បោះពុម្ពផ្សាយឆ្នាំ២០០៦។ ហើយជំពូកមនុស្សដែលខ្ញុំសម្ភាស ដូចខ្ញុំជម្រាបអម្បាញ់មិញ គឺទី១ អ្នកដែលរងគ្រោះផ្ទាល់ អ្នកដែលសេសសល់ជីវិតពីការកាប់សម្លាប់ ហើយទី២ គឺអតីតកម្មាភិបាលដែលធ្លាប់បម្រើការជាសន្តិសុខ ជាឃាតករនៅក្នុងរបបនោះ។

**ស៖** បាទ ហើយតាមខ្លឹមសារ តើខ្លឹមសារដែលសំខាន់ៗនៃសៀវភៅបះបោរជនជាតិចាមនោះ តើលោកផ្តោតលើបញ្ហាអ្វីសំខាន់ចម្បងនៅក្នុងស្នាដៃនិពន្ធរបស់លោក?

**ឆ៖** សៀវភៅនេះ គឺមានប្រាំមួយផ្នែក។ ផ្នែកទី១ គឺនិយាយអំពីការចូលកាន់កាប់របស់ខ្មែរក្រហម អំពីបដិវត្តខ្មែរក្រហម អំពីវិធីសាស្ត្រដែលខ្មែរក្រហមបានធ្វើការលួងលោមទៅដល់ជនជាតិចាមនៅមុនឆ្នាំ៧៥ គឺចាប់តាំងពី៧០, ៧១, ៧២, ៧៣ រហូតមក។ ហើយផ្នែកទី២ និយាយអំពីការចាប់ៗប្រជាជនចាមនៅតាមភូមិនីមួយៗដូចជាចាប់អ្នកដែលចេះដឹងខាងសាសនា អ្នកដែលមានជីវភាពធូរធារជាមេដឹកនាំសាសនា ជាអ្នកដែលគេគោរពនៅក្នុងភូមិអីហ្នឹង ចាប់ហ្នឹង មុន៧៥ទៅទៀត។ ហើយផ្នែកទី៣ គឺនិយាយអំពីការបះបោររបស់ជនជាតិចាមនៅភូមិកោះផល។ ហើយជំពូកទី៤ និយាយអំពីការបះបោររបស់ជនជាតិចាមនៅភូមិស្វាយឃ្លាំង ជាភូមិកំណើតជាទឹកដីរបស់ខ្ញុំផ្ទាល់។ ហើយទី៥ គឺនិយាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

អំពីជនជាតិចាម វាសនារបស់ជនជាតិចាមក្រោយពីការបះបោរ ពិសេសគឺមានការសម្លាប់រង្គាលនៅឆ្នាំ ៧៧។ ហើយជំពូកទី៦ មានឯកសារយោងមួយចំនួន ហើយនិងឯកសារពាក់ព័ន្ធខ្លះៗទៀត។

[១០:០៣:១១]

**ស៖** បាទ តាមការសិក្សាស្រាវជ្រាវរបស់លោក តើលោកអាចបញ្ជាក់បានដែរទេ ការបះបោរជនជាតិចាមហ្នឹង ចាប់ផ្ដើមកើត កកើតដំបូងនៅថ្ងៃខែឆ្នាំណាដែរនៃការដែលមានចលនាបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់ខ្មែរក្រហមជាលើកដំបូង លោករកឃើញដែរទេ ហើយលោកចងចាំដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាបបញ្ជាក់អង្គសវនាការថា ការបះបោរធំៗមានពីរនៅក្នុងស្រុកក្រូចឆ្មារ ប៉ុន្តែមុននឹងធំពីរហ្នឹង គឺមានតូចមួយ ទ្រង់ទ្រាយតូច។ អ៊ីចឹងខ្ញុំនិយាយអំពីរឿងតូចហ្នឹងកើតឡើងនៅភូមិទ្រា។ ភូមិទ្រានេះនៅក្នុងឆ្នាំ៧៣ ហើយក្រោយមកយើងអត់ចាំថ្ងៃ អត់ចាំខែទេ យើងដឹងតែឆ្នាំ៧៣។ ហើយនៅក្នុងឆ្នាំ១៩៧៥ យើងក៏អត់ដឹងថ្ងៃច្បាស់ដែរ ហើយបើខែប្រហែលជានៅក្នុងខែ១៩ ខែកញ្ញាអាហ្នឹងមានការបះបោរនៅភូមិកោះផល នៅក្នុងស្រុកក្រូចឆ្មារ ហើយប្រហែលជាពីរអាទិត្យមក អ៊ីចឹងប្រហាក់ប្រហែលជាចូលក្នុងខែតុលា ពីព្រោះប្រជាជនចាមពេលហ្នឹងគឺនៅក្នុងរបបខ្មែរក្រហមគ្រប់គ្រងពេញទំហឹងហើយ យើងអត់មានកំណត់ត្រាអីច្បាស់លាស់ ហើយសូម្បីតែនាឡិការមួយសម្រាប់តែមើលថ្ងៃខែ ក៏មិនងាយរកបានមើលដែរ មិនដឹងថាថ្ងៃណា ខែណា។ អ៊ីចឹងប្រហាក់ប្រហែលតាមសាក្សី គាត់ថាប្រហែលជាខែ១០ ហើយខែ១០នេះ បើនិយាយពីខែអ៊ីស្លាមនៅក្នុងខែ រ៉ាម៉ាដន គឺថ្ងៃទី២៩ នៃខែរ៉ាម៉ាដនអាហ្នឹងខែអ៊ីស្លាម ច្បាស់ គេចាំច្បាស់ ថ្ងៃទី២៩ ខែរ៉ាម៉ាដន ប្រហែលជានៅក្នុងខែ១០ ឆ្នាំ៧៥ គឺមានការកើតបញ្ហាបះបោរប្រឆាំងជាមួយក្រុមខ្មែរក្រហមនៅភូមិស្វាយឃ្លាំង។

**ស៖** បាទ អរគុណ ហើយចុះព្រឹត្តិការណ៍នៃការបះបោរជនជាតិចាមនៅឃុំស្វាយឃ្លាំងហ្នឹងបណ្ដាលមកពីមូលហេតុអ្វីដែរ ដំបូងឡើយ បណ្ដាលមកពីហេតុអ្វីចម្បងៗ សំខាន់ៗដែលនាំឱ្យកើតមានចលនាបះបោរប្រឆាំងនឹងការគ្រប់គ្រងរបស់ខ្មែរក្រហម?

[១០:០៥:០០]

**ឆ៖** បាទ លោកប្រធាន ការបះបោរនេះគឺកើតឡើងនៅកោះផលមុនៗ ស្វាយឃ្លាំង ប៉ុន្តែលោកប្រធានសួរខ្ញុំស្វាយឃ្លាំង ខ្ញុំក៏ឆ្លើយស្វាយឃ្លាំងមុនទៅ។ គឺស្វាយឃ្លាំងនេះ និយាយទៅ ខុសពីកោះផលបន្តិច ខុសត្រង់ថា អ្នកភូមិស្វាយឃ្លាំងមិនសូវប៉ះពាល់ចេញមុខតវ៉ាជាមួយខ្មែរក្រហមប៉ុន្មានទេ តាំងពី ៧៣, ៧៤ រហូតដល់ ៧៥ហ្នឹង គឺរណប គេឱ្យបិទវិហារ ក៏នាំគ្នាបិទទៅ គេឱ្យកាត់សក់ខ្លី នារីគេឱ្យ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

កាត់សក់ខ្លី តាមសាសនាអ៊ីស្លាម គេអត់ឲ្យកាត់សក់ទេ គេនាំគ្នាកាត់សក់ទៅ គេឲ្យបើកកុំឲ្យនារីៗគ្រប ក្បាលក៏នាំគ្នា ធ្វើតាមទៅ។ ហើយនៅតែមានការចាប់យកទៅសម្លាប់ៗនៅមន្ទីរសន្តិសុខស្រុកក្រូចឆ្មារ អ៊ីចឹងហើយទោះបីតែធ្វើតាមក៏ស្លាប់ បើមិនធ្វើតាមក៏ស្លាប់ ហើយមុនដែលនាំគ្នាបះបោរហ្នឹង គឺមាន បញ្ជីមួយ ព្រោះសន្តិសុខស្រុកហ្នឹងទៅធ្វើការចុះឡើងនៅផ្ទះអ្នកភូមិមួយដែលបម្រើនិន្ទាការឲ្យខ្មែរក្រហម ហ្នឹង។ បញ្ជីហ្នឹង ឃើញថាថ្ងៃ ពីរបីថ្ងៃទៀតនេះ គេត្រូវការចាប់មនុស្សចំនួនច្រើន ប្រហែលជាជិត ១០០នាក់ ហើយអ៊ីចឹងនាំគ្នាពិភាក្សា កើតឡើងចេញពីក្រុមយុវជន ពិភាក្សាថា បើយើងនៅក៏គេសម្លាប់ អ៊ីចឹង យើងត្រូវតែតដៃទៅ វាគង់តែស្លាប់ដូចគ្នា។ អ៊ីចឹងហើយយប់ នៅពេលយប់ហ្នឹង គឺមានក្រុមយុវជន ហ្នឹង គេនាំគ្នាកាន់ដាវ កើតឡើងពីយុវជន ខ្មែរក្រហមគេទៅចាប់មែន គេដឹងថាផែនការយប់ហ្នឹងចាប់ អ៊ីចឹងយុវជននេះ គេនាំគ្នាកាន់ដាវៗម្នាក់មួយៗ ក្រុមមិនជាធំប៉ុន្មានទេ ប្រហែលជា ប្រាំ ប្រាំមួយនាក់ កាន់ដាវទៅ ឃើញក្រុមខ្មែរក្រហមហ្នឹងដើរចាប់ៗ ស្រាប់តែមកប្រទះយុវជនៗក៏នាំគ្នាដេញកាប់ទៅ ដល់ដេញកាប់ទៅ ក្រុមយុវជនហ្នឹងក៏នាំគ្នាប្រកាស ប្រកូកប្រកាសឲ្យអ្នកភូមិហ្នឹង “ងើបឡើងយើងតស៊ូ ទាំងអស់គ្នា” គេហៅថា “ហ្សាប៊ីលីឡុះ”។ មានន័យថា “តស៊ូ ដើម្បីសាសនាយើង ស្លាប់ដើម្បីសាសនា យើង”។ អ៊ីចឹង អ្នកភូមិផ្សេងៗទៀតក៏ងើបឡើងដូចគ្នា អត់មានផែនការជាក់លាក់ មានមេកើយអីជាក់ លាក់ទេ គឺថាបើយើងនៅក៏ស្លាប់ដែរ អ៊ីចឹងយើងត្រូវតស៊ូ ម្នាក់ៗកាន់ដាវ កាន់កាំបិត ផ្គាក់គ្រប់បែប យ៉ាង កុំឲ្យខ្មែរក្រហមចូលមកចាប់តទៅទៀត។ ហើយដល់ពេលព្រឹកឡើង យើងអ្នកភូមិគេនាំគ្នាជីក ត្រង់សេ ព្រោះគេដឹងថានឹងមានខ្មែរក្រហមមួយចំនួនធំមកបង្ក្រាបហើយកាលណាយើងនាំគ្នាកាប់ក្រុម គេអ៊ីចឹង។ អ៊ីចឹងនាំគ្នាជីកត្រង់សេ ដើម្បីពួនស្ទាក់ការពារទឹកដីហ្នឹង កុំឲ្យខ្មែរចូលមកទៀត ប៉ុន្តែការត តាំងដោយៗដៃជាមួយនឹងអាវុធគ្រប់ធុន ដែលបានបញ្ជូនពីថ្នាក់ឃុំ ពីថ្នាក់ស្រុក ពីថ្នាក់តំបន់។ ការ តតាំងបានតែមួយថ្ងៃតែប៉ុណ្ណឹង ហើយក៏ខ្មែរក្រហមបានចូលលុកលុយបាញ់កាំភ្លើងធំ កាំភ្លើងតូចសម្លាប់ ប្រជាជនចាម ទាំងចាស់ទាំងក្មេង ស្ត្រី ដោយគ្មានរើសមុខ។ ហើយចុងក្រោយ អ្នកដែលតស៊ូត្រូវទម្លាក់ អាវុធចុះ អ្នកដែលសេសសល់ត្រូវខ្មែរក្រហមកៀរយកទៅដាក់ឃុំឃាំង ហើយនៅពេលដែលកៀរ បណ្តើរ គេរើសភាគច្រើនបុរសៗដែលត្រូវរបួស មានកម្លាំងកាយ ដែលតស៊ូជាមួយគេ គេនាំគ្នារើសម្តង មួយៗយកទៅសម្លាប់ គេចាប់យកទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខហ្នឹងវាពេញទៅហើយ អ៊ីចឹងអត់ មានកន្លែងទេ គេដាក់នៅសាលារៀន គេដាក់នៅក្នុងឡថ្នាំ ហើយស្ត្រីគេដាក់នៅក្នុងវត្ត ហើយយើងបាន រងគ្រោះនៅទីនោះ ដោយការអត់បាយ ដោយជំងឺ ដោយរបួស ពិកា ដោយគ្មានការព្យាបាល ស្លាប់ម្តង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

មួយៗ ច្រើនទៀតនៅកន្លែងនោះ។ ចុងក្រោយគេឲ្យយើងជួបជុំគ្នា គេបើក ពីព្រោះការឃុំឃាំងនោះ បុរសនៅផ្សេង ស្ត្រីនៅផ្សេង ហើយក្មេងៗជាកុមារហ្នឹង គេឲ្យនៅជាមួយម្ដាយ។ អ៊ីចឹងប្រហែលជាមួយខែមក គេបើកអ្នកដែលសេសសល់ជីវិតពីស្លាប់ ពីការរើសយកទៅសម្លាប់ហ្នឹង គេឲ្យមករើសរកមើលអ្នកណាប្ដី ប្រពន្ធអ្នកឯង កូនអ្នកឯង ទៅរកជួបគ្នាទៅ។ អង្គការគេត្រូវជម្លៀស បញ្ជូនៗអ្នកឯងហ្នឹងទៅកន្លែងមួយផ្សេង មិនមែនទៅភូមិអ្នកឯងវិញទេ។ ហើយអ៊ីចឹងក៏នាំគ្នាជួបជុំប្រពន្ធកូនខ្លះមក ប្ដីមើលប្រពន្ធមិនយល់ ប្រពន្ធមើលប្ដីមិនយល់ ពីព្រោះវាអត់បាយ អត់ទឹក៣០ថ្ងៃស្ទើរស្លាប់ ស្ទើររស់ទៅហើយ។ អ៊ីចឹងបានគេបញ្ជូនឲ្យទៅរស់នៅលាយឡំជាមួយបងប្អូនខ្មែរនៅក្នុងទឹកដីក្នុងភូមិភាគបូព៌ា ហើយមួយចំនួនទៅភូមិភាគខាងជើង ដែលឆ្លងទន្លេតាមស្ទឹងត្រង់។ នេះសូមជម្រាបលោកប្រធានត្រួសៗប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយការរៀបរាប់ក្បោះក្បាយរបស់លោកពី អ៊ីសា ឧស្មាន ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់អ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក រួមទាំងមន្ត្រីច្បាប់របស់អង្គ -- ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិផង ហើយនិងឲ្យអញ្ជើញគាត់ទាំងពីររូបមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣នាទី ដល់ម៉ោង ១០:៣៣នាទី)*

[១០:៣៣:៣៦]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក អ៊ីសា ឧស្មាន យើងមានសំណួរបន្តិចបន្តួចទៀតទេសួរលោក។ លោករៀបរាប់ច្រើនហើយអម្បាញ់មិញនេះ។ ហើយយើងចង់ដឹងថា តាមការសិក្សាស្រាវជ្រាវរបស់លោក ប្រជាជនចាមមានប៉ុន្មាននាក់ដែរនៅស្វាយឃ្លាំងមុនមានការបះបោរ? ហើយលោកបានស្រាវជ្រាវរកឃើញនូវចំណុចនេះដែរឬទេ?

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ ជម្រាបលោកប្រធាន យើងអត់ដឹងចំនួននាក់ទេ តែដឹងថាចំនួនជាគ្រួសារ គឺមានចំនួនជាងមួយពាន់គ្រួសារ បើខ្ញុំមិនចាំមិនខុសទេ ប្រហែលជា១២៤០គ្រួសារ ព្រោះខ្ញុំមានសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំកន្លែងណាមួយ។ ហើយនៅក្រោយរបបខ្មែរក្រហមដួលរលំ ប្រជាជនដែលនៅភូមិស្វាយឃ្លាំងបានត្រឡប់ទៅវិញ ឃើញសេសសល់ប្រហែលជា១២០គ្រួសារ។ ហើយនេះ ១២០គ្រួសារនេះ មិនមែនគ្រួសារនៅទាំងអស់ទេ គឺបាត់បង់សមាជិកនៅក្នុងគ្រួសារសឹងគ្រប់គ្រួសារទៅទៀត។ យើងរាប់តែក្បាលគ្រួសារទេ។

**ស៖** បាទ អរគុណ។ ហើយឥឡូវនេះ យើងបង្វែរទៅការសិក្សាស្រាវជ្រាវរបស់លោក អំពីការបះបោរជនជាតិចាម ប្រឆាំងនឹងការគ្រប់គ្រងរបស់ពួកខ្មែរក្រហមនៅកោះផល តើកើតឡើងនៅពេលណា ហើយនិងមូលហេតុអីដែលនាំឱ្យមានចលនាបះបោរប្រឆាំងតបតជនជាតិចាមចំពោះពួកខ្មែរក្រហមនៅទីនោះ? លោក តាមការស្រាវជ្រាវរបស់លោក លោកអាចអត្ថាធិប្បាយរៀបរាប់ពីបញ្ហានេះបានដែរទេ កោះផលណ៎ះ! យើងនិយាយពីរឿងកោះផល? អំមិញលោកថា ការសួររបស់យើងហ្នឹង គឺវាមិនតាមលំដាប់លំដោយ ព្រោះកោះផលកើតមុន។ អ៊ីចឹងឥឡូវយើងសួរពីរឿងកោះផល ព្រោះព្រឹត្តិហេតុតែពីរទេ គឺនៅស្វាយឃ្លាំង ហើយនិងកោះផល។

[១០:៣៦:៤៧]

**ឆ៖** នៅកោះផលនេះ គឺមានទ្រង់ទ្រាយខុសពីស្វាយឃ្លាំង ពីព្រោះកោះផលមិនព្រមធ្វើតាមបញ្ជារបស់ខ្មែរក្រហមទេ។ ខ្មែរក្រហមបង្ខំឱ្យបិទវិហារ ឱ្យឈប់ថ្វាយបង្គំព្រះមួយថ្ងៃប្រាំដង ឱ្យលះបង់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01392992



សម្លៀកបំពាក់ប្រពៃណី ធ្វើអ្វីៗប្រឆាំងជាមួយសាសនាអ៊ីស្លាម គឺអ្នកកោះផលទទួលយកអត់បានទេ។ ហើយតាំងការគាបសង្កត់ចាប់ផ្ដើមនៅឆ្នាំ១៩៧៣។ ដល់ធ្វើអត់បាន ខ្មែរក្រហមក៏ពិបាកចូលកោះផលដែរ។ អ៊ីចឹងហើយប្រហែលជាក្នុងឆ្នាំ១៩៧៤ គេហៅប្រធានភូមិកោះផល រួមជាមួយអ្នកដឹកនាំសាសនានៅកោះផលហ្នឹង ហៅមកប្រជុំនៅភូមិផ្សេងក្រៅពីកោះផល ព្រោះខ្ញុំសូមបញ្ជាក់ដែរ កោះផលនេះ គឺជាទឹកដីមួយ ភូមិមួយនៅលើកោះដែលមានទន្លេមេគង្គព័ទ្ធជុំវិញ។ អ៊ីចឹងគេឲ្យអ្នកភូមិ អ្នកប្រធានភូមិហើយនិងអ្នកដឹកនាំសាសនាបីបួនរូបហ្នឹងមកប្រជុំនៅ ឆ្លងទូកមក។ ហើយតាមអ្នកកោះផល ក្ដាប់ផែនការថា ប្រហែលជាការមានការចាប់ហើយ អ៊ីចឹងហើយបានគាត់អត់មកតែគាត់ទេ មានអ្នកហែហមមួយក្រុមធំប្រហែលជា១០០នាក់។ ដល់ពេលមកដល់ទៅ ក៏អត់មានប្រជុំអីពិភាក្សាអីច្បាស់លាស់ទេ ក៏គេនាំគ្នាត្រឡប់ទៅភូមិរបស់គេវិញ។ ហើយសភាពការណ៍នេះ ខ្មែរក្រហមចេះតែបញ្ជូនសារដដែលៗថាឲ្យកោះផលហ្នឹង ឈប់ប្រតិបត្តិសាសនាទៅ ធ្វើតាមបដិវត្តទៅ។ ប៉ុន្តែអ្នកកោះផលមិនព្រមធ្វើទេ គឺនៅតែបន្តធ្វើអ្វីដែលខ្លួនជឿៗ គោរពមានជំនឿ អ្វីដែលប្រពៃណី អ្វីដែលជាតិសាសន៍របស់យើងគោរព គឺយើងនៅតែធ្វើ។

ហើយដល់ពេលមកក្នុង៧៥នេះ គឺខ្មែរក្រហមគេៗចូល។ ចូលទៅដំបូងនេះ គឺមានកម្មាភិបាលថ្នាក់ស្រុក នៅស្រុកក្រូចឆ្មារ មានចៅហ្វាយស្រុក វាចូលមួយលើក ពីរលើក ហើយលើកចុងក្រោយ គឺដែលកើតមានការបះបោរហ្នឹង ពីព្រោះចូលប្រជុំនិយាយ អ្នកកោះផលមិនស្ទូវជាមាត់កទេពេលហ្នឹង ប៉ុន្តែមិនធ្វើតាម។ ហើយដល់ពេលលើកចុងក្រោយនៅឆ្នាំ៧៥ ប្រហែលជានៅក្នុងខែ៨ នៅពេលហ្នឹង គឺថាចំខែបួស ហើយមានប្រធានស្រុកឈ្មោះ តាផា មានកម្មាភិបាលថ្នាក់ស្រុករួមដំណើរ មានសន្តិសុខរួមដំណើរ ទៅហៅអ្នកភូមិកោះផលហ្នឹង ប្រជុំ "ឥឡូវមកប្រជុំមក"។ អ្នកភូមិទាំងអស់មកប្រជុំ ប៉ុន្តែមានកម្លាំងមួយចំនួនហ្នឹងគេអត់ព្រមមកទេ គេត្រៀមថាពួកខ្មែរក្រហមតែធ្វើអីតែមិនស្រួល គេមានកម្លាំងទប់ស្កាត់របស់គេ គេលាក់ខ្លួន។ ដល់ពេលហៅមកប្រជុំ គេនាំគ្នាប្រជុំ។ ប្រជុំនេះ គឺដាក់ផែនការមួយធ្ងន់ធ្ងរៗ គឺគេហៅថា "ផែនការ៥ខ" គេហៅអ៊ីចឹង។ ពាក្យខ្មែរក្រហម គេហៅ "ផែនការ៥ខ"។ ខ្ញុំសូមលើកឡើងអំពីផែនការ៥ខនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

01392993





សូមអរគុណលោកប្រធាន។ យើងបាន -- យើងទាំងអស់គ្នាអានសៀវភៅរបស់លោក ឧស្មាន អស់ហើយ ដូច្នេះ មិនចាំបាច់ឱ្យគាត់ដកស្រង់ ឬក៏លើកឡើងនូវផ្នែកនៃសៀវភៅរបស់គាត់ដែរ។ ហេតុដូច្នេះ ខ្ញុំគិតថាលោកប្រធានគួរបង្គាប់ដល់សាក្សី ឱ្យផ្ដល់សក្ខីកម្មតែទៅលើអង្គហេតុដែលគាត់បានដឹងដោយខ្លួនឯងតែប៉ុណ្ណោះ ព្រោះថាអ្វីដែលគាត់បាននិយាយវាគ្រាន់តែជាចម្លើយដែលគាត់បានដកស្រង់នៅក្នុងសៀវភៅរបស់គាត់តែប៉ុណ្ណោះ ហើយ<មិនត្រូវបញ្ជាក់ថា បញ្ហាភាគច្រើនដែលគាត់កំពុងនិយាយនេះ ឬយ៉ាងហោចណាស់បញ្ហាភាគច្រើនបំផុត>ដែលគាត់<កំពុង>ផ្ដល់សក្ខី<កម្ម> គឺ<>ជា<>អង្គហេតុ<មានទំនាស់នោះទេ។> ដូច្នេះ ខ្ញុំមិនច្បាស់<នូវអ្វីដែល>យើង<បាន>ធ្វើ<តាំងពី>ព្រឹក<មក>នេះ<ទេ។ យើងទាំងអស់គ្នាបានអាន>សៀវភៅរបស់លោក ឧស្មាន។ ដូច្នេះ ខ្ញុំគិតថាវាមិនចាំបាច់ដែលគាត់ត្រូវដកស្រង់នូវសម្រង់វែងៗចេញពីក្នុងសៀវភៅរបស់គាត់នោះឡើយ។

[១០:៤២:៣៥]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមនិយាយដោយសង្ខេប ព្រោះថា<សាក្សីនេះ>ត្រូវបានកោះហៅ<ក្នុង>នាមជា<>អ្នកជំនាញ មិនមែនសាក្សីអង្គហេតុ។ ដូច្នេះ ក្នុងនាមជាអ្នកជំនាញ គាត់មានសិទ្ធិក្នុងការពន្យល់ទៅលើព័ត៌មានដែលគាត់ពឹងផ្អែកទៅលើ។ ទោះបីថាជាអ្វីដែលគាត់បានអាន ស្ដាប់ឮ ឬក៏អ្វីដែលគាត់បានទទួលបទពិសោធន៍ផ្ទាល់ខ្លួន។ ដូច្នេះ ខ្ញុំគិតថាវាអត់មានអ្វីខុសដែលថាសាក្សីរូបនេះបានពន្យល់អំពីអ្វីដែលបានកើតឡើង។ ដូច្នេះ ខ្ញុំគិតថា មេធាវីគាត់អាចសួរសំណួរ <>អំពីអ្វីដែលមាននៅក្នុងសៀវភៅ អ្វីដែលមានហេតុការណ៍<បះបោរនោះ>។

**លោក វិចទ័រ កូប៉េះ៖**

លោកប្រធាន ខ្ញុំគិតថាសាក្សីគាត់អាយុបួនឆ្នាំនៅពេលនោះ នៅឆ្នាំ៧៥។ ដូច្នេះ គាត់គ្រាន់តែពឹងផ្អែកទៅលើអ្វីដែលគាត់បានស្ដាប់ឮតែប៉ុណ្ណោះ។ <ខ្ញុំយល់ឃើញថាពុំមានមូលដ្ឋានក្នុងផ្លូវច្បាប់ ដូច>អ្វីដែលព្រះរាជអាជ្ញាបាននិយាយ<នោះទេ>។ ដូច្នេះ ខ្ញុំគិតថារហូតមកដល់ពេលនេះ គឺថាអ្នកជំនាញគាត់គ្រាន់តែសង្ខេបអំពីចម្លើយដែលគាត់បានប្រមូលផ្ដុំនៅក្នុងសៀវភៅរបស់គាត់តែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

យើងបានតាំងសំណួរ ដោយប្រយ័ត្នប្រយែង យើងតែងតែប្រើពាក្យថា តាមការសិក្សាស្រាវជ្រាវរបស់អ្នកជំនាញ។ យើងមិនសួរអង្គហេតុ ក្នុងឋានៈគាត់ជាសាក្សីដឹងរឿងហេតុផ្ទាល់ទេ គឺ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** ។
**Deleted:** ខ្ញុំគិតថា អ្វី
**Deleted:** បាន
**Deleted:** ថា
**Deleted:** ទៅលើ
**Deleted:** ថា
**Deleted:** កំពុងតែ
**Deleted:** អ្វីទេនៅពេលមួយ
**Deleted:** ទាក់ទងទៅនឹង
**Deleted:** សាក្សី
**Deleted:**
**Deleted:** ឬក៏គាត់អាចមិនសួរសំណួរ
**Deleted:** <>
**Deleted:** ទោះបីថាគាត់អាច ឬមិនអាននៅទីនោះផ្ទាល់ក៏ដោយ ប៉ុន្តែខ្ញុំគិតថាសម្រាប់
**Deleted:** <>
**Deleted:** គ្រាន់តែជាការនេះ
**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)
**Formatted:** Font: 6 pt, Complex Script Font: 6 pt

ឆ្លងកាត់ការស្រាវជ្រាវ។ គាត់រៀបរាប់ប្រាប់យើង ហើយតាមដំណើរនៃសាច់រឿងដែលមាននៅក្នុងការដែលគាត់ចងក្រងជាសៀវភៅពីរក្បាលនោះឡើង។

លោកអាចបន្តការបញ្ជាក់ចុងក្រោយរបស់លោក អំពីការដែលបញ្ជា៥ខ អម្បាញ់មិញនេះ ដើម្បីតាមការស្រាវជ្រាវរបស់លោក តើវាមានខ្លឹមសារ និងមូលហេតុយ៉ាងម៉េចលើបញ្ជានោះ?

[១០:៤៥:១២]

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ ខ្ញុំសូមរៀបរាប់ ខទី១ គឺគេដាក់កំណត់ថា ស្ត្រីដែលជាជនជាតិចាមទាំងអស់ហ្នឹងត្រូវតែកាត់សក់ឲ្យខ្លីរបៀបបដិវត្តន៍ ហើយឈប់ទទូរក្បាលទៀតទៅ។ ខទី២) គឺថាគម្ពីគួរអានដែលជាគោលការណ៍គ្រឹះរបស់សាសនាអ៊ីស្លាមហ្នឹងត្រូវតែប្រមូលយកដុតចោលឲ្យអស់ ហើយទី៣) គឺថាចាមទាំងអស់នៅភូមិកោះផលហ្នឹងត្រូវតែចិញ្ចឹមជ្រូក ហើយត្រូវតែហូបសាច់ជ្រូក។ ហើយខមួយទៀតហ្នឹងគឺថាឲ្យឈប់ថ្វាយបង្គំព្រះ ហើយវិហារទាំងអស់ ស្វ៉ារនៅកោះផលហ្នឹងត្រូវតែបិទទ្វារ។ ហើយខចុងក្រោយគឺថា បុរស និងស្ត្រីជនជាតិចាមហ្នឹង ត្រូវតែរៀបការជាមួយជនជាតិដទៃទៀត កុំឲ្យរៀបការជាមួយចាមដូចគ្នា។ អាហ្នឹងខរបស់គេ។ ប៉ុន្តែទាំង៥ខ នេះគឺអ្នកភូមិកោះផលហ្នឹងមិនអាចទទួលយកខណាមួយបានទេ។

**ស៖** បាទ អរគុណ។ ហើយតាមការសិក្សាស្រាវជ្រាវរបស់លោក តើការប្រព្រឹត្តប្រឆាំង ការតបត បានន័យថាការបង្ក្រាបរបស់ទៅលើជនជាតិចាមដែលមានការបះបោរនៅកោះផលហ្នឹងមានចរិតយ៉ាងលក្ខណៈយ៉ាងម៉េចដែរអំពីការប្រព្រឹត្តរបស់កងកម្លាំង ឬក៏រដ្ឋអំណាចខ្មែរក្រហមជំនាន់នោះដែលបង្ក្រាបទៅលើក្រុមដែលបះបោរនៅកោះផល តាមការស្រាវជ្រាវរបស់ តើលោកបានសិក្សាស្រាវជ្រាវស្វែងយល់អំពីបញ្ហានៃការបង្ក្រាបប្រឆាំងទៅនឹងការបះបោរនោះយ៉ាងដូចម្តេចដែរលោកដឹងទេ?

[១០:៤៧:៥០]

**ឆ៖** ទោះថាទទួលយកបាន ឬក៏មិនបាន គេនៅតែបង្ខំ ហើយមិនព្រមឈប់អង្គប្រជុំទេ គេត្រូវនៅតែបន្តនៃការប្រជុំ។ ហើយប្រជុំនេះគឺខកដល់ម៉ោងត្រូវថ្វាយបង្គំ ហើយពិសេសខែហ្នឹងគឺខែបួស តមចំណីអាហារ គឺប្រជាជនចាមនៅភូមិកោះផលហ្នឹងត្រូវតែស្រាយបួសម៉ោងប្រាំមួយល្ងាចជាងហ្នឹង។ ដល់ពេលគេប្រជុំទៅ គេអត់ឲ្យយើងស្រាយបួសទេ គេប្រជុំតាំងពីថ្ងៃរហូតតទៅ ដល់ម៉ោងស្រាយបួសត្រូវតែស្រាយហើយ ហើយត្រូវតែថ្វាយបង្គំហើយ ដល់ម៉ោងថ្វាយបង្គំ ប៉ុន្តែគេអត់អនុញ្ញាត ហើយគេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

មិនឈប់។ អ៊ីចឹងកំពុងនៅប្រជុំនិយាយមេស្រុកគេនៅតែនិយាយចុះឡើងៗ ក៏មានអ្នកភូមិម្នាក់ងើបឡើង គឺៗស្រែកតាមភាសាអារ៉ាប់ហ្នឹងណ៎ា អង់គ្លេសគេហៅ "*ខល ហ្វ័រ ប្រេយ័រ*" ហ្នឹងខ្មែរយើង ខ្ញុំមិនដឹងថាអីទេ ប៉ុន្តែចាមគេហៅ "អាហ្សាន"។ អ៊ីចឹងគេនាំគ្នាស្រែក គាត់ត្រូវស្រែកហៅទាំងអស់ទៅថ្វាយបង្គំហើយៗពេលហ្នឹង គឺសភាពចលាចល ពីអ្នកភូមិ គាត់ងើបឈរលែងស្ដាប់ប្រធានអង្គប្រជុំហ្នឹងហើយ។ ដល់ពេលហ្នឹងគឺមានក្រុមដែលត្រៀមលក្ខណៈសម្រាប់តបតហ្នឹងក៏ចេញមុខមក។ ដល់ចេញមកខាងខ្មែរក្រហមនេះដោយសារឃើញគ្នាគេអ្នកភូមិហ្នឹងមានគ្នាច្រើនជាង ក៏ដកខ្លួនថយទៅ ដកខ្លួនថយ។ ដល់ពេលព្រឹកឡើង គឺគេនៅតែបញ្ជូនសារមកឱ្យអ្នកភូមិកោះផលហ្នឹងត្រូវតែចុះញ៉ម បញ្ឈប់នូវការតតាំងហ្នឹងទៅឱ្យទទួលយកខទាំងប្រាំហ្នឹងទៅ។ បញ្ជូនសារមក អ្នកភូមិនៅតែមិនទទួលយកទៀត ហើយចុងក្រោយគឺគេបញ្ជូនទាហានៗនេះ គឺមិនធម្មតាទេ គឺមានកាំភ្លើងយន្ត កាំភ្លើងធំគ្រប់ប្រភេទ ពីព្រោះកាំភ្លើងតូចមិនអាចបាញ់ទៅដល់កោះផលបានទេ ពីព្រោះត្រូវឆ្លងទន្លេ។ អ៊ីចឹងគេដាក់នៅម្ខាងត្រើយម្ខាងទន្លេ ដើម្បីបាញ់សម្រុកទៅកោះផល សម្រុកហើយគេបញ្ជូនកងទ័ពរបស់គេតាមទូក តាមកាណូត ឆ្លងទៅជាន់ទឹកដីកោះផល ប្រយុទ្ធតាមរបៀបថ្មើរជើង ហើយអ្នកភូមិហ្នឹងគឺគាត់អត់មានអីទេ ដូចនៅស្វាយឃ្លាំងដែរគឺការពារខ្លួនគាត់គឺមានតែកាំបិត មានតែដាវ ដុំថ្ម ហើយការតតាំងប្រយុទ្ធគ្នាគឺនៅកោះផលនេះរងគ្រោះធ្ងន់ធ្ងរណាស់ ព្រោះគេបាញ់កាំភ្លើង កាំភ្លើងតូចផង ធ្វើឱ្យអ្នកភូមិស្លាប់ៗ ដែលលែងរាប់ដឹងចំនួនប្រាកដថាប៉ុន្មានហើយៗអ្នកដែលជញ្ជូនសពយកទៅកប់ហ្នឹង ក៏ស្លាប់ខ្លួនឯងទៀត ហើយសពត្រូវបានកប់រួមគ្នាក្នុងមួយរណ្ដៅធំ៣០-៤០នាក់ ប៉ុន្តែចុងក្រោយគឺលែងមានអ្នកកប់សព អ្នកភូមិស្វាយឃ្លាំងត្រូវចុះញ៉មឈប់ប្រយុទ្ធតតាំង ហើយអ្នកខ្លះក៏ហែលទឹកឆ្លងទន្លេ ឬក៏ទៅរកកន្លែងណាមានសុវត្ថិភាព ខ្លះចាប់បានត្រូវសម្លាប់ ហើយអ្នកមួយចំនួនដែលនៅសេសសល់ពីការស្លាប់ហ្នឹង គេបញ្ជូនទៅឃុំរកាខ្នុរ។ នៅក្នុងឃុំរកាខ្នុរនេះគេប្រមូលទៅគេដាក់ គេវាយតម្លៃថាកោះផលនេះគឺជាខ្មាំងទាំងអស់ ប៉ុន្តែវាមានប្រភេទខ្មាំង វាមានខ្មាំងទី១ វាមានខ្មាំងទី២ វាមានខ្មាំងទី៣។ ហើយខ្មាំងទី១ ត្រូវបញ្ជូនទៅកន្លែងនេះ ទី២បញ្ជូនទៅកន្លែងនេះ ទី៣ទៅកន្លែងនេះ អាខ្មាំងទីប៉ុន្មានក៏ដោយ កន្លែងដែលគាត់ទៅគឺនៅក្នុងឃុំៗឈូកមានភូមិក្របីក្រៀក ផ្កាដូង ច្រវាក់ដែក បារាយណ៍ ព្រោះខ្មាំងគេបែងចែកជាបួន។ ហើយកន្លែងបួនកន្លែងនេះទីតាំងបួនកន្លែងនេះគឺជាតំបន់មួយគ្រុនចាញ់ ធ្វើឱ្យអ្នកភូមិកោះផលហ្នឹងស្លាប់ៗ។ ក្នុងចំណោមបួនភូមិនេះ គឺមានពីរភូមិស្លាប់ទាំងអស់តែម្ដង នៅសល់ពីរភូមិប្រហែលជាប៉ុន្មានខែក្រោយមកគេត្រូវបញ្ជូនចេញពីកន្លែងស្លាប់ដោយសារគ្រុនចាញ់ អ្នកដែលនៅសេសសល់មួយចំនួនតិច បញ្ជូនចេញ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

គេយកទៅដាក់នៅមួយចំនួនគឺទៅខាងភូមិភាគខាងជើងឆ្លងទន្លេ។ នេះជម្រាបលោកប្រធានត្រួសៗប៉ុណ្ណឹង បាទ។

[១០:៥៣:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការរៀបរាប់ប៉ុណ្ណេះ នេះជាសំណួរបឋមរបស់យើង។ ហើយតទៅនេះយើងនឹងផ្តល់វេទិកាជូនទៅភាគីដើម្បីមានឱកាសដើម្បីសួរដេញដោលចំពោះលោក។ ដំបូងនេះផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ហើយសួរដេញដោលអ្នកជំនាញនេះមុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខមានរយៈពេលមួយថ្ងៃ និងមួយវគ្គនៃសវនាការក្នុងការសួរដេញដោលចំពោះអ្នកជំនាញរូបនេះ។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី សូមលោក<>ជួយ<>ពន្យល់ជូនទៅអង្គជំនុំជម្រះថាតើមានកត្តាអ្វីដែលនាំឱ្យចាមនៅកម្ពុជាកំណត់អត្តសញ្ញាណរបស់ខ្លួនថាគឺជាចាម តើវាខុសប្លែកពីចាម<និងខ្មែរដទៃទៀត>យ៉ាងដូចម្តេច<ខ្លះ>?

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ អរគុណលោកដែលបានសួរសំណួរនេះ។ ចាមមិនជាខុសគ្នាប៉ុន្មានទេ នៅកន្លែងណាក៏ដោយ ព្រោះជាពូជសាសន៍តែមួយដែលចេញពីទឹកដីតែមួយ គឺទឹកដីចម្ប៉ាត្រូវបានឈ្លានពានដណ្តើមយកដោយវៀតណាម។ អ៊ីចឹង មានចាមមួយចំនួននៅកម្ពុជា ចាមមួយចំនួនរស់នៅចិន នៅកោះ នៅហៃណាម ចាមមួយចំនួននៅថៃ មួយចំនួនទៅម៉ាឡេ ប៉ុន្តែយើងនៅនិយាយភាសានៅអាចយល់គ្នាបានចំពោះភាសាយើងអាចយល់គ្នាបាន ហើយសូម្បីតែជនជាតិភាគតិចនៅតំបន់ភ្នំ ដូចជាចារាយ រដែ ក៏អាចយល់គ្នាបានដែរពីព្រោះគាត់ជាពូជអំបូររបស់ចាមដែរ។ ឃើញខុសគ្នាបន្តិចបន្តួចត្រង់សាសនា។ សាសនាគឺមានចាមកាន់សាសនាអ៊ីស្លាម មានចាមមិនមែនកាន់សាសនាអ៊ីស្លាម ពីព្រោះប្រទេសចម្ប៉ាដំបូងឡើយមិនខុសពីប្រទេសខ្មែរទេ គឺកាន់សាសនាហិណ្ឌូ។ នៅពេលដែលខ្មែរត្រឡប់ទៅពីហិណ្ឌូទៅព្រះពុទ្ធ ចាម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**Deleted:** ស្រី

**Deleted:** មកដល់យើងខ្ញុំបន្តិចដោយ

**Deleted:** <>

**Deleted:** នឹ

**Deleted:** នៅកន្លែងដទៃទៀត

**Deleted:** <>

**Deleted:** ដែរ

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

មួយចំនួនពីគឺហិណ្ឌូទៅអ៊ីស្លាម ប៉ុន្តែពេលដែលប្តូរសាសនាហ្នឹងគឺនគររបស់ខ្លួនឯងហ្នឹងដួលរលំ។ អ៊ីចឹង អ្នកខ្លះនៅតែទទួលមនោគមវិជ្ជា ជំនឿជឿជាក់ទៅលើរបៀបរបបហិណ្ឌូនៅឡើយ។ អ្នកខ្លះគឺហិណ្ឌូសុទ្ធ ដូចជាចាមនៅសព្វថ្ងៃនៅវៀតណាមនេះ ហើយចាមនៅកម្ពុជានេះមានអ៊ីស្លាមសុទ្ធ និងអ៊ីស្លាមមួយទៀត របៀបជាអ៊ីស្លាម លាយសាសនាព្រះពុទ្ធផង ឬក៏អាចថាជាៗស្អីដែលសេសសល់ពីហិណ្ឌូខ្លះ ហៅថាចាមអ៊ីម៉ាំសាន់ ហើយគាត់ថ្វាយបង្គំតែមួយអាទិត្យម្តង។ ចំពោះចាមដែលកាន់សាសនាអ៊ីស្លាម ដែលមកពីអារ៉ាប់ មកពិតប្រាកដ គឺថ្វាយបង្គំមួយថ្ងៃប្រាំដង។ អានេះឃើញ សូមបញ្ជាក់ឡើងវិញថា ត្រង់ភាសា មុខមាត់និយាយស្តី ប្រពៃណីគឺដូច អត់ខុសទេ គឺខុស សាសនាអាចមានលក្ខណៈខុសគ្នាតិចតួច។

[១០:៥៧:៤៤]

**ស៖** អរគុណច្រើន។ លោកបាននិយាយថា ថា គឺចាមដែលមកពីចម្ប៉ាមកកម្ពុជា<ដែលជាប្រវត្តិសាស្ត្រមានដីនៅប្រទេសវៀតណាមបច្ចុប្បន្ន ហើយនៅក្នុងសៀវភៅរបស់លោក> លោកនិយាយ<ថាតាំងពី>សតវត្សរ៍ទី១៥ គឺប្រហែលជា<៥០០>ឆ្នាំ មុនរបបកម្ពុជាប្រជាធិបតេយ្យ។ តើសហគមន៍ចាមនៅកម្ពុជាអាចរក្សាអត្តសញ្ញាណខ្លួនបានដោយរបៀបណា? តើមានកត្តាអ្វីខ្លះ ដែលនាំឲ្យសហគមន៍ចាមនៅកម្ពុជាហ្នឹងអាចរក្សាអត្តសញ្ញាណរបស់ខ្លួនបាន?

**ឆ៖** នៅកម្ពុជា ចាមនិយាយភាសាចាម ទី១។ ហើយរបៀបរបបរស់នៅជាចាម បានន័យថា សហគមន៍ចាម យើងអត់ទាន់មានទៅរស់នៅលាយឡំជាមួយសហគមន៍ជនជាតិផ្សេងទេ យើងនៅជាក្រុមចាម និយាយភាសាចាម ទំនៀមទម្លាប់ចាម នៅក្នុងគ្រួសារនិយាយភាសាចាម ឈ្មោះជាចាម។ ហើយយើងមានមោទនភាពជាចាម។ ដូច្នេះយើងអត់មានបាត់បង់អត្តសញ្ញាណទេ ឲ្យតែឃើញ គេថា គេស្គាល់តាមការនិយាយ គេស្គាល់តាមរូបភាពនៃការស្លៀកពាក់ គឺគេដឹងថាចាម។

**ស៖** សូមអរគុណ។ ភាសាចាម តើលោកអាចពន្យល់បានទេថានៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យ ឬក៏<>របបកម្ពុជាប្រជាធិបតេយ្យ<ទើបចាប់ផ្តើម> តើជនជាតិចាមទាំងនោះ អាចនិយាយ និងសរសេរភាសាចាមបានទេ<?> ហើយថាតើភាសាចាមហ្នឹង អាចបន្តពីមួយជំនាន់ទៅមួយជំនាន់ដោយរបៀបណា?

**ឆ៖** នៅពេលណាក៏ដោយ លើកលែងតែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ គឺគ្រប់ជំនាន់ ចាមនិយាយភាសាចាមនៅក្នុងគ្រួសារ សរសេរអក្សរក៏អក្សរចាម ហើយយើងនៅតែដឹងឮពីប្រវត្តិសាស្ត្រ ថាចាមមិនមែនកំណើតជីដូនជីតារបស់យើងនៅក្នុងទឹកដីកម្ពុជានេះទេ គឺមកពីចម្ប៉ា។ ហើយមក -- ដូច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** គឺជារឿងពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រ

**Deleted:** <>

**Formatted:** Condensed by 0.1 pt

**Deleted:** មុន

**Formatted:** Font: Not Bold, Complex Script Font: Bold

**Formatted:** Font: Not Bold, Complex Script Font: Bold

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

មកដល់សព្វថ្ងៃនេះក៏<ដូច>គ្នាដែរ គឺថាយើងនិយាយភាសាចាម ហើយបើចាមឲ្យមកនិយាយភាសាខ្មែរ គាត់ពិបាកនិយាយ។ និយាយមិនសូវច្បាស់ប៉ុន្មានទេ ហើយពាក្យខ្លះក៏គាត់មិនចេះនិយាយទៅទៀត លើកលែងតែអ្នកដែលធ្វើការជាមួយខ្មែរ ដូចខ្ញុំផ្ទាល់បានអាចចេះនិយាយភាសាខ្មែរបានស្ទាត់។

[១១:០១:២២]

**ស៖** ចុះអំពីសាសនាវិញ ឥឡូវនេះ ខ្ញុំផ្តោតតែទៅលើជនជាតិចាមនៅក្នុងប្រទេសកម្ពុជាទេ តើសាសនា<>វាមានសារៈសំខាន់បែបណាដែរ ដើម្បីឲ្យពួកគាត់ហ្នឹងអាចយកមកបញ្ជាក់អត្តសញ្ញាណថាពួកគាត់ គឺជាជនជាតិចាម?

**ឆ៖** កន្លែងនេះហើយ ដែលមានការយល់ច្រឡំនៅក្នុងសង្គមខ្មែរមួយចំនួន ហើយនៅក្នុង -- នៅក្រៅពីស្រុកខ្មែរក៏យល់ច្រឡំ។ យល់ច្រឡំយ៉ាងម៉េច ឲ្យតែអ្នកកាន់សាសនាអ៊ីស្លាម គេច្រើនតែថាជាចាម ហើយការពិតសាសនាមិនអាចកំណត់ជនជាតិបានទេ។ សាសនាអ៊ីស្លាម នៅម៉ាឡេក៏កាន់សាសនាអ៊ីស្លាម ឥណ្ឌូនេស៊ីក៏អ៊ីស្លាម នៅគុយវ៉ែតក៏អ៊ីស្លាម ហើយអ៊ីចឹងអ្នកដែលថ្វាយបង្គំមួយថ្ងៃប្រាំដង ជឿព្រះជឿមហាម៉ាត់ អ្នកហ្នឹងគឺអ៊ីស្លាម ប៉ុន្តែចង់និយាយថា មិនអាចកំណត់ថា អ្នកដែលកាន់សាសនាអ៊ីស្លាមសុទ្ធតែជាចាមទេ។ វាមានការយល់ច្រឡំដែលខ្ញុំនិយាយខាងដើមថា គេឃើញថារឿងភេរវកម្មមួយដែលអ្នកកាន់សាសនាអ៊ីស្លាម លាបពណ៌ថាជាសាសនាអ៊ីស្លាម គេថាអ្នកហ្នឹងជាចាមដែរ។ ការពិតមិនមែនទេ គឺចាម គឺកំណត់ដោយភាសា ដោយប្រវត្តិសាស្ត្រ ដោយវប្បធម៌ គឺមិនមែន មិនអាចកំណត់បានដោយសាសនាទេ។

**ស៖** សូមអរគុណ។ ប្រហែលជាសំណួរមិនច្បាស់ហើយមើលទៅ។ សំណួររបស់ខ្ញុំ គឺថាប្រទេសកម្ពុជាជាប្រទេសដែលប្រជាជនភាគច្រើនកាន់ព្រះពុទ្ធសាសនា។ អ៊ីចឹងនេះ ខ្ញុំសួរថាតើមានកត្តាអ្វីដែលនាំឲ្យគាត់ហ្នឹងអាចរក្សាបាននូវសាសនានេះបាននៅក្នុងប្រទេសកម្ពុជា?

[១១:០៣:៤៣]

**ឆ៖** បាទ លោកលើកឡើងត្រឹមត្រូវហើយ ភាគច្រើននៃប្រជាពលរដ្ឋនៅប្រទេសកម្ពុជាកាន់សាសនាព្រះពុទ្ធ ប៉ុន្តែបើភាគច្រើន ខ្ញុំចង់និយាយថាភាគច្រើននៃអ្នកកាន់សាសនាអ៊ីស្លាម នៅក្នុងប្រទេសកម្ពុជា គឺជាចាម ប៉ុន្តែក្នុងហ្នឹងក៏មានភាគតិចដែរ ដែលកាន់សាសនាអ៊ីស្លាម ហើយមិនមែនជាចាម។

**ស៖** សូមអរគុណ។ ខ្ញុំព្យាយាមរៀបចំសំណួរម្តងទៀត សំណួររបស់ខ្ញុំ គឺសម្រាប់ជនជាតិចាមដែលប្រតិបត្តិសាសនា<អ៊ីស្លាម> តើសាសនា <ការរក្សាសាសនា និងសេរីភាពក្នុងការប្រតិបត្តិ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** ដោយ

**Deleted:** ចាម

**Deleted:** <>

**Deleted:** ចាម

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

សាសនា> ហ្នឹងវាមានសារៈសំខាន់យ៉ាងដូចម្ដេច<>?

**ឆ៖** បាទ អរគុណ ខ្ញុំយល់ច្រើនជាងមុនសំណួរនេះ។ គឺសាសនាអ៊ីស្លាម គឺមានសារៈសំខាន់ៗ អ្នកដែលកាន់សាសនាត្រូវតែគោរពប្រតិបត្តិសាសនារបស់ខ្លួន ហើយចាមក៏អ៊ីចឹងដែរ។ ចាមដែលជឿជាក់លើសាសនា សាសនាអ៊ីស្លាម ជាពិសេសគឺត្រូវតែរក្សាៗទំនៀមទម្លាប់នេះតាំងពីជីដូនជីតារហូត គឺអត់លះបង់ទេ នៅពេលណាក៏ដោយ គឺយើងអត់បាត់បង់សាសនារបស់យើងទេ គឺសាសនារបស់យើងគឺសាសនាអ៊ីស្លាម។ លើកលែងតែនៅក្នុងរបបខ្មែរក្រហមទេ ទោះបីជាមានការបង្ខិតបង្ខំឱ្យបញ្ឈប់ប្រតិបត្តិសាសនាអ៊ីស្លាមក៏ដោយ ក៏ប៉ុន្តែនៅក្រោយរបបហ្នឹង គឺជនជាតិចាមនៅតែទទួលយកសាសនាអ៊ីស្លាមមកប្រតិបត្តិនៅក្នុងសហគមន៍របស់ខ្លួនឡើងវិញ យើងអត់បាត់សាសនាទេ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយទៅនឹងសំណួររបស់លោកប្រធានអំពីទីកន្លែងដែលជនជាតិចាមរស់នៅ_នៅពេលចាប់ផ្ដើមនៅរបបកម្ពុជាប្រជាធិបតេយ្យ ហើយលោកបានឆ្លើយថានៅកំពង់ចាម គឺជាតំបន់ដែលមានជនជាតិចាមប្រមូលផ្ដុំរស់នៅច្រើនជាងគេនៅទីនោះ។ ដូច្នេះខ្ញុំសួរថា តើជនជាតិចាមរស់នៅក្នុងភូមិចម្រុះគ្នាជាមួយនឹងប្រជាជនកម្ពុជាដែរ ឬក៏អត់ទេ?

[១១:០៦:៥១]

**ឆ៖** អត់ទេបាទ មិនមែនទេ យើងរស់នៅដាច់ដោយឡែក ជាសហគមន៍ផ្សេងគ្នា គ្រាន់តែសហគមន៍ហ្នឹង ភូមិហ្នឹងជាប់ៗព្រំប្រទល់ជាមួយភូមិខ្មែរ ប៉ុន្តែយើងអត់រស់នៅឡូកឡំជាមួយជនជាតិខ្មែរទេ។

**ស៖** មានសំណុំឯកសារមួយគឺ <E3/1593> គឺជាសៀវភៅរបស់លោក ប៊ែន គៀរនិន ហើយខ្ញុំសូមដកស្រង់<ថាតើលោកយល់ស្របដែរឬយ៉ាងណា។> ឯកសារ<ជាភាសាខ្មែរលេខ 0063 7755> <>, អង់គ្លេស <00678632>, បារាំង 00639022។ ខ្ញុំសូមផ្ដល់ខ្មែរម្ដងទៀត ហើយសូមយឺតបន្តិចគឺ 00637755។ គាត់បានសរសេរថាអំពីជនជាតិចាម "គេបានរស់នៅប្រហែលជា៧០ភូមិនៅតាមទន្លេមេគង្គនៅកំពង់ចាម នៅ<ប៉ែក>ខាងកើត និងនៅខេត្តកំពង់ឆ្នាំង និងនៅខេត្តពោធិ៍សាត់ភាគខាងលិច។ គឺថាជនជាតិចាម គឺជាជនជាតិបង្កើតបានជាក្រុមជនជាតិភាគតិចមួយ នៅស្រុកក្រូចឆ្មារ ដែលមានចាមរស់នៅច្រើន។ ពួកគេរស់នៅចម្រុះ -- ពួកគេរស់នៅក្នុងភូមិធំ គឺថាមានផ្ទះសម្បែងដំបូលជាប់ៗគ្នា។ នៅក្នុងឆ្នាំ១៩៥០ មានជនជាតិចាមជាង<២០.០០០>នាក់។" តើលោកយល់ស្របទេលោក ដែលថានៅដើមទសវត្សរ៍១៩៧០ហ្នឹង គឺចាមរស់ប្រមូលផ្ដុំទីនោះច្រើនជាងគេ។

**ឆ៖** ខ្ញុំយល់ស្របត្រង់ចំណុចថា គាត់ថា ជនជាតិចាម ទីតាំងដែលជនជាតិចាមរស់នៅ មាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** សេរីភាពក្នុងការប្រតិបត្តិសាសនាទុំងវាមានសេរីភាពយ៉ាងដូចម្ដេច ដែលនាំឱ្យគាត់អាចរក្សាសាសនារបស់គាត់បាន

**Deleted:** <>

**Deleted:** E3

**Deleted:** <>

**Deleted:** មើលគឺ

**Deleted:** E3/15

**Deleted:** <>

**Deleted:** 0067632

**Deleted:** <>

**Deleted:** ត្រើយ

**Deleted:** <>

**Deleted:** ២០០.០០០

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

នៅតាមដងទន្លេមេគង្គ ពិសេសនៅក្នុងខេត្តបី គឺខេត្តកំពង់ចាម ដូចជានៅក្រូចឆ្មារជាដើម នៅកំពង់ឆ្នាំង នៅពោធិ៍សាត់ត្រឹមត្រូវ ប៉ុន្តែមានបន្ថែមទៀតដែរ យើងមិនបាច់លើកទេ ប៉ុន្តែអំពីចំនួន ខ្ញុំមិនថាគាត់ខុសទេ ប៉ុន្តែយើងត្រូវការធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត ដើម្បីឲ្យឃើញការពិត។ ខ្ញុំមិនទាន់ទទួលយកថាត្រឹមត្រូវ ហើយក៏ខ្ញុំមិនថាគាត់ខុសដែរ។

[១១:១០:០៦]

**ស៖** សូមអរគុណ។ ខ្ញុំដឹងហើយ គឺថាលោកដឹងអំពីរចនាសម្ព័ន្ធភូមិភាគនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តើចាមមានតែនៅក្នុងភូមិភាគបូព៌ាទេ ឬក៏មាននៅភូមិភាគដទៃទៀត? តើមានសហគមន៍ចាមនៅជិតភ្នំពេញ នៅ<ភូមិភាគ>បស្ចិម ភូមិភាគ<និរតី> មានជនជាតិចាមរស់នៅភូមិភាគដទៃទៀត<>ដែរទេ?

**ឆ៖** បាទ ពិតជាមាន។ ច្បាស់ណាស់ ស្ទើរតែគ្រប់ភូមិភាគទាំងអស់ ប្រហែលជាមានចាមគ្រប់ភូមិភាគហើយ ពីព្រោះយើងនិយាយពីភូមិសាស្ត្រ ទឹកដីខេត្តដែលចាមនៅស្ទើរតែគ្រប់ខេត្ត គ្រាន់តែខេត្តខ្លះនៅច្រើន ខេត្តខ្លះនៅតិច។ ដូចនៅក្បែរៗភ្នំពេញនេះ ក៏មានតំបន់ដែលចាមរស់នៅតាំងពីដើមកំណើតរហូតមកដល់បច្ចុប្បន្ននេះ។ អ៊ីចឹងអ្នកភ្នំពេញជម្លៀសទៅដល់កន្លែងណា ក៏មានលាយចាមទៅកន្លែងនុ៎ងដែរ។ នៅពោធិ៍សាត់ក៏មាន បាត់ដំបងក៏មាន ខាងកំពតក៏មាន។ លើកលែងតិចណាស់ ដែលគ្មានចាម ដូចជាកំពង់ស្ពឺ ពីដើមអត់មានទេ ប៉ុន្តែមានចាមនៅហួសកំពង់ស្ពឺ ចូលទៅព្រៃទប់ មានចាមដែរ។ អ៊ីចឹងខ្ញុំអាចសន្និដ្ឋានបានថា ស្ទើរតែគ្រប់ភូមិភាគមានចាមរស់នៅ។

**ស៖** នៅក្នុងសៀវភៅរបស់លោក លោកបានសរសេរថា ស្រុកក្រូចឆ្មារ ត្រូវបានចាត់ទុកថាជាកន្លែងមួយដ៏រឹងមាំនៃជនជាតិចាមរស់នៅក្នុងប្រទេសកម្ពុជា។ តើ -- សូមលោកពន្យល់ជូនតុលាការបន្តិចមើលថា ហេតុអ្វីបានជាលោកសរសេរថានៅក្រូចឆ្មារហ្នឹង គឺជា *ហាតលេន* – គឺជាទឹកដីដ៏រឹងមាំ – សម្រាប់ជនជាតិចាម?

**ឆ៖** បាទ នៅក្រូចឆ្មារនេះ ទី១ ភូមិសាស្ត្រទឹកដីនេះ គឺមានប្រជាជនចាមរស់នៅច្រើន។ ទី២ អ្នកដែលចេះដឹងខាងសាសនាអ៊ីស្លាម អ្នកដែល អ្នកប្រាជ្ញពីរឿងជនជាតិចាម ពីរឿងសាសនាអ៊ីស្លាមហ្នឹង គឺបានទៅរៀននៅក្រៅប្រទេសហ្នឹង មួយចំនួនធំហ្នឹងគឺទៅពីស្រុកក្រូចឆ្មារនេះ។ ហើយមួយទៀតមន្ត្រីរាជការ ដែលធ្វើការធំៗនៅក្នុងរាជការពីដើម តាំងពីជំនាន់ស្តេចមុនៗមក មុនព្រះករុណាសម្តេចសីហនុ ហ្នឹងទៅទៀត គឺមានចាមដែលធ្វើការឲ្យរាជការ មានចាមដែលជាមិត្តភក្តិរបស់ស្តេច មានដូច

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: <>

Deleted: បស្ចិម

Deleted: ក្រៅពីភូមិភាគបូព៌ា

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

នៅភូមិស្វាយឃ្លាំងផ្ទាល់ គឺឈ្មោះ ស្លែម៉ាន ហៅ តាបររទេះ។ តានេះគឺជាមិត្តភក្តិជិតស្និទ្ធរបស់ស្ដេចមួយអង្គ មុនព្រះករុណាសម្ដេច សីហនុ នេះ។ អ៊ីចឹងហើយ គឺថាសិស្សដែលចង់ដឹងពីប្រវត្តិសាស្ត្រ ដែលចង់ពីធម៌អាថ៌ត្រឹមត្រូវ គេបញ្ជូនទៅខាងក្រូចឆ្មារហ្នឹងឱ្យទៅរៀន។ អ៊ីចឹងហើយ គឺថាក្រូចឆ្មារនេះ គឺជាទឹកដីរបស់ចាមដែលល្បីល្បាញ ត្រូវគេទទួលស្គាល់ និងមានការកើតសរសើរពីសំណាក់សហគមន៍ចាមផ្សេងៗទៀត នៅក្នុងប្រទេសកម្ពុជា។

[១១:១៤:២៧]

**ស៖** សូមអរគុណ។ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ តើសមាជិកសហគមន៍ចាមណាខ្លះដែលសំខាន់ជាងគេ ដែលនាំមុខក្នុងការរក្សាអត្តសញ្ញាណរបស់ខ្លួន ហើយថាតើ<>មាន<អ្នកដែលមានតួនាទីជាក់លាក់ណាមួយ ឬតួនាទីជា>មេដឹកនាំ <នៅក្នុងភូមិចាមនានាដែរឬទេ>?

**ឆ៖** សូមទោស លោកសួរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏មុនហ្នឹងបាទ ខ្ញុំដូចជាស្ដាប់អត់ទាន់បានអំមិញ។

**ស៖** ខ្ញុំផ្ដោតទៅលើអ្វីដែលកើតមានមុនគោលនយោបាយនៃរបបនោះត្រូវបានយកមកអនុវត្តហើយក្រោយមក<ខ្ញុំនឹងសួរថាតើ>ខ្មែរក្រហមអនុវត្តគោលនយោបាយ<នោះនឹងមានប៉ះពាល់អ្វីខ្លះ>។ នៅក្នុងសៀវភៅរបស់លោក ៗនិយាយអំពីហាកឹម។ អ៊ីចឹងសូមលោកពន្យល់សិនថា ហាកឹមជាអ្វី? តើតួនាទីជា ហាកឹមនេះ ជាតួនាទីមុខងារមួយសំខាន់សម្រាប់ឱ្យចាមរក្សាអត្តសញ្ញាណរបស់ខ្លួនឬ?

**ឆ៖** នៅតាមសហគមន៍ចាម គ្រាប់សហគមន៍ទាំងអស់គឺតែងតែមានហាកឹម មែនហៅថា "ហាកឹម"។ ហាកឹមនេះ គឺផ្ដោតសំខាន់ទៅលើសាសនា មិនមែនប្រវត្តិសាស្ត្រ មិនមែនវប្បធម៌ទេ គឺសាសនា។ អ្នកដែលគ្រប់គ្រងសាសនាអ៊ីស្លាមនៅក្នុងភូមិ។ ខ្ញុំលើកឧទាហរណ៍ សាសនាអ៊ីស្លាមមានច្បាប់នៅក្នុងការបែងចែកទ្រព្យសម្បត្តិ កេរអាករពីឪពុកម្ដាយ។ អ៊ីចឹងនៅពេលដែលកូនចៅត្រូវការចែកការសម្រេចចិត្តទៅលើគ្រួសារ ថាតើគ្រួសារហ្នឹងចង់យកច្បាប់រដ្ឋ ឬក៏ច្បាប់សាសនា។ ហើយការបែងចែកវាអាចខុសគ្នា។ ច្បាប់គឺបែងចែកផ្សេង សាសនាបែងចែកផ្សេង។ អ៊ីចឹងបើគ្រួសារនោះសម្រេចថាយកសាសនា ត្រូវហាកឹម ដើម្បីឱ្យគាត់សម្រេចនៃការបែងចែកមរតករបស់គ្រួសារហ្នឹង។ បើយកតាមច្បាប់រដ្ឋ គាត់ត្រូវទៅមេឃុំ ទៅប៉ូលិស ដើម្បីធ្វើការបែងចែក។ អ៊ីចឹងហាកឹមជាអ្នកមើលការខុសត្រូវជាអ្នកធ្វើកិច្ចទាំងអស់នៅក្នុងសហគមន៍ ទទួលខុសត្រូវខាងផ្នែកសាសនាអ៊ីស្លាម។

[១១:១៧:២៣]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** តំបន់ណាដែលចាមហ្នឹង

**Deleted:** <>

**Deleted:** មានភាពជាអ្នកដឹកនាំហ្នឹងរឹងមាំជាងគេនោះ

**Deleted:**

**Deleted:** <>

**Deleted:** បាន

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**ស៖** បាទ សូមអរគុណ។ ចុះតួនាទីដទៃៗទៀត ដូចជាគ្រូបង្រៀន ឬក៏អ្នកមានតួនាទីក្នុងការរក្សាអត្តសញ្ញាណរបស់ខ្លួនវិញនោះ វាយ៉ាងដូចម្ដេចដែរ?

**ឆ៖** ហាកឹម គឺជាបុគ្គលទី១នៅក្នុងសហគមន៍ ដែលមើលការងារខាងផ្នែកសាសនាធំជាងគេ តែបន្ទាប់ពីហាកឹមក៏មានហាកឹមរងពីរនាក់ទៀត។ ហាកឹមរងនេះ ពេលដែលហាកឹមអវត្តមាន។ ហើយក្រៅពីហាកឹម និងហាកឹមរងនេះ គឺមានតួន។ "តួន"បានន័យថាគ្រូបង្រៀនសាសនា។ អ៊ីចឹងគ្រូបង្រៀនសាសនាពីដើមឡើយ គឺអ្នកភូមិជាអ្នកចិញ្ចឹមគ្រូបង្រៀនឲ្យជាលុយកាក់ ជាអង្ករជាអីអ៊ីចឹងទៅ។ អ៊ីចឹងតួនគាត់ទៅរែអង្គាសខ្លួនឯងទេ។ ហាកឹមជាអ្នករៃអង្គាសពីអ្នកភូមិដោះស្រាយជីវភាពឲ្យតួន។ ហើយបុគ្គលមួយទៀត គេហៅថា "ហាជី"។ ហាជី គាត់ជាអ្នកដែលគេគោរពនៅក្នុងភូមិដែរ ពីព្រោះគាត់បានទៅធ្វើធម៌ គេហៅថា ហាជី តាមភាសាចាម។ ភាសាអារ៉ាប់ គេហៅហាជី ទៅៗធ្វើធម៌ហ្នឹងនៅអារ៉ាប៊ីសាអូឌីត។ ហើយគាត់ត្រឡប់មកវិញ គាត់រស់នៅក្នុងភូមិ អត់មានតួនាទីជាអ្នកដឹកនាំទេ ប៉ុន្តែគេគោរពគាត់ គេដឹងថាគាត់ហ្នឹងមនុស្សល្អ មនុស្សដែលយល់ដឹងពីរឿងសាសនា ពីព្រោះគាត់បានទៅធ្វើហាជីនៅអារ៉ាប៊ីសាអូឌីត។ ហើយក្រៅពីហ្នឹងទៅទៀត អ្នកដែលដឹកនាំសាសនាគេហៅថា "មេចំអះ"។ មេចំអះនេះ បើនិយាយតាមខ្មែរឲ្យស្រួលស្ដាប់គេមេក្រុម។ នៅក្នុងហាកឹម គាត់បែងចែក ឧបមាថាមួយភូមិហ្នឹងត្រូវ១០មេចំអះ។ អ៊ីចឹងក្នុងម្នាក់ត្រូវទទួលខុសត្រូវ ឧទាហរណ៍ថា ១៥គ្រួសារអ៊ីចឹង។ អ៊ីចឹងម្នាក់ហ្នឹងជាមេចំអះ។ អ៊ីចឹងតួនាទីមេចំអះនេះ គឺដូចជាជំនួយការរបស់ហាកឹម ដែលសម្រាប់ចាត់ចែងការងារនៅក្នុងគ្រួសារមួយចំនួនគ្រួសារដែលគេបែងចែកឲ្យហ្នឹង។

**ស៖** សូមអរគុណច្រើន។ ឥឡូវនេះ ខ្ញុំសូមបន្តទៅមុខឲ្យបានលឿនបន្តិច ខ្ញុំសូមចាប់ផ្ដើមពិភាក្សាគ្នាអំពីផលប៉ះពាល់នៃគោលនយោបាយរបស់ខ្មែរក្រហមមកលើជនជាតិចាម។ ខ្ញុំសូមឲ្យលោកបែងចែកថា តើគោលនយោបាយនោះវាអាចចូលរួមពាក់ព័ន្ធដោយរបៀបណាដែរនៅពេលនោះ? យើងមានការពិភាក្សាគ្នាខ្លះៗរួចមកហើយអំពីព្រឹត្តិការណ៍នៅក្នុងឆ្នាំ១៩៧៥ នៅស្វាយឃ្លាំង និងកោះផល។ ខ្ញុំសូមចូលទៅនិយាយអំពីរយៈពេលឆ្នាំ១៩៧០ រហូតមកទល់ពេលដែលកងទ័ពលន់ នល់ ចុះចាញ់នៅថ្ងៃ១៧ មេសា ១៩៧៥។ សូមលោកពន្យល់ជូនតុលាការបន្តិចមើល៍ថា តើគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងជួរណសិរ្សនោះ តើវាប៉ះពាល់មកដល់សហគមន៍ដោយរបៀបណាដែរ?

[១១:២១:១៦]

**ឆ៖** ពីដំបូងឡើយ ពីឆ្នាំ៧០ នៅពេលដែលកើតបដិវត្តន៍ខ្មែរក្រហមគឺអត់មានប៉ះពាល់ទេ ចាម

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងឌូបកប្រែ និងឌូបកប្រែបន្ត។

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

សរសើរស្រឡាញ់ៗខ្មែរក្រហមណាស់ ពីព្រោះខ្មែរក្រហមគាត់ដឹងសុខទុក្ខ ហើយជាពិសេសៗ គឺនៅពេលដែលមានការអំពាវនាវ ព្រះករុណាឱ្យកូនចៅរត់ចូលព្រៃដើម្បីរំដោះ នៅពេលហ្នឹងគឺចាមមួយចំនួនធំគឺអត់ចង់នៅក្រោមការគ្រប់គ្រងរបស់ លន់ នល់ ទេ ពីព្រោះនៅក្រោមសម្តេចឪវាមានការរីកចម្រើន ប្រទេសជាតិរីកចម្រើន អត់មានសង្គ្រាម ចង់បានសម្តេចឪត្រឡប់មកវិញ។ អ៊ីចឹងចាមហ្នឹងក៏នាំគ្នាស្រឡាញ់គាំទ្រចូលបដិវត្តន៍ដើម្បីសម្តេចឪដែរ។ ដល់ពេលបន្តិចម្តងៗ ៧០, ៧១, ៧២ អត់មានការប្រែប្រួលទេ គឺខ្មែរក្រហមនៅតែធ្វើល្អ រហូតដល់ខ្មែរក្រហមខ្លះគឺប្រដៅកូនចៅចាមហ្នឹងឱ្យធ្វើតាមទំនៀមទម្លាប់ចាមកុំឱ្យលះបង់សាសនា កុំឱ្យលះបង់ប្រពៃណី បង្រៀនប្រវត្តិសាស្ត្រចាមឱ្យចាមយល់ទៀត។ អ៊ីចឹងម្នាក់ៗស្រឡាញ់ខ្មែរក្រហមណាស់។ ប៉ុន្តែការប្រែប្រួលចាប់ពីឆ្នាំ៧៣ នៅក្នុងឆ្នាំ៧៣ គឺមានការប្រែប្រួលហើយ គឺមានការចាប់ៗយកទៅដាក់មន្ទីរឃុំឃាំង។ ខ្ញុំធ្វើការសិក្សាស្រាវជ្រាវគឺនៅក្នុងស្រុកក្រូចឆ្មារនេះ គឺឃើញថាចាប់ដំបូងពី៧៣ គេចាប់នេះគឺចាប់អ្នកដែលដឹកនាំសាសនាមាន ហាកឹម មានតួន មានហាជីហ្នឹង មេចំអះអីហ្នឹង គេចាប់យកទៅដាក់ឃុំឃាំង មួយចំនួនធំត្រូវគេសម្លាប់ទៅ ខ្លះហ្នឹងគេចាប់ច្រឡំទៅក៏គេដោះលែងមកវិញមក។ ដល់ពេល៧៤ ក៏នៅតែបន្តការចាប់ ហើយចាប់នេះអត់មានថយទេ ចាប់តាំងពីតិចទៅច្រើន អស់ពីអ្នកដឹកនាំ ចាប់ប្រជារាស្ត្រធម្មតា។ អ៊ីចឹងហើយបានថា ឃើញការប្រែប្រួលអ៊ីចឹង ប្រជាជនចាមក៏លែងមានជំនឿ លែងគាំទ្រទៅដល់ចលនាខ្មែរក្រហមទៀតហើយ ប៉ុន្តែវាហួសពេលទៅហើយ ព្រោះទឹកដីហ្នឹងគឺគ្រប់គ្រងដោយខ្មែរក្រហមហើយ។ នៅលន់នល់ គ្រប់គ្រងដូចជានៅតែទីរួមខេត្ត ឬក៏តំបន់ដែលទីប្រជុំជន ទីក្រុងធំៗទេ។ អ៊ីចឹងវាហួសពេល ដូច្នេះហើយយើងអត់ត្រឡប់ទៅរក លន់ នល់ បានទេ រស់នៅក្រោមការចាប់ធ្វើទុក្ខបុកម្នេញ អស់ពីចាប់ទៅគេកៀបសង្កត់ផ្នែកសាសនាសព្វបែបសព្វយ៉ាង។ គេសម្លាប់ គេរកលេសដើម្បីសម្លាប់ អ៊ីចឹងហើយបានថា កើតចលនាបះបោរនេះ។ ចលនាបះបោរពីរភូមិនេះសំខាន់ ពីព្រោះពេលដែលបះបោររួច ប្រហែលជាមួយខែក្រោយហ្នឹង គឺគេបញ្ជូនចាមចេញពីភូមិរបស់ខ្លួន លុបបំបាត់សហគមន៍ចាមកាន់តែខ្លាំង។ អ៊ីចឹងហើយការជម្លៀសចាមនេះ មិនមែនដូចជម្លៀសបងប្អូនខ្មែរទេ បងប្អូនខ្មែរដែលរស់នៅទីក្រុងគេជម្លៀស គេជម្លៀសអ្នកដែលរស់នៅក្រោមការគ្រប់គ្រងរបស់ លន់ នល់ គេវ៉ៃ បានគេជម្លៀស ប៉ុន្តែចាមនេះគាំទ្រខ្មែរក្រហមតាំងពី៧០, ៧១ នៅពេលដែលកើតបះបោរហើយ គេជម្លៀសៗដើម្បីបំបាត់ពូជសាសន៍ចាម។

[១១:២៥:១៥]

ហើយដូចខ្ញុំសូមជម្រាបបញ្ជាក់ថាការធ្វើទុក្ខបុកម្នេញទៅលើជាតិសាសន៍ចាមនេះ វាខុស វាមាន

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទ្រង់ទ្រាយខុសពីជនជាតិខ្មែរ។ ខ្ញុំសូមបញ្ជាក់ថាខ្មែរក្រហមគាត់និយាយភាសាខ្មែរ គាត់ហូបសាច់ជ្រូក គាត់រស់នៅរបៀបជាខ្មែរ អ៊ីចឹងហើយគាត់ -- ប៉ុន្តែចាមគេបង្ខំបំបាត់ភាសាចាម – បំបាត់ភាសាចាមឲ្យរស់ -- ឲ្យឈប់រស់នៅជាសហគមន៍ ឲ្យដូរឈ្មោះទៅជាខ្មែរ ឲ្យស្លៀកពាក់របៀបជាខ្មែរ ប៉ុន្តែខ្មែរក្រហមមិនអាចធ្វើទង្វើនេះលុបបំបាត់ជាតិសាសន៍ លុបបំបាត់ភាសារបស់បងប្អូនខ្មែរដែលនិយាយបានទេ ពីព្រោះខ្លួនឯងនិយាយភាសាខ្មែរដែរ ហើយមិនអាចបង្ខំខ្មែរឲ្យហូបសាច់ជ្រូកទេ ពីព្រោះខ្មែរគាត់ហូបសាច់ជ្រូកស្រាប់ទៅហើយ។ អ៊ីចឹងអាការបង្ខំនេះគាត់ធ្វើតែទៅលើចាមទេ អ៊ីចឹងហើយបានថានយោបាយដែលធ្វើឲ្យដូចគ្នានេះគឺប៉ះពាល់ៗធ្ងន់ធ្ងរណាស់ទៅលើអ្នកដែលប្រព្រឹត្ត អ្នកដែលប្រកាន់យកសាសនាបែបបទមួយដែលខុសពីជនជាតិដទៃ ជនជាតិភាគច្រើននេះ។

**ស៖** សូមអរគុណ។ ខ្ញុំចូលទៅនិយាយអំពីរបបកម្ពុជាប្រជាធិតេយ្យ និងគោលនយោបាយដែលប៉ះពាល់ដល់ជនជាតិចាម។ ប៉ុន្តែឥឡូវនេះយើងផ្តោតទៅលើអំឡុងពេលនៃសង្គ្រាមស៊ីវិលសិន។ តើលោកបានដឹងថាជនជាតិចាមជាច្រើនចូលរួមជាមួយរណសិរ្សរបស់សម្តេច សីហនុ ដែរទេ? ហើយថាតើជនជាតិចាមចូលរួមប្រយុទ្ធតែជាមួយភាគីម្ខាង ឬក៏ចូលទាំងសងខាង? ឧទាហរណ៍ដូចថាជនជាតិចាមនេះចូលរួមតែជាមួយនឹងរណសិរ្ស ឬក៏ចូលរួមជាមួយនឹងកម្លាំងលន់ នល់ ដែរ?

**ឆ៖** បាទ មានសងខាង ព្រោះនយោបាយប្រទេសខ្មែរនៅពេលដែលមានការបែងចែកបក្សពួកជំនាន់ណាក៏ដោយត្រូវការកម្លាំងចាមគ្រប់ជំនាន់ទាំងអស់ តាំងពីនៅ -- ខ្ញុំមិនបាច់លើកវែងឆ្ងាយទេ ប៉ុន្តែនៅសម័យហ្នឹងគឺលន់ នល់ គាត់ជិតស្និទ្ធជាមួយប្រជាជនចាមដែរ ប្រជាជនចាមដែលរស់នៅក្បែរទីក្រុងភ្នំពេញជាពិសេសគឺមានមន្ត្រីរាជការបម្រើសម័យ លន់ នល់ មានតួនាទីខ្ពស់ៗតាំងពីកងកម្លាំងប្រដាប់អាវុធ ជាមេទាហានធំ កងពលតូចលេខ៥ហ្នឹង គឺមេកងពលហ្នឹងគឺជាចាមឈ្មោះ ឡេស កសឹម។ មានចាមនៅក្នុងរដ្ឋសភា ព្រឹទ្ធសភាកាន់ការងារនេះ ការងារនោះជាប៉េអឹម ហើយនៅខាងខ្មែរក្រហមដូចគ្នាគេត្រូវការចាមដែរ ចាមក៏ចូលរួមដែរ ចាមដែលរស់នៅជនបទដូចខ្ញុំបានលើកឡើងខាងដើម គឺស្រឡាញ់គាំទ្ររណសិរ្សរបស់សម្តេចឪហ្នឹង ក៏ចូលរួមគាំទ្រមានជាក់ស្តែងគឺមានតា សុះ ម៉ាន ឪពុក តាម៉ាត់ លីគាត់ជាមេដឹកនាំខាងចលនារបស់ខ្មែរក្រហមហ្នឹង អ៊ីចឹងយើងមានភាគី ពីរភាគីបាទ មានៗពីរបាទ ចាមចូលពីរកន្លែង។

[១១:២៩:០២]

**ស៖** សូមអរគុណ។ លេខយោងជើងទំព័រមួយរបស់លោកនៅក្នុងសៀវភៅរបស់លោក សូម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

លោកចំណាយពេលទៅលេខយោងជើងទំព័រនេះបន្តិច_គឺទាក់ទងអំឡុងពេលនៃសង្គ្រាមស៊ីវិល។ គឺលេខយោងទំព័រ១៧៥ គឺយើងអាចរកបានគ្រប់ភាសាដែលនិយាយថា "ខ្មែរ-ស" គឺជាក្រុមតស៊ូដែលត្រូវបង្កើតឡើងនៅឆ្នាំ១៩៧០ វាបានបាត់ទៅវិញនៅក្នុងឆ្នាំ១៩៧៥។ គោលបំណងរបស់ខ្មែរស គឺប្រឆាំងជាមួយនឹងលន់ នល់ ដោយចូលរួមជាមួយនឹងខាង សីហនុ នៅពេលដែលពួកគេចូលបង្កើតឡើងគឺចូលរួមជាមួយនឹងចលនាខ្មែរក្រហម។ សូមលោកពន្យល់ចលនាខ្មែរសហ្នឹងឲ្យបានលម្អិតជូនតុលាការបន្តិចមើល?

**ឆ៖** ខ្ញុំសូមសារភាពថា ខ្ញុំមិនសូវជាបានចាប់អារម្មណ៍ស្រាវជ្រាវឲ្យបានស៊ីជម្រៅ ពីរឿងបញ្ហាខ្មែរ-សនេះប៉ុន្មានទេ ពីព្រោះខ្មែរស វាអត់សូវមានអីពាក់ព័ន្ធទៅលើជនជាតិចាមប៉ុន្មានទេ។ អ៊ីចឹង ខ្ញុំអត់មានអីត្រូវពន្យល់ អត់មានចំណេះដឹងខាងហ្នឹងជ្រៅជ្រះទេ ខាងខ្មែរ-ស ហ្នឹង។

**ស៖** សូមអរគុណៗណាស់នៅពេលដែលលោកមិនមានព័ត៌មានពាក់ព័ន្ធសំណួររបស់ខ្ញុំ គ្រាន់តែ<ពន្យល់>ជូនតុលាការជាការស្រេច។ ឥឡូវនិយាយអំពីជ័យជម្នះរបស់ខ្មែរក្រហម ឆ្នាំ១៩៧៥ វិញម្តង។_តើជ័យជម្នះវាប៉ះពាល់ទៅដល់ជីវភាពរស់នៅ ជីវិតរបស់ជនជាតិចាមយ៉ាងដូចម្តេច? តើលោកអាចពន្យល់ថាតើវាប៉ះពាល់ទៅដល់របៀបរបបរស់នៅ វាពាក់ព័ន្ធទៅដល់សាសនា វាប៉ះពាល់ទៅដល់<ការស្លៀកពាក់ ដល់>ជីវភាពយ៉ាងដូចម្តេចដែរ ក្រោយជ័យជម្នះ១៩៧៥?

**ឆ៖** ការប៉ះពាល់នេះ មិនមែនចាប់ពី១៧ មេសា ៧៥ ទេ ប៉ះពាល់តាំងពី៧៣ ដូចខ្ញុំបានលើកឡើង។ ការបិទ បង្ខំឲ្យឈប់ប្រតិបត្តិសាសនាហ្នឹង កើតតាំងពី៧៣។ អ៊ីចឹង៧៥ ១៧ មេសា ៧៥ នេះ គឺប៉ះពាល់ចាម ដែលរស់នៅក្បែរទីក្រុងនៅទីរួមខេត្ត ដូចបងប្អូនខ្មែរទូទៅដែរ គឺប៉ះពាល់ត្រង់ថា គេជម្លៀសចេញពីភូមិកំណើត ដូចជាចាមនៅច្រាំងចម្រេះ ជ្រោយចង្វាជាដើម។ ចំពោះចាមនៅៗតាមជនបទ អត់មានអីប៉ះពាល់ អត់មានអីខុសប្លែកទេ។ ឃើញខុសប្លែក គឺត្រង់នៅពេលដែលក្រោយការបះបោរ គឺចាប់ពីខែតុលា ឆ្នាំ៧៥ ទៅវិញទេដែលមានចលនាបះបោរ បានគេជម្លៀសចាម បានគេកៀបសង្កត់ចាមកាន់តែធ្ងន់។

[១១:៣២:២៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗលោកអ្នកជំនាញ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

Deleted: អ៊ីចឹងទៅ

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងឧបករប្រែ និងឧបករប្រែបន្ត។*

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់អ្នកជំនាញរូបនេះនៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមន្ត្រីច្បាប់នៃការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយកន្លះរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១១:៣៣នាទី ដល់ម៉ោង ១៣:៣២នាទី)*

[១៣:៣២:២៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយតទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ជម្រាបសួរលោកអ្នកជំនាញ មុនពេលយើងឈប់សម្រាក យើងបាននិយាយគ្នាអំពីគោលនយោបាយខ្មែរក្រហមទៅលើជនជាតិចាមនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ គឺថាយើងពាក់ព័ន្ធទៅនឹងចំណុចនេះ លោកនិយាយអំពីការ<ហាមប្រាមមិនឲ្យ>បួងសួង <មិនឲ្យមាន>វិហារ ក៏ដូចជាគម្ពីគួរ៉ាន់ <តាំងពីដើម>ឆ្នាំ១៩៧៣ ហើយបន្តមកដល់ក្នុងរបបនោះទៀត។ ចុះការស្លៀកពាក់របស់ជនជាតិចាមវិញ តើមានគោលនយោបាយពាក់ព័ន្ធទៅនឹងការស្លៀកសម្លៀកបំពាក់បែបជនជាតិចាមនេះដែរទេ?

[១៣:៣៣:៥៣]

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ សូមជម្រាបលោកព្រះរាជអាជ្ញាថា ចាមគឺមានឯកសណ្ឋានរបៀបរបបនៃការស្លៀក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងឧបករណ៍ និងឧបករណ៍ប្រែបន្ត។*

Deleted: ♀

Deleted: <>

Deleted: នៅក្នុង

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ពាក់ផ្សេង ខុសប្លែកពីជនជាតិដទៃ ដូចជា បុរស គាត់មានសារុងរបស់គាត់ គាត់មានអាវវែងរបស់គាត់ គាត់មានកាតិបរបស់គាត់ ហើយចំពោះស្ត្រីវិញ ភាគច្រើនស្ត្រីចាម គាត់អត់ស្លូវស្លៀកខោទេ តែងតែភាគច្រើន គឺសារុង អាវវែង ហើយនិងទំនៀមទម្លាប់នៃការទទូរក្បាលមិនឱ្យចេញសក់ក្បាល។

**ស៖** ហើយចុះ<កាតិប>ដែលពាក់នៅលើក្បាលរបស់<បុរស>ហ្នឹង ក្បាល គឺតើវាមានពណ៌តែមួយ ឬយ៉ាងណាចំពោះកាតិបដែលប្រុសៗពាក់នុ៎ង?

**ឆ៖** អាចពណ៌ខុសៗគ្នា។ ចំពោះកាតិប ភាគច្រើនគឺស ហើយបើក្រៅពីស មានខ្មៅ សម្រាប់បុរស។ តែសម្រាប់ស្ត្រីតាមពណ៌ផ្សេងៗដែលបុគ្គលម្នាក់ៗចូលចិត្ត។

**ស៖** នៅក្នុងរបបនោះតើមានជនជាតិចាមណាម្នាក់ផ្លាស់ប្តូរឈ្មោះដែលគេធ្លាប់ប្រើទេ? ហើយបើមាន ថាតើមកពីមូលហេតុអ្វីដែរ?

**ឆ៖** បាទ ប្រាកដជាមាន ពីព្រោះឈ្មោះចាម គឺមានលក្ខណៈជាចាម។ អ៊ីចឹងហើយបានខ្មែរក្រហមបង្ខំឱ្យផ្លាស់ប្តូរឈ្មោះឱ្យទៅជាឈ្មោះខ្មែរ។ ហើយត្រង់ឈ្មោះនេះមិនមែនតែបង្ខំឱ្យដូរទៅលើចាមទេ សូម្បីតែជនជាតិខ្មែរខ្លួនឯងហ្នឹងក៏ត្រូវតែដូរដែរ។ ឈ្មោះរបៀបជាបញ្ញវន្ត ជាអ្នកចេះដឹង មានន័យ ឈ្មោះហ្នឹងត្រូវតែដូរឱ្យឈ្មោះខ្លី ឈ្មោះសាមញ្ញ ដែលងាយហៅ ហើយគេច្រើនតែដាក់ មិត្តនេះ មិត្តនោះអ៊ីចឹង។ អ៊ីចឹងចាមក៏ដូរ ខ្មែរក៏ដូរដែរឈ្មោះហ្នឹង។ ប៉ុន្តែការដូរឈ្មោះជនជាតិចាម វាបាត់បង់អត្តសញ្ញាណមួយរបស់ចាមទៅហើយ។

**ស៖** យើងដឹងថា យើងទាំងអស់គ្នាដឹងហើយអំពីការហាមឃាត់<ស្ដីពីអាហារ>មកលើជនជាតិចាម។ តើមានការកែប្រែណាមួយត្រូវបានអនុវត្តទៅលើជនជាតិចាមដែរទេ ពាក់ព័ន្ធទៅនឹងចំណីអាហារវិញ តើមានការតម្រូវឱ្យជនជាតិចាមហ្នឹងហូបយ៉ាងណាៗដែរទេ?

[១៣:៣៧:២១]

**ឆ៖** ចាម គឺតាមក្រឹត្យក្រមនៃសាសនាត្រូវមានកំណត់នៃការ -- នៃចំណីអាហារដែលត្រូវហូប។ ដូចជាសាច់ជ្រូកជាដើម គឺចាមមិនអាចហូប សូម្បីតែប៉ះៗពាក់ក៏មិនអាចប៉ះបានដែរ។ សត្វឆ្កែ និងសត្វមួយចំនួនផ្សេងទៀតយើងមិនអាចហូបបានទេ ឧទាហរណ៍ដូចជាកង្កែប ជាពស់ យើងអត់ហូប។ យើងហូបអ្វីដែលកំណត់ឱ្យហូប ប៉ុន្តែប៉ះពាល់ខ្លាំងជាងគេ គឺសាច់ជ្រូក ដែលយើងមិនអាច សូម្បីតែប៉ះក៏ប៉ះមិនបានដែរ។ អ៊ីចឹងហើយនៅពេលហ្នឹងគឺខ្មែរក្រហមបង្ខំឱ្យជនជាតិចាមហ្នឹងហូប ពិសេសគឺហូបសាច់ជ្រូកហ្នឹងតែម្តង។ នៅពេលបងប្អូនខ្មែរត្រូវការហូបចុក សាច់ជ្រូក គឺជាចំណីមួយដែលខ្មែរត្រូវការ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**Deleted:** <>

**Deleted:** ក្រមា

**Deleted:** <>

**Deleted:** ស្ត្រី

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ចាំបាច់ ប៉ុន្តែគាត់មិនបង្ខំឲ្យខ្មែរហូបទេ គាត់ដឹងថាចាមមិនចេះហូបសាច់ជ្រូក អ៊ីចឹងត្រូវបង្ខំចាមហ្នឹងឲ្យហូបសាច់ជ្រូក។ ហើយពេលខ្លះ វាអត់មានជ្រូកច្រើនទេ ប៉ុន្តែគេធ្វើសម្ល គេដាក់សាច់ជ្រូកតែមួយដុំ ពីរដុំ ដើម្បីឲ្យមានជ្រូកនៅក្នុងសម្លហ្នឹង។ អ៊ីចឹង ចាមមិនអាចប៉ះពាល់បានទេតាមច្បាស់សាសនាអ៊ិស្លាម។ តែផ្ទុយទៅវិញ គឺខ្មែរក្រហមបង្ខំធ្វើម៉េចឲ្យតែហូប។ ហើយមានករណីខ្លះគឺត្រូវយកសម្លាប់ចោល បើសិនជាបដិសេធនូវការហូបសាច់ជ្រូកហ្នឹង។

**ស៖** សូមអរគុណ។ មានឯកសារមួយនៅក្នុងសំណុំរឿង គឺឯកសារ E3/178 ខ្ញុំសូមសួរលោកអំពីឃ្លាមួយនៅក្នុងឯកសារនោះ គឺឯកសារបានមកពីរបបនោះតែម្តង។ ERN ជាភាសាខ្មែរ 00275588, បារាំង 00623305, អង់គ្លេស 00342709។ នៅក្នុងឯកសារនេះ គឺបានសរសេរថា "សមាសភាព១៧មេសា ពីភ្នំពេញ ដែលជាជនជាតិចាម បានធ្វើការជំទាស់តវ៉ានៅក្នុងសហករណ៍ពាក់ព័ន្ធទៅនឹងជំនឿរបស់ខ្លួន នូវអ្វីដែលខ្លួនត្រូវហូប ដោយយោងទៅតាមសាសនារបស់ខ្លួន ដោយការចង្អុលទៅលើមាត្រា១០នៃរដ្ឋធម្មនុញ្ញ"។ ហើយរបាយការណ៍បន្តទៅទៀតថា "សម្រាប់ស្ថានភាពនេះ យើងបានចាត់វិធានការពិសេស គឺ<វកខ្មែរ និងវកមើលមេដឹកនាំចលនានេះ>ដើម្បីបោសសម្អាតឲ្យបានស្រួល។

ខ្ញុំថា ខ្ញុំយល់ឃើញថាឯកសារនេះ ក៏បានលើកយកមកនិយាយនៅក្នុងសៀវភៅរបស់លោក<> តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ខ្ញុំនៅចាំបានថា ខ្ញុំបានប្រើប្រាស់ឯកសារនេះ នៅក្នុងសៀវភៅរបស់ខ្ញុំ។

[១៣:៤០:៥៣]

**ស៖** តាមការដឹងរបស់លោក តើមានអ្វីកើតឡើងទៅលើជនជាតិចាមទាំងអស់នោះ ដែលតាមគឺថាអនុវត្តតាមការហាមឃាត់របស់សាសនារបស់ខ្លួន អ្នកដែលបដិសេធចំពោះគោលនយោបាយរបស់ខ្មែរក្រហម តើមានអ្វីកើតឡើងទៅលើពួកគាត់?

**ឆ៖** តាមការស្រាវជ្រាវរបស់ខ្ញុំ ខ្ញុំមិនបានស្រាវជ្រាវឲ្យស៊ីជម្រៅ តើឯកសារហ្នឹងត្រូវគេយកទៅប្រើប្រាស់យ៉ាងម៉េច ត្រូវចាត់ការយ៉ាងម៉េចជាមួយប្រជាជនដែលជំទាស់នោះទេ ប៉ុន្តែតាមរយៈនៃការស្រាវជ្រាវសម្ភាសជាមួយសាក្សី សាក្សីស្ទើរតែគ្រប់ៗរូបទាំងអស់ នៅពេលដែលនិយាយពីចំណីអាហារ គឺគេបាននិយាយថា នៅសម័យនុ៎ង គេបង្ខំឲ្យគាត់ហូបសាច់ជ្រូក បង្ខំឲ្យគាត់ចិញ្ចឹមជ្រូក។ ហើយបើសិនជាគាត់បដិសេធ ត្រូវបានសម្លាប់។ ហើយមានករណីកើតឡើងជាក់ស្តែងមែន គឺអ្នកដែលបដិសេធនឹងបញ្ហានេះ ត្រូវៗសម្លាប់ចោល។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** <>

**Deleted:** មើលអំពីកម្លាំងរបស់គេមើលចំនួនស្ត្រី

**Deleted:** ផងដែរ។

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

01393009



**ស៖** សូមអរគុណ។ ខ្ញុំសូមអានឲ្យលោកស្ដាប់ចេញពីសៀវភៅ ប៉ែន យៀវនិន គឺ<E3/1593> ទំព័រ<៤៦១>ជាភាសាអង់គ្លេស, ERN ជាភាសាបារាំង 00639251 នៅត្រង់ទំព័រ <៥៤០>ជាភាសាបារាំង។ ឯកសារនេះ និយាយអំពីលទ្ធផលនៃកិច្ចសម្ភាសន៍ ដែលលោកបានសម្ភាសឡើង "នៅពេលដែលសួរជនជាតិចាមដែលត្រូវបានបង្ខំឲ្យហូបសាច់ជ្រូកនោះ អ្នកសម្ភាសចំនួន៩១នាក់ និយាយថា "បាទ" តែប្រាំមួយនាក់ទេដែលនិយាយថា"ទេ"។ ហើយវាការប្រើប្រាស់ភាសាចាម ក៏ត្រូវបានហាមឃាត់នៅក្នុងរបបខ្មែរក្រហម ៣៦និយាយថា "បាទ", ឯតែមួយទេនិយាយថា "អត់ទេ"។ នៅពេលសួរថាតើជនជាតិចាមត្រូវបានគេបំបែកចេញពីគ្នា ផ្លាស់ប្ដូរទីកន្លែងឬក៏យ៉ាងណា? អ្នកត្រូវបានសម្ភាស៥១នាក់ និយាយ"បាទ" ហើយមិនមានអ្នកណានិយាយថា"ទេ" ទេ។ ដូច្នេះ លទ្ធផលនៃកិច្ចសម្ភាសន៍ ប៉ែន យៀវនិន ទាក់ទងទៅនឹងអ្វីដែលលោក អ្នកដែលលោកបានសម្ភាសដែលទាក់ទងទៅនឹងការប្រើប្រាស់ភាសាចាម ដែលត្រូវបានគេហាមឃាត់ ហើយតម្រូវឲ្យហូបសាច់ជ្រូក ហើយជនជាតិចាមក៏ត្រូវផ្លាស់ប្ដូរទីកន្លែងរស់នៅ។

ឥឡូវខ្ញុំរៀបសំណួរឲ្យបានស្រួលជាងនេះបន្តិច។ លទ្ធផលនៃការសម្ភាសរបស់ ប៉ែន យៀវនិន ហ្នឹង គឺពាក់ព័ន្ធទៅនឹងលទ្ធផលរបស់លោកផងដែរ ដែលនិយាយថា៩១នាក់ និយាយថាគេឲ្យហូបសាច់ជ្រូក តែប្រាំមួយនាក់និយាយថាអត់ទេ។ ហើយ៣៥<នាក់ថា>គេតម្រូវឲ្យ<ហូបសាច់ជ្រូក ហើយប្រាំមួយនាក់ថា អត់ទេ>។ តើលោកយល់យ៉ាងម៉េចដែរ?

**ឆ៖** ខ្ញុំមិនប្រឆាំងនឹងអ្វីដែលការរកឃើញរបស់ ប៉ែន យៀវនិន ទេ ប៉ុន្តែយើងត្រូវតែដឹង ថាតើអ្នកប្រាំមួយនាក់ដែលនិយាយថា គេមិនបង្ខំគាត់ឲ្យហូបសាច់ជ្រូកហ្នឹង វាអាចមានមែនករណីហ្នឹងសម្រាប់គាត់ផ្ទាល់។ ប៉ុន្តែបើយើងនិយាយជារួម និយាយភាគច្រើន គឺត្រូវបានបង្ខំឲ្យហូបសាច់ជ្រូក បង្ខំឲ្យឈប់និយាយភាសាចាម។

[១៣:៤៤:៥០]

វាអាចកើតឡើងមែនចំពោះជនជាតិចាមណាដែលនៅកន្លែងឆ្ងាយ ហើយកន្លែងហ្នឹងដែលមានមេភូមិ ឬក៏មេឃុំ ប្រធានសហករណ៍នោះចិត្តល្អ ពីព្រោះតាមការស្រាវជ្រាវរបស់ខ្ញុំ ការកៀបសង្កត់ទៅលើជនជាតិចាមនេះ វាអាស្រ័យទៅលើប្រធាននៅទីតាំងហ្នឹងតែម្ដង បើប្រធានហ្នឹងមានមនោសញ្ចេតនាអាណិតស្រឡាញ់ ជនជាតិចាមដែរ នៅពេលហ្នឹងក៏វាអាចបន្ធូរបន្ថយក្នុងករណីណាមួយដែលបញ្ចោញពីលើទៅគាត់មិនយកទៅអនុវត្ត។ ប៉ុន្តែបើភាគច្រើន ចង់និយាយថាភាគច្រើនគាត់ត្រូវបានគេកៀបសង្កត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

Deleted:
Deleted:
Deleted: <>
Deleted: E31593
Deleted: <>
Deleted: ៩១
Deleted: <>
Deleted: និងទំព័រ៤០
Deleted:
Deleted: <>
Deleted: តម្រូវថា ត្រូវ
Deleted: ធ្វើដូច្នេះ
Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)
Formatted: Font: 6 pt, Complex Script Font: 6 pt

ឲ្យហូបសាច់ជ្រូក ឲ្យឈប់និយាយភាសាចាម ហើយត្រូវផ្លាស់ប្តូរទីតាំងចេញពីភូមិកំណើតរបស់គាត់។

**ស៖** នៅពេលនោះ យោងទៅលើការស្រាវជ្រាវរបស់លោក តើមានជនជាតិចាមណាដែលមិនចេះនិយាយភាសាខ្មែរដែរទេ?

**ឆ៖** មាន ពិសេសគឺចាស់ៗទុំបាទ ដែលគាត់ ដែលមិនសូវជាបានរាប់អានជាមួយបងប្អូនខ្មែរ ហើយគាត់មិនសូវដើរហើរទៅណាឆ្ងាយពីភូមិ គាត់នៅតែក្នុងភូមិរបស់គាត់នៅក្នុងតែក្រុមសហគមន៍របស់គាត់ហ្នឹង ដូច្នេះគាត់មានមួយចំនួនដែលគាត់អាចថាមិនមែនអត់ចេះនិយាយសោះ គាត់ចេះនិយាយប៉ុន្តែវាមានកម្រិតទាប គាត់អាចយល់បានតិច បើសិនជាអ្នកដែលធ្វើដំណើរបានច្រើន អ្នកដែលចុះប្រឡូកនៅក្នុងសង្គមខ្មែរឲ្យបានច្រើន អាហ្នឹងគាត់និយាយ ពិសេសគឺក្មេងៗគាត់និយាយធម្មតា។

**ស៖** មុនរបបកម្ពុជាប្រជាធិបតេយ្យ តើភាសាសំណេររបស់ចាមហ្នឹងដែលបានបង្រៀនទៅដល់ក្មេងៗនោះ តើនៅតែបន្តបង្រៀនទៅដល់ក្មេងៗទៀតដែរទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** អត់ទេ ពីព្រោះលែងមានគ្រូ លែងមានសាលារៀន លែងមានសិស្ស សម្រាប់ភាសាសម្រាប់សាសនាហ្នឹងហើយ។

[១៣:៤៧:៤១]

**ស៖** ប្រហែលជាដោយសារសំណួរខ្ញុំពិបាកបន្តិច មុនពេល មុនរបបកម្ពុជាប្រជាធិបតេយ្យអ្នកណាជាអ្នកបង្រៀនភាសាសរសេរនេះ?

**ឆ៖** បាទ អរគុណដែលបានសួរម្តងទៀត។ មុនរបបកម្ពុជាប្រជាធិបតេយ្យ គឺអត់មានបញ្ហាអីទេ សម្រាប់ជនជាតិចាមដែលរៀនភាសា រៀនសាសនា ដែលរៀនប្រវត្តិសាស្ត្ររបស់ខ្លួន ពីព្រោះមុនរបបកម្ពុជាប្រជាធិបតេយ្យនេះអត់មានការកៀបសង្កត់ ពិសេសនៅក្នុងតំបន់ដាច់ស្រយាល។ បើមុនរបបកម្ពុជាប្រជាធិបតេយ្យនេះ បានន័យថា មុនឆ្នាំ៧០ម្ល៉េះនៅក្នុងសង្គមរាស្ត្រនិយម គឺអត់មានការកៀបសង្កត់ណាមួយទៅលើជនជាតិចាមទេ។ ដូច្នេះ ជនជាតិមានសិទ្ធិសេរីភាពពេញលេញនៅក្នុងការរៀនសូត្ររបស់ខ្លួន ចង់រៀនសាសនា ភាសា ប្រវត្តិសាស្ត្ររបស់ខ្លួនអាចរៀនបានដោយសេរី។

**ស៖** យើងដឹងទាំងអស់ហើយថារបបនោះមានអាយុកាលតិចជាងបួនឆ្នាំ។ តាមការស្រាវជ្រាវរបស់លោក តើវាមានការប៉ះពាល់<ពីរបបកម្ពុជាប្រជាធិបតេយ្យ>អ្វីទៅដល់ភាសាចាមដែរទេ ហើយវាមានការ -- វាធ្វើឲ្យប៉ះពាល់ទៅដល់សមត្ថភាពរបស់ក្មេងៗដែលរៀនភាសា ដែលត្រូវរៀនសរសេររៀនអាននោះដែរទេ<>?

Deleted: នៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01393011

E1/388.1/Corr-1



[១៣:៤៩:១៤]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹង គឺថា នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនេះគឺសិទ្ធិសេរីភាពខាងជំនឿសាសនា ខាងជនជាតិរបស់ខ្លួននេះគឺបាត់ទាំងស្រុង ហើយការបង្ខំឲ្យនិយាយភាសាខ្មែរ ដូចឈ្មោះជាខ្មែរ បង្ខំឲ្យហូបសាច់ជ្រូក។ ដូច្នេះមានក្មេងៗមួយចំនួននៅឆ្នាំ១៩៧៩ ហ្នឹង គាត់ -- ដែលកើតនៅក្នុងរបបហ្នឹង គាត់អត់ចេះនិយាយភាសាចាមទៅវិញ។ ជាក់ស្ដែងប្អូនស្រីរបស់ខ្ញុំផ្ទាល់ គឺគាត់ពិបាកនឹងនិយាយភាសាចាមណាស់ ហើយសូម្បីតែខ្លួនខ្ញុំផ្ទាល់ហ្នឹងក៏មានការពិបាកដែរ បើភ្លេចភ្លាំងភាសារបស់ខ្លួនក្នុងរយៈពេលជាងបីឆ្នាំនេះ យើងភ្លេចភាសារបស់ខ្លួនសម្រាប់ក្មេងៗ ប៉ុន្តែសម្រាប់មនុស្សចាស់ គាត់មិនបញ្ហាអ្វីទេសម្រាប់គាត់។

**ស៖** ឥឡូវនេះ ខ្ញុំបន្តទៅប្រធានបទមួយថ្មីទៀតដែលយើងបានលើកមកនិយាយខ្លះៗ ហើយព្រឹកមិញនេះពាក់ព័ន្ធទៅនឹងសំណួររបស់លោកប្រធាន គឺការបះបោររបស់ជនជាតិចាមប្រឆាំងទៅនឹងគោលនយោបាយកម្ពុជាប្រជាធិបតេយ្យ។ ដំបូងលោកនិយាយលម្អិតនូវអ្វីដែលកើតមានឡើងនៅកោះផល និងស្វាយឃ្លាំង ហើយក៏ដូចជានៅទ្រាផងដែរ។ តើមានអ្វីកើតឡើងទៅដល់ជនជាតិចាមនៅភូមិទ្រា នៅឆ្នាំ១៩៧៣?

**ឆ៖** ផ្អែកតាមសាក្សីដែលបានដឹងរឿង ជាអ្នកដែលចូលរួមនៅក្នុងសកម្មភាពបះបោរប្រឆាំងនៅភូមិទ្រានេះនៅក្នុងឆ្នាំ១៩៧៣ ពេលហ្នឹង គឺខ្មែរក្រហមបានទៅចាប់អ្នកភូមិម្នាក់នៅក្នុងភូមិទ្រាហ្នឹង ហើយអ្នកភូមិហ្នឹងគាត់ដឹងខ្លួនទាន់ គាត់រត់គេចពីការចាប់ ហើយខ្មែរក្រហមបានដេញបាញ់ ប៉ុន្តែបាញ់មិនត្រូវគាត់ទេ ក្រោយមកកម្លាំងខ្មែរក្រហមដែលទៅចាប់ហ្នឹងគេដកមកវិញ។ អ៊ីចឹងជនជាតិចាមមួយក្រុមនាំគ្នាមកតវ៉ានៅមន្ទីរឃុំនៅខាងកើតភូមិទ្រាហ្នឹង មកតវ៉ាថាហេតុអីបានជាចាប់ពួកជនជាតិយើងគាត់មានកំហុសអី? សូមបញ្ឈប់នូវការចាប់ហ្នឹងទៀតទៅ ប៉ុន្តែខ្មែរក្រហមអត់មានឆ្លើយតបអីទេ កំហឹងនៃការតវ៉ាហ្នឹងវាធ្វើឲ្យអ្នកដែលទៅតវ៉ាហ្នឹងដុតមន្ទីរមួយនៅ -- មិនមែនជាមន្ទីរឃុំទេ ដូចជាមន្ទីរពាណិជ្ជកម្ម ដុតហើយក៏នាំគ្នាត្រឡប់មកផ្ទះវិញ។ ដល់ពេលត្រឡប់មកវិញ ខ្មែរក្រហមគេបញ្ជូនកងទ័ពរបស់គេមួយក្រុម នាំគ្នាទៅចាប់ៗអ្នកដែលចូលរួមដុតមន្ទីរឃុំ ចូលរួមនៅក្នុងការទៅតវ៉ាហ្នឹង។ អ៊ីចឹងមានអ្នកខ្លះក៏គេចាប់បាន អ្នកខ្លះក៏គេចាប់មិនបានរត់គៀសខ្លួនមានហែលទឹកមករហូតមកដល់កំពង់ចាមក៏មាន ដែលជាកន្លែងគ្រប់គ្រងដោយលន់ នល់។ នេះហើយថាជាការបះបោរលើកទី១នៅឆ្នាំ៧៣ នៅភូមិទ្រាហ្នឹង គឺកើតឡើងអ៊ីចឹង។

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៥២:៥៨]

**ស៖** សូមអរគុណ។ លោកនិយាយអំពីការបះបោរ ហើយសៀវភៅរបស់លោក<មានចំណាងជើង>"ការបះបោររបស់ជនជាតិចាម"។ ខ្ញុំសូមសួរលោកបន្ថែមថាតើគោលបំណងនៃការបះបោរនេះគឺអ្វីដែរ? តាមការសិក្សាស្រាវជ្រាវរបស់លោក តើគេមានផែនការអ្វីដើម្បីបះបោរ ហើយដើម្បីវាយក្តោបក្តាប់ដណ្តើមទីក្រុងភ្នំពេញទម្លាក់របបនោះចោលដែរទេ?

**ឆ៖** ការបះបោរនេះគឺគោលដៅសំខាន់គឺទាមទារសេរីភាពៗនៃការគោរពប្រតិបត្តិសាសនា ជំនឿសាសនារបស់ខ្លួន គោរពអ្វីដែលខ្លួនបានធ្វើ ធ្លាប់ធ្វើជាប្រពៃណីរបស់ខ្លួនពីមុនមក។ អ៊ីចឹងយើងទាមទារចង់បានសេរីភាព មិនមែនបះបោរក្នុងន័យផ្តួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនោះទេ។

**ស៖** ឥឡូវយើងផ្តោតទៅលើកោះផលនិងស្វាយឃ្លាំងក្នុងឆ្នាំ<១៩៧៥> ទោះបីជាការបះបោរមួយណាក៏ដោយក៏បានដែរ។ តើលោកអាចជម្រាបជូនតុលាការបានដែរទេ អ្នកដែលជំទាស់តវ៉ាជាមួយនឹងរដ្ឋាភិបាលហ្នឹង មានអាវុធទេ? មានកាំភ្លើងធំដែរទេ? តើពួកគាត់មានអាវុធប្រភេទណាដែរទេ?

**ឆ៖** សម្រាប់អ្នកបះបោរ សម្រាប់អ្នកភូមិ សម្រាប់ជនជាតិចាម គឺដែទទេ គឺអត់មានអាវុធអីការប្រើតតាំងជាមួយកម្លាំងខ្មែរក្រហមពេលដែលគេទៅបាញ់សម្លាប់អ្នកភូមិនេះ គេប្រើកាំបិត ប្រើដាវប្រើដុំថ្ម លើកលែងនៅភូមិស្វាយឃ្លាំង ដោយសារពេលហ្នឹងមានដណ្តើមអាវុធបានពីរដើមពីខាងខ្មែរក្រហម ហើយប្រើប្រាស់អាវុធហ្នឹងដើម្បីតបតជាមួយខ្មែរក្រហម។ បើក្រៅពីស្វាយឃ្លាំង ដូចនៅទ្រានៅកោះផល គឺអត់មានអាវុធទាល់តែសោះ។

**ស៖** លោកបាននិយាយនូវអ្វីដែលបានកើតឡើងនៅកោះផល គឺថាមានការបាញ់ផ្តោងដោយកងទ័ពកម្ពុជាប្រជាធិបតេយ្យ។ មុនពេលបាញ់ផ្តោងចូលទៅលើកោះនេះ តើអ្នកដែលជំទាស់តវ៉ាហ្នឹងមានបានសម្លាប់កម្មាភិបាលណាខ្លះដែរទេ នៅកោះផល?

**ឆ៖** សូមទោសបាទ ខ្ញុំអត់យល់ច្បាស់។

**ស៖** នៅកោះផល លោកបាននិយាយនិងពន្យល់អ្វីដែលកើតឡើង។ មានការប្រជុំមួយពីសំណាក់កម្មាភិបាល នៅពេលដែល គឺថា គឺនៅពេលដែលជនជាតិចាមហ្នឹងគាត់កំពុងថ្វាយបង្គំហ្នឹង<។ មានចាមម្នាក់ក្រោកឈរ ហើយក៏ប្រកូកប្រកាសដល់អ្នកបួងសួងដទៃទៀត។ មនុស្សក៏ចាប់ផ្តើមដើរចេញប្រសេចប្រសាច។ ពីរឬបីថ្ងៃក្រោយមកក៏>មានការបាញ់ផ្តោងចូលទៅទីនោះ ដោយកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ។ សំណួររបស់ខ្ញុំសួរថា នៅពេលមានការបះបោរហើយបាញ់ផ្តោងចូលនោះ តើ

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

Deleted: <>

Deleted: និយាយអំពី

Deleted: <>

Deleted: ១៩៧៣

Deleted:

Deleted:

Deleted: ហើយជនជាតិចាមក៏បានបះបោរ ហើយ

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ជនជាតិចាមនៅទីនោះ មានបានសម្លាប់កម្មាភិបាលខ្មែរក្រហមណាខ្លះដែរទេ?

**ឆ៖** នៅក្នុងការតតាំង បើខ្ញុំចាំមិនខុសទេ ដូចជាអត់មានបង្ហាញច្បាស់ ថាសាក្សីមួយណាបង្ហាញថាគាត់បានសម្លាប់ ឬក៏បានឃើញអ្នកភូមិសម្លាប់ខ្មែរក្រហមវិញទេ។ ប៉ុន្តែផ្ទុយទៅវិញ ឃើញតែអ្នកភូមិទេអ្នកដែលៗកាន់ដាវ អ្នកដែលបះបោរហ្នឹងទេ ដែលរងគ្រោះ ត្រូវបានខ្មែរក្រហមសម្លាប់។

[១៣:៥៧:១៧]

**សៈ** នៅក្នុងសៀវភៅរបស់លោក គឺឯកសារ <u><E3/2653></u> លោករៀបរាប់ដំណើររឿងមួយចំនួននៅស្វាយឃ្លាំង ហើយដំណើររឿងមួយគឺមានសាក្សីម្នាក់ឈ្មោះ ម៉ាន់ ហ្សេន ហើយនិងតាឡឹក គឺថាបានចាក់សម្លាប់កម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ចែត នៅ<u><មុន></u>ពេលដែលខ្មែរក្រហម<u><></u>បាញ់ផ្លោងចូលស្វាយឃ្លាំង។ អ៊ីចឹងហើយបានជាខ្ញុំសួរថា មុនពេលដែលកងទ័ពខ្មែរក្រហមបាញ់ផ្លោងចូលទៅស្វាយឃ្លាំងហ្នឹង តើជនជាតិចាមនោះបានសម្លាប់កម្មាភិបាលណាម្នាក់មុននោះហើយឬនៅ? ខ្ញុំអត់និយាយអ្នកដែលស្លាប់នៅក្នុងពេលបាញ់ផ្លោង ឬពេលប្រទះគ្នានោះទេទាំងភាគីទាំងសងខាង។ ខ្ញុំសួរនៅមុនហ្នឹង ថាតើជនជាតិចាមនៅទីនោះបានសម្លាប់កម្មាភិបាលណាម្នាក់ហើយឬនៅ?

**ឆ៖** បាទ បើលោកសួរអំពីរឿងរ៉ាវកើតឡើងនៅស្វាយឃ្លាំង គឺត្រឹមត្រូវ ពីព្រោះកាលណាសម្លាប់កម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ ចែត កើតឡើងនៅស្វាយឃ្លាំង មិនមែននៅកោះផលទេ។ នៅពេល ចែត នេះត្រូវបានសម្លាប់នៅពេលយប់ ពេលដែលកម្លាំងបះបោរហ្នឹងដេញៗ ចែតហ្នឹង ហើយដៃគូបក្ខពួករបស់ ចែត ហ្នឹងចេញពីភូមិ ពីព្រោះ ចែត ហ្នឹងគឺគេកំពុងតែដើរចាប់អ្នកភូមិហ្នឹង។ អ៊ីចឹងដេញមកដល់ព្រំប្រទល់ភូមិ អ្នកដែលបះបោរហ្នឹងបានដេញទាន់ ហើយក៏កាប់កម្មាភិបាលម្នាក់ឈ្មោះ ចែត ហ្នឹងស្លាប់នៅនឹងកន្លែង។ ហើយរហូតដល់ព្រឹកឡើងបានកម្លាំងខ្មែរក្រហមគេបញ្ជូនទៅបង្ក្រាបអ្នកភូមិ សភាពការណ៍នៅយប់នោះ ក្រោយពីស្លាប់ ចែត ភ្លាមៗគឺអត់ទាន់មានបញ្ហាអីកើតឡើងទេ។

[១៣:៥៩:៤០]

**សៈ** សូមអរគុណ។ ឥឡូវនេះ យើងនិយាយអំពីអ្នកដែលចូលរួមពាក់ព័ន្ធនៅក្នុងការបះបោរនេះ។ តើពួកគាត់មានទំនាក់ទំនងជាមួយកម្លាំងប្រដាប់អាវុធខាងក្រៅដែរទេ? ដូចជាកម្លាំងប្រដាប់អាវុធមក -- កម្លាំងប្រដាប់អាវុធប្រទេសក្រៅដែលត្រូវទំនាក់ទំនងអាចនឹងមានជំនួយឬក៏យ៉ាងណានោះ មានដែរទេ?

**ឆ៖** អត់មានទេ សម្រាប់អ្នកបះបោរ គឺកម្លាំងអ្នកភូមិរបស់ខ្លួន សាមីខ្លួនហ្នឹង សូម្បីតែបះបោរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: <>

Deleted: E32653

Deleted: <>

Deleted: វាយ

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

នៅកោះផល ពេលហ្នឹងអ្នកស្វាយឃ្លាំងក៏អត់ដឹង អ្នកនៅក្បែរកោះផលហ្នឹងក៏អត់ដឹង ឮតែកាំភ្លើង ពីព្រោះការធ្វើដំណើរចរាចរចុះឡើងហ្នឹងត្រូវបានបិទមុនពេលបះបោរបាទ។ អ៊ីចឹងការបះបោរនេះ អត់មានរៀបចំជាផែនការអីជាក់លាក់មានមេកើយមានការគាំទ្រពីក្រៅភូមិហ្នឹង គឺអត់មានទេ។ ដូចជានៅស្វាយឃ្លាំងជាដើម គឺបះបោរហ្នឹងកើតឡើងចេញពីក្រុមយុវជនមួយចំនួនដែលគាត់មិនអនុញ្ញាតឲ្យគេចាប់ពូមីងឪពុកម្ដាយរបស់គាត់។ អ៊ីចឹងហើយបានគាត់រៀបចំក្រុមរបស់គាត់ដើម្បីតតាំង ហើយមានអ្នកភូមិ ក្រោយមកអ្នកភូមិចូលរួមទាំងអស់គ្នា។ អ៊ីចឹងអត់មាន ជាសរុបមកគឺអត់មានជំនួយ ជាគំនិតជាគ្រឿងសម្ភារៈស្អីពីខាងក្រៅភូមិរបស់ខ្លួនទេ។

**ស៖** សូមអរគុណ។ នៅពេលលោកធ្វើការសម្ភាសនេះ តើលោកសម្ភាសនៅក្នុងឆ្នាំណាដែរ? អំពីការបះបោររបស់ជនជាតិចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង? ប៉ុន្តែការសម្ភាសរបស់លោកនេះ តើលោកចាប់ផ្ដើមសម្ភាសហ្នឹងនៅឆ្នាំណាដែរ?

[១៤:០១:៥២]

**ឆ៖** ខ្ញុំមិនអាចកំណត់ថាឆ្នាំណាមួយបានទេ ប៉ុន្តែចាំថា នៅក្រោយបោះពុម្ពសៀវភៅទី២ របស់ខ្ញុំ បានន័យថា -- ទី១ (សុំទោស) បានន័យថា ក្រោយឆ្នាំ២០០២ ខ្ញុំបានចាប់ផ្ដើមស្រាវជ្រាវសៀវភៅការបះបោររបស់ជនជាតិចាមនេះ ហើយគ្មាន -- ដូច្នេះទាល់តែមើលឯកសារឡើងវិញ បានខ្ញុំអាចប្រាប់ថា មាន -- ឆ្នាំណាមានប៉ុន្មាននាក់ៗ។

**ស៖** បាទ មិនជាអ្វីទេ លោកថាលោកចាប់ផ្ដើមនៅក្នុងឆ្នាំ២០០២ ហើយសៀវភៅនេះ បោះពុម្ពផ្សាយនៅឆ្នាំ២០០៦។ ដូច្នេះសំណួររបស់ខ្ញុំគឺ ក្នុងពេលលោកសម្ភាស លោកសន្ទនាជាមួយជនជាតិចាមទាំងនោះ តើជនជាតិចាមទាំងអស់នោះគាត់មានលក្ខណៈ គឺថានឹងនររឹងមាំក្នុងការឆ្លើយទៅនឹងសំណួររបស់លោក នូវអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះដែរទេ ឬក៏គាត់មានមោទនភាពក្នុងការឆ្លើយនូវសំណួររបស់លោក ឬក៏យ៉ាងណានោះទេ?

**ឆ៖** គាត់សប្បាយចិត្ត គាត់សហការជាមួយខ្ញុំ គាត់មានមោទនភាពដែលមានខ្ញុំម្នាក់ចងក្រងប្រវត្តិសាស្ត្រឈឺចាប់របស់ខ្លួនដើម្បីទុកឲ្យក្មេងជំនាន់ក្រោយទៀតបានដឹង។ ហើយការសម្ភាសភាគច្រើនជាភាសាចាមផង ពីព្រោះគាត់ងាយនឹងនិយាយទាក់ទងគ្នា ហើយខ្ញុំក៏ចូលចិត្តនិយាយភាសាចាមជាមួយគាត់ដែរ។

**ស៖** សូមអរគុណលោក។ សំណួររបស់ខ្ញុំខុសពីនេះបន្តិច ឥឡូវខ្ញុំរៀបសំណួរឡើងវិញ ដើម្បី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ឲ្យបានចម្លើយទៅច្បាស់។ នៅក្នុងសហគមន៍ចាម តើអ្នកដែលបះបោរប្រឆាំងនឹងខ្មែរក្រហមហ្នឹងជាវីរជន ជាវីរបុរស ឬក៏ថាអ្នកបះបោរហ្នឹងវាទៅជាអ្នកដែលនាំឲ្យមានភាពអាម៉ាស់ចូលមកដល់ក្នុងភូមិសហគមន៍របស់ខ្លួន? <តើលោកមានទស្សនៈបែបណា?>

[១៤:០៤:២៨]

**ឆ៖** សម្រាប់នៅអ្នកភូមិស្វាយឃ្លាំង អ្នកភូមិកោះផល អត់មានអ្នកណាស្ដីបន្ទោសចំពោះអ្នកដែលបះបោរនោះទេ ពីព្រោះការបះបោរនេះ គឺចូលរួមគ្រប់គ្នា សូម្បីតែស្ត្រីក៏ចូលរួមដែរ។ ចូលរួមជញ្ជូនស្បៀងអាហារ ចូលរួមដឹករណ្ដៅសម្រាប់កប់សាកសព ចូលរួមព្យាបាលជួយអ្នកដែលរងរបួស។ ហើយសម្រាប់ -- នេះសម្រាប់ភូមិស្វាយឃ្លាំង និងកោះផល។ ហើយបើនិយាយពីចាម ជនជាតិចាមនៅភូមិដទៃទៀត ស្រុកដទៃទៀត ក៏អត់មានអ្នកណាស្ដីបន្ទោសចាមនៅកោះផល ចាមនៅស្វាយឃ្លាំងថាមកពីការបះបោរហ្នឹងបានមានចាមហ្នឹងទទួលទណ្ឌកម្មកាន់ធ្ងន់ធ្ងរ គឺអត់មានទេ ពីព្រោះការចាប់ ការយកទៅសម្លាប់នេះ កើតឡើងមុនបះបោរ។ មានតែគេនិយាយថា បើសិនជាដឹងថាភូមិពីរហ្នឹងបះបោរដឹងគម្រោងការដូច្នេះ គេក៏ចង់បះបោរជាមួយគ្នាដែរពេលហ្នឹង ដើម្បីឲ្យបានកម្លាំងច្រើន។

**ស៖** សូមអរគុណលោក។ សំណួររបស់ខ្ញុំម្ដងនេះ មិនពាក់ព័ន្ធទៅនឹងសៀវភៅរបស់លោកទេ តាមដែលខ្ញុំយល់យ៉ាងហោចណាស់ក៏នៅក្នុងភាសាអារ៉ាប់ដែរ ដែលមានពាក្យសម្រាប់អ្នកដែលស្លាប់ គឺស្លាប់ដើម្បីសាសនា។ ត្រូវតែស្លាប់ដើម្បីសាសនា តើមានពាក្យ<>បែបនេះ នៅក្នុងសហគមន៍ចាមយើងនេះទេ?

**ឆ៖** យើងប្រើពាក្យមួយគេហៅថា “ហ្សាប៊ីលីឡ្លះ”។ ហ្សាប៊ីលីឡ្លះនេះ តាមន័យនៅក្នុងសាសនាអ៊ីស្លាមបើសិនជាមានការ<គាប>សង្កត់ រឹតត្បិតសាសនា ហើយអ្នកហ្នឹងសុខចិត្តស្លាប់ បានន័យថាបូជាជីវិតដើម្បីសាសនា គឺអ្នកហ្នឹង នឹងបានផលបុណ្យពីព្រះ ហើយបានឡើងឋានសួគ៌។

[១៤:០៦:៥៩]

**ស៖** លោកបាននិយាយថា ក្រោយការបះបោរនេះ ប្រជាជនដែលរស់នៅក្នុងភូមិទាំងនោះ ត្រូវបានគេផ្លាស់ទីលំនៅទៅកាន់កន្លែងផ្សេងៗទៀត តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកអាចពន្យល់ជូនតុលាការសង្ខេបបន្តិចបានទេ ពួកគាត់ហ្នឹងត្រូវបានគេបញ្ជូនទៅទីណា គេបញ្ជូនរួមគ្នា ឬក៏គេបញ្ជូនទៅហើយបំបែកចេញពីគ្នា<ទៅកាន់ទីកន្លែងថ្មីនេះ>?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** ស្តោក

**Deleted:** គៀប

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**ឆ៖** នៅក្រោយពីការបះបោរប្រហែលរយៈពេលមួយខែ គេហៅជនជាតិចាមនៅតាមភូមិផ្សេងៗទៀតដែលអត់មានការបះបោរហ្នឹង គេហៅប្រជុំ គ្រប់ភូមិទាំងអស់ អត់មានលើកលែងទេ។ ដល់គេប្រជុំ គឺផែនការប្រជុំហ្នឹង គឺទី១ គេគំរាមកំហែង បំភិតបំភ័យជនជាតិចាម ហើយបង្ខំត្រូវតែភ្លេចសាសនា ត្រូវធ្វើតាមបដិវត្តន៍ បញ្ជារបស់បដិវត្តន៍ ហើយផែនការទី២ ត្រូវតែជម្លៀសៗចេញពីភូមិកំណើតរបស់ខ្លួន។ អ៊ីចឹងចាមបះបោរ ដូចខ្ញុំបានរៀបឡើង -- បានវាយវ៉ាប់ខាងដើមនៅកោះផល គេជម្លៀសភ្លាមៗ នៅស្វាយឃ្លាំងគេយកទៅឃុំឃាំងរយៈពេលមួយខែ ហើយនៅពេលដែលអ្នកស្វាយឃ្លាំងហ្នឹងគេឃុំឃាំងមួយខែហើយគេជម្លៀស ជនជាតិចាមនៅភូមិដទៃៗទៀតហ្នឹង គឺជម្លៀសពេលប្រហាក់ប្រហែលហ្នឹង។ គឺប្រហែលជានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយការជម្លៀសនេះមិនជម្លៀសពីកន្លែងនេះជាសហគមន៍យកទៅដាក់នៅកន្លែងមួយទៀតឲ្យគាត់នៅផ្តុំគ្នាទេ គឺជម្លៀសបំបែក។ បានន័យថាក្នុងភូមិគាត់បញ្ជូនចេញទៅ គាត់ទៅដល់ទីតាំងថ្មីហ្នឹង គេឲ្យគាត់នៅពីរគ្រួសារ បីគ្រួសារនៅក្នុងភូមិនេះ។ ពីរគ្រួសារ បីគ្រួសារនៅក្នុងភូមិនោះ ហើយនៅពេលដល់កន្លែងភូមិថ្មីដែលគាត់ត្រូវនៅហ្នឹងអត់មានផ្ទះទេ មួយចំនួន គឺត្រូវនៅក្រោមផ្ទះបងប្អូនខ្មែរ ឬក៏ម្ចាស់ផ្ទះគាត់មានមនោសញ្ចេតនាស្រលាញ់រាប់អានគាត់រស់នៅជាមួយបងប្អូនខ្មែរ នៅតាមភូមិនីមួយៗ ក្នុងមួយមានពីរគ្រួសារ បីគ្រួសារតែប៉ុណ្ណឹង។ អ៊ីចឹងអស់មានសហគមន៍ចាម លែងមានចាមរស់នៅជាក្រុមដែលអាចថ្វាយបង្គំរួមគ្នាអីបានទៀតហើយ គឺបែកបាក់អស់ហើយ បងប្អូនក្រុមគ្រួសារ តាមទិសដៅដែលគេកំណត់រៀងៗខ្លួន។

**ស៖** ថាតើការរស់នៅជីវភាពរស់នៅហ្នឹង យើងមានលក្ខណៈដូចម្តេច ពាក់ព័ន្ធអ្នកដែលគេបញ្ជូនទៅ តើមានការប៉ះពាល់ទៅនឹងការរស់នៅរបស់គាត់យ៉ាងណាខ្លះ សូមបញ្ជាក់បន្តិច?

**ឆ៖** បាទ នៅពេលដែលគាត់ទៅនៅទីកន្លែងថ្មី គឺទី១ គាត់បាត់បង់សហគមន៍របស់គាត់ ហើយកន្លែងថ្មីនេះគេងាយនឹងមើល គេងាយនឹងតាមដាន ថាតើនៅក្នុងភូមិហ្នឹងមានចាមពីរបីគ្រួសារហ្នឹង តើនៅនិយាយភាសាចាមទៀតអត់។ ហើយគេត្រូវបង្ខំឲ្យហូបសាច់ជ្រូកត្រូវតែតាមគេ។ អ៊ីចឹងហើយនៅពេលដែលនៅរស់ ទៅរស់នៅក្នុងលែងមានសហគមន៍ជាមួយបងប្អូនខ្មែរ គេងាយតាមដានណាស់ ហើយឪពុកម្តាយនៅផ្សេងសម្រាប់កូនជាយុវជន ជាកុមារនៅផ្សេង គេបែងចែក លែងសូម្បីតែគ្រួសារពីរបីដែលនៅក្នុងភូមិហ្នឹង គឺបំបែកៗទៅតាមវ័យ តាមភេទឲ្យនៅផ្សេងៗគ្នា។ លែងជួបជុំជាគ្រួសារទៀតហើយ។

[១៤:១១:២៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**សៈ** បាទ សូមលោកជំនាញ<បញ្ជាក់>បន្តិច។ លោកបានបញ្ជាក់ពីមុននៅក្នុងសក្ខីកម្មកាលពីព្រឹកមិញនេះ ដែលថាជនជាតិចាមហ្នឹង គឺដំបូងគាត់ភាគច្រើន គាត់រស់នៅក្នុងខេត្តកំពង់ចាម នៅតាមបណ្ដោយដងទន្លេមេគង្គ ហើយលោកជំនាញក៏បានបញ្ជាក់ផងដែរថា ភាគច្រើនតំបន់នោះ គឺភាគច្រើនគ្រប់គ្រងទៅដោយ<វណសិរ្ស ឬ>បក្សកុម្មុយនីស្តកម្ពុជា ជាពិសេសនៅក្នុងគេថា<សង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ ដល់>ឆ្នាំ១៩៧៣ ហើយតំបន់នោះគឺជាទីតាំង មូលដ្ឋាន ហើយថាតើអ្នកដែលរស់នៅទីនេះ<ត្រូវគេជម្លៀសឱ្យទៅនៅកន្លែងផ្សេងទៀត ឬគេអនុញ្ញាតឱ្យប្រជាជនទាំងនោះនៅភូមិកំណើតរបស់ខ្លួនដដែល?>

**ផៈ** សម្រាប់អ្នកកោះផល គេបញ្ជូនទៅនៅភូមិបួននៅក្នុងឃុំឈូក មានភូមិក្របីក្រៀក ផ្កាដូងបារាយណ៍ និងច្រវាក់ដែក។ ទីកន្លែងដែលរងគ្រោះមួយសាទៀតដោយជំងឺគ្រុនចាញ់។ ប៉ុន្តែមួយរយៈពេលប្រហែលជាបីបួនខែក្រោយមក គេបញ្ជូនអ្នកដែលសេសសល់ពីស្លាប់ដោយសារគ្រុនចាញ់ហ្នឹងទៅខាងភូមិភាគខាងជើងវិញ ឆ្លងទន្លេទៅកាត់តាមស្រុកស្ទឹងត្រង់។ សម្រាប់អ្នកស្វាយឃ្លាំងវិញ នៅក្រោយពេលបះបោរ មួយចំនួន គេបញ្ជូនទៅស្រុកដំបែ ហើយមួយចំនួនទៀតគេបញ្ជូនឆ្លងទន្លេទៅភូមិភាគខាងជើងដូចគ្នានៅក្នុងទឹកដីស្រុកស្ទឹងត្រង់ ហើយមួយចំនួនមាននៅរហូតឆ្លងមកដល់ខាងកំពង់ធំក៏មានដែរ ហើយមួយចំនួនចូលទៅក្នុងស្រុកព្រែកប្រសព្វខេត្តក្រចេះ។ ដូចគ្នាចំពោះចាមដែលអត់បះបោរក៏ត្រូវគេបញ្ជូនមួយចំនួនគឺមកភូមិភាគខាងជើង ហើយមួយចំនួននៅក្នុងភូមិភាគបូព៌ាដដែល ប៉ុន្តែគ្រាន់តែដូរស្រុកដូរភូមិទាំងអស់ អត់ -- មាន ខ្ញុំសូមបញ្ជាក់ដែរ ការជម្លៀសចាមចេញពីភូមិដទៃនេះ មានចាមមួយចំនួន មួយចំនួនតិចតួចដែលត្រូវគេអនុញ្ញាតឱ្យរស់នៅក្នុងភូមិរបស់ខ្លួន ឱ្យបន្ត គេភាគច្រើនគេបញ្ជូនចេញពីភូមិ ដូចជានៅស្វាយឃ្លាំង ប្រហែលជានៅ -- សូមទោស មិនមែនស្វាយឃ្លាំងទេ នៅភូមិផ្សេងៗទៀត អ្នកគេមើលថាមាននិន្នាការទន់ខ្សោយ ដែលដើរតាមបដិវត្តន៍របស់គេ អត់មានប្រឆាំងនឹងគេៗទុកមួយចំនួនតូចឱ្យរស់នៅក្នុងភូមិកំណើតហ្នឹង។ ហើយពេលហ្នឹងគឺមានបងប្អូនខ្មែរចូលទៅរស់នៅក្នុងភូមិរបស់គាត់ លាយឡំជាមួយក្រុមរបស់គាត់ដែលនៅស្រុកកំណើតរបស់គាត់ហ្នឹង។

[១៤:១៤:៥៨]

**សៈ** សូមអរគុណ។ ហើយខ្ញុំមានសម្រង់ដែលដកដោយ -- ដកស្រង់ដោយលោក យៀវនិន ខ្ញុំសូមអានជូនលោក វាមានទំព័រ២៥៩ គឺ ERN ជាភាសាអង់គ្លេសគឺ <01150136> សូមអធ្យាស្រ័យ ខ្ញុំមិនអាចរក ERN ជាភាបារាំងទេ។ បាន គឺបានបញ្ជាក់ថា បាទ ខ្ញុំសូមអានជូនលោក គឺនៅក្នុងផ្នែកនុំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Font: Not Bold, Complex Script Font: Bold

**Deleted:** ញ្ជា

**Formatted:** Font: Not Bold, Complex Script Font: Bold

**Deleted:** ន្លៀ

**Deleted:** គឺមានដឹងថាមានភូមិជាទឹកដីសម្រាប់ជនជាតិចាមរស់នៅ ហើយតើគេមានការជូនទៅដាក់ទៅនៅ ជូនទៅនៅកន្លែងផ្សេងទៀតដែលឆ្ងាយពីភូមិកំណើតគេដែរទេ? ជាពិសេសគឺអ្នកកោះផល។

**Formatted:** Font: Not Bold, Complex Script Font: Bold

**Deleted:** <>

**Deleted:** 0

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

គឺនិយាយអំពីភូមិភាគនិរតី គឺនៅក្នុងកថាខណ្ឌទី១ នៅក្នុងប្រយោគទី២ "នៅក្នុងស្រុកអង្គរជ័យ គឺនិរតីនោះ គឺចាម ជនជាតិចាមដែលរស់នៅទីនោះ" គឺគេៗ បាទ សូមអធ្យាស្រ័យ គេហៅថា គឺគេ គេហៅថា មូលដ្ឋាន -- មូលថាញ់ ផ្ទុ -- "*មូលថាញ់ផ្ទុ*" – ហៅថា "<ប្រ>ជាជន<>ថ្មី" ដែលគេកំណត់នៅក្នុងការជម្លៀស<មុន>ឆ្នាំ១៩៧៥ ហើយអ្នកទាំងអស់នោះ គេហៅថា ជាប្រជាជនថ្មី បាទ។

ហើយបន្ទាប់មកទៀត នៅក្នុងប្រយោគមួយទៀត "អ្វីដែលសំខាន់បំផុតនោះ គឺពួកចាមនៅក្នុងនិរតីនោះ គឺគេហៅតែជាអ្នកគេបញ្ជូនទៅ ទោះបីជាគេបញ្ជូនចេញពីភូមិរបស់ខ្លួននៅក្នុងឆ្នាំ១៩៧៤។" ជាទូទៅ នៅក្នុងការកំណត់ប្រភេទនៃមនុស្សនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ <ជាប្រជាជនថ្មី និងប្រជាជនចាស់។ ក្នុងការសិក្សាស្រាវជ្រាវរបស់លោក>ថាតើគេ<ប្រព្រឹត្តលើ>ជនជាតិចាម<ដូច>ជាប្រជាជនមូលដ្ឋានដែរឬទេ?

[១៤:១៧:៣០]

**ឆ៖** ខ្ញុំមិនសូវបានស្រាវជ្រាវពីរឿងជនជាតិចាមនៅភូមិភាគនិរតីទេ ពីព្រោះប្រជាជនចាមរស់នៅតិចតួច។ ប៉ុន្តែខ្ញុំនិយាយជារួម ថាជនជាតិចាមត្រូវបានជម្លៀស ហើយសម្រាប់ប្រជាជននៅទីក្រុងខ្មែរដែលនៅទីក្រុងក៏បានជម្លៀស។ ហើយអ្នកដែលជម្លៀសទៅរស់នៅកន្លែងផ្សេង ខ្មែរក្រហមឲ្យនិយមន័យថា "ប្រជាជនថ្មី"។ ដូច្នេះវាដូចសម្រាប់ចាមដែរ គឺចាមត្រូវបានជម្លៀសដែរ។ ដូច្នេះចាម ក៏នៅក្នុងប្រភេទ គេហៅថាប្រជាជនថ្មីដូចគ្នាដែរ ពីព្រោះបានចាកចេញពីស្រុកកំណើតរបស់ខ្លួន ទៅរស់នៅលាយឡំជាមួយអ្នកផ្សេង។

**សៈ** <អ៊ីចឹងមានន័យ>ថា គេមិនចាត់ទុកប្រជាជនចាមជាប្រជាជនមូលដ្ឋាននោះទេ <ទោះបីជាពួកគេមកពីតំបន់>គ្រប់គ្រងរបស់បក្សកុម្មុយនីស្ត<ដែលរណសិរ្សកាន់កាប់តាំងពីឆ្នាំ១៩៧០>នោះ?

**ឆ៖** បាទ យើងឃើញថា ចាមត្រូវបានជម្លៀស មិនថានៅទីកន្លែងដែលគាត់បះបោរ ឬក៏មិនថាកើតឡើងតែនៅក្នុងស្រុកក្រូចឆ្មារទេ ដូចជាស្រុកផ្សេងទៀត ស្រុកឆ្លូង ខេត្តក្រចេះ ស្រុកពញាក្រែក ស្រុកត្បូងឃ្មុំ ស្រុកកងមាស ស្រុកកំពង់សៀម ត្រូវបានជម្លៀសទាំងអស់។ ជម្លៀសចេញពីស្រុកកំណើតរបស់ខ្លួន ឲ្យទៅរស់នៅលាយឡំជាមួយបងប្អូនខ្មែរ បែកបាក់គ្រួសារ ដល់ពេលកន្លែងដែលគាត់ទៅតាំងទីលំនៅថ្មីហ្នឹង ខ្វះខាតចំណីអាហារត្រូវគេ ចំណីអាហារ គេបែងចែកខុសពីអ្នកមូលដ្ឋាន ហើយយ៉ាងហោចណាស់ ក៏អ្នកមូលដ្ឋានហ្នឹង គាត់មានអ្វីៗដែលនៅសេសសល់ពីមុនមក គាត់អាចលាក់បាំងបាន ប៉ុន្តែសម្រាប់អ្នកដែលទៅរស់នៅថ្មី គឺទទេស្អាត សូម្បីតែផ្ទះ សូម្បីតែសម្លៀកបំពាក់ឲ្យគ្រប់គ្រាន់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: ជាតិ

Deleted: <>

Deleted: នៅក្នុង

Deleted:

Deleted: <>

Deleted: ៗចាត់

Deleted: <>

Deleted: តើៗមានករណី

Deleted: <>

Deleted: ជាពិសេស នៅពេលដែលស្ថិតនៅក្រោមការ

Deleted:

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ហ្នឹងគឺគ្មានផង គឺគាត់ត្រូវគេជម្លៀសចេញ ចាកចេញទៅហើយ។ អ៊ីចឹងស្ថានភាពសម្រាប់ជនជាតិចាមគ្រប់កន្លែងទាំងអស់មិនខុសពីស្ថានភាពប្រជាជនខ្មែរទូទៅ ដែលត្រូវបានគេជម្លៀសចេញពីទីក្រុងទេ គឺស្ថានភាពដូចគ្នា។ ដូច្នេះហើយសម្រាប់ខ្ញុំផ្ទាល់ ខ្ញុំយល់ឃើញថា ចាមក៏ត្រូវបានចាត់នៅក្នុងស្ថានភាពប្រជាជនថ្មីដូចប្រជាជនខ្មែរដែលចេញពីទីក្រុងដែរ។

[១៤:២០:៥៨]

**ស៖** សូមអរគុណលោក។ ខ្ញុំនឹងបន្តទៅប្រធានបទមួយទៀត គឺខ្ញុំចង់ជជែកជាមួយលោកជំនាញពាក់ព័ន្ធជាមួយនឹងចំនួនជនជាតិចាម ពាក់ព័ន្ធជាមួយនឹងចំនួនជនជាតិចាមដែលលោកអាចស្មានបាន តើមានចំនួនប៉ុន្មានមុនសម័យកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំចង់ដឹងថា តើលោកប្រតិកម្មយ៉ាងណាពាក់ព័ន្ធទៅនឹងសម្រង់របស់ -- នៅលើឯកសារ <E367/4.1.7>។ សូមអធ្យាស្រ័យលោកប្រធានដោយសារឯកសារយើងមិនទាន់មានលេខ ERN នៅឡើយ ហើយចាំយើងសម្រាកសិនចាំខ្ញុំជូនលេខឯកសារ ERN ជាភាសានីមួយៗនោះ។ នៅក្នុងកថាខណ្ឌទី២ របស់លោក ម៉ៃខល វីកឃើរី ហ្នឹង គាត់បានបញ្ជាក់ថា "ជនជាតិ -- ស្ថិតិប្រជាពលរដ្ឋកម្ពុជានៅក្នុងសម័យណាក៏ដោយ ជាពិសេសពាក់ព័ន្ធទៅនឹងការសន្មតក៏ដូចជាការទស្សន៍ទាយនោះ គឺវាប្រាកដជាមានការគណនាមិនគ្រប់គ្រាន់មួយ ដោយលោក យៀរនិន ហើយនិងខ្ញុំផ្ទាល់"។ ហើយនៅក្នុងឯកសារមួយទៀតក៏បានបញ្ជាក់ផងដែរថា គឺតាមរយៈ<លិខិតរបស់លោកសរសេរទៅ>កាសែតភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី១០ ខែ៣ ២០០៦ នោះ គឺបានបញ្ជាក់ថា លោកបានបញ្ជាក់ថា ជាការពិតណាស់ វាគឺជាផ្នែកមួយដែលមានការលំបាកក្នុងការស្រាវជ្រាវ ជាពិសេសពាក់ព័ន្ធទៅនឹងអ្នកដឹកនាំជនជាតិចាមដែលបានបាត់បង់ជីវិត ហើយក៏មានការយល់ស្របថា ទិន្នន័យទាំងអស់នោះ គឺផ្អែកទៅលើការស្រាវជ្រាវជាក់លាក់ ដែលយើងប្រើប្រាស់តាមរយៈអ្នកប្រាជ្ញដែលយើងត្រូវការឱ្យមានការសិក្សាស្រាវជ្រាវ។

អ៊ីចឹងខ្ញុំសួរថា ពាក់ព័ន្ធទៅនឹងអ្វីដែលលោក ម៉ៃខល វីកឃើរី ហើយនិងលោកបានបញ្ជាក់នោះគឺវាបញ្ជាក់អំពីការពិបាកក្នុងការទទួលបាននូវតួលេខ ចំនួនជនជាតិចាមមុនពេលកម្ពុជាប្រជាធិបតេយ្យ និងក្រោយពីកម្ពុជាប្រជាធិបតេយ្យមែនទេ?

[១៤:២៣:២៨]

**ឆ៖** បាទ ខ្ញុំឯកភាពថា ការស្វែងរកតួលេខមួយដែលពិតប្រាកដហ្នឹងគឺពិបាក ដោយសារថាយើងអត់មានឯកសារច្បាស់លាស់បង្ហាញថា ចំនួនពិតប្រាកដប៉ុនណាមុនរបបខ្មែរក្រហមនេះ។ ប៉ុន្តែបើ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** <>

**Deleted:** 1

**Formatted:** Font: Bold, Complex Script Font: Not Bold

**Deleted:** ត

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ក្រោយរបបខ្មែរក្រហម ការរាប់ចំនួនទៅអ្នកប្រាជ្ញផ្សេងៗ និងខ្ញុំផ្ទាល់ចំនួនមិនសូវជាខុសគ្នាទេ។ ប្រជាជនចាមទូទាំងប្រទេសហ្នឹងសល់ប្រហាក់ប្រហែលជា២០០.០០០នាក់។ បញ្ហាចម្រូងចម្រាសខុសគ្នា គឺមុនរបបខ្មែរក្រហម សម្រាប់ខ្ញុំផ្ទាល់ផ្អែកតាមសាក្សីដែលបានឃើញឯកសារ សាក្សីដែលបានចងចាំថា ប្រជាជនចាមនៅមុនរបបខ្មែរក្រហម។ គឺបានន័យថា ក្នុងសម័យលន់ នល់ មានប្រហាក់ប្រហែល ៧០០.០០០នាក់។ អ៊ីចឹងហើយការបូក ដកលេខហ្នឹងទៅ វាឃើញខុសជាមួយអ្នកស្រាវជ្រាវដទៃទៀត ពីព្រោះអ្នកស្រាវជ្រាវដទៃទៀតគាត់ផ្អែកទៅលើឯកសារដែលគាត់រកបានតាំងពីជំនាន់បារាំង ដូចលោក ប៊ែន យៀវនិន, វីកឃើរី ជាដើម គាត់ផ្អែកទៅលើឯកសាររបស់គាត់ ប៉ុន្តែសួរថាឯកសារបង្ហាញជាក់លាក់ឱ្យគាត់បង្ហាញឯកសារដែលគាត់យកហ្នឹងមក គឺវាអត់ឃើញជាក់លាក់ដូចគ្នា សម្រាប់ខ្ញុំគឺពឹងផ្អែកទៅលើសាក្សីសុទ្ធដែលខ្ញុំបានសម្ភាស។ ហើយខ្ញុំបានឃើញឯកសារមួយដែលខ្មែរក្រហមជម្លៀសប្រជាជនចាមចេញពីភូមិភាគបូព៌ា ទៅភូមិភាគពាយ័ព្យដែលជម្លៀសចេញពីភូមិភាគបូព៌ាហ្នឹង៥០០.០០០នាក់ ប៉ុន្តែនៅសល់តែ -- តែ៥០.០០០នាក់ សូមទោស ហើយប្រជាជនចាមនៅសល់ភូមិភាគបូព៌ាហ្នឹង ១០០.០០០នាក់ទៀត នេះឯកសារតួលេខ១៥។ អ៊ីចឹងហើយយើងមើលវាយតម្លៃគ្រាន់តែភូមិភាគបូព៌ាមួយមានប្រជាជនចាមជាង១០០.០០០នាក់ទៅហើយ ចុះនៅភូមិភាគខាងជើង នៅខេត្តដទៃៗទៀត អ៊ីចឹងខ្ញុំជឿថា អ្វីដែលខ្ញុំស្រាវជ្រាវមិនជាខុសពីការពិតប៉ុន្មានទេ ៧០០.០០០នាក់នោះ។

**ស៖** សូមថ្លែងអំណរគុណ លោកប្រធាន គឺខ្ញុំមានលេខឯកសារ E សម្រាប់ឯកសារលោក ម៉ៃខល វីកឃើរី គឺE3/9682 ហើយឯកសាររបស់លោក អ៊ីសា ឧស្មាននេះ គឺE3/9680។ ដូច្នេះប្រសិនបើខ្ញុំមិនច្រឡំទេ គឺទិន្នន័យដែលលោក ប៊ែន យៀវនិន ហើយនិង ម៉ៃខល វីកឃើរី ដែលបានប្រើប្រាស់នោះ គឺវាបានយកចេញមកពីជំរឿនដែលប្រមូលដោយសម័យអាណានិគមបារាំងនោះ គឺឆ្នាំ១៩៦២ តាមរយៈជំរឿនឆ្នាំ១៩៦២របស់រដ្ឋាភិបាល<។ ហើយខ្ញុំជឿថា យៀវនិន ផ្អែកលើ>បញ្ជី ចុះឈ្មោះបោះឆ្នោត។ គឺយើងឃើញថា តាមខ្ញុំយល់គឺយើងបានទទួលទិន្នន័យនេះនៅក្នុងសម័យ ឬក៏ជំរឿនសម័យអាណានិគមពោលគឺជំរឿនឆ្នាំ១៩៦២ មិនអ៊ីចឹងអីលោកជំនាញ?

[១៤:២៧:៤១]

**ឆ៖** បាទ ខ្ញុំបានអានសៀវភៅ វីកឃើរី និង ប៊ែន យៀវនិន ដែរខ្ញុំឃើញថាគាត់ពឹងផ្អែកទៅលើឯកសារជំរឿន ប៉ុន្តែយើងដាក់សំណួរថាតើយើងអាចទុកចិត្តបានប៉ុនណា។ បើខ្ញុំធ្លាប់សម្ភាសអ្នកដែលកើតមុនឆ្នាំ៦២ ធ្លាប់បានសួរតាមសហគមន៍ផ្សេងៗ តើកាលពីឆ្នាំ៦២ មុន៦២ ឬក៏ក្រោយ៦២ហ្នឹង តើ

Formatted: Font: Bold, Complex Script Font: Not Bold

Deleted: <>

Deleted: តាមរយៈការចុះ

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ទុ។*

01393021



មានគេរាប់ចំនួនជនជាតិចាមដែរអត់? គ្មានអ្នកណាចងចាំបានទេ ថាមានការរាប់ច្បាស់លាស់ណាមួយដែលយើងទុកចិត្តបាននោះ គឺអត់ឃើញ។ បានន័យថាអ្នកតាមស្រុកភូមិ អ្នកដែលធ្លាប់ធ្វើការជាប្រធានភូមិ ជាមេឃុំ ពេលហ្នឹងគឺអត់មានទេ គឺឈ្មោះចេញទៅមែន អាចមានធ្វើជំរឿនមែន ប៉ុន្តែមិនបែងចែកថាអ្នកណាជាចាម អ្នកណាជាខ្មែរ អ្នកណាជាចិន អ្នកណាជាវៀតណាមឲ្យបានជាក់លាក់។ អ៊ីចឹងខ្ញុំគិតថាវានៅតែមានការសង្ស័យថាតើជំរឿនដែលឯកសារដែលគាត់យោងហ្នឹង តើយើងជឿជាក់បានប៉ុនណា។

**ស៖** សូមអរគុណ។ អ៊ីចឹងខ្ញុំចង់<កែ>បន្តិច <ខាងដើមខ្ញុំនិយាយថា>សតវត្សរ៍ទី១៩។ <តាមពិតវាជាសតវត្សរ៍ទី>២០<។> <ដូចដែល ឃៀរនិន និង វីកឃើរី ពន្យល់ថា ឃៀរនិន ផ្តែកលើការធ្វើជំរឿន> ក្នុងឆ្នាំ១៩៣៦ នៅក្នុងកម្ពុជា <ហើយក៏មានការពិភាក្សាគ្នាលើការធ្វើជំរឿននៅក្នុងឆ្នាំ១៩៦២ផងដែរ>។ អ៊ីចឹងខ្ញុំសូមសួរថាតើលោកដឹងដែរឬទេ ថាតើជំរឿនហ្នឹងគេធ្វើឡើងយ៉ាងដូចម្តេចដែរ?

**ឆ៖** ជាការពិតហើយ ខ្ញុំអត់បានស្រាវជ្រាវពីរឿងជំរឿននៅក្នុងសម័យមុនសម័យខ្មែរក្រហមនោះទេ ខ្ញុំអត់បានស្រាវជ្រាវពីរឿងជំរឿននោះទេ។

**ស៖** ដូច្នេះលោកបញ្ជាក់ថា លោកបាននិយាយសម្ភាសជាមួយនឹងចាស់ៗ<។> <តើ>ជនជាតិចាមចាស់ៗ<ទាំងនោះចាំបានការធ្វើ>ជំរឿនឆ្នាំ១៩៦២ <ឬជំរឿនឆ្នាំ១៩៦៣> <ដោយរបៀបណាទេ?> <តើមាននរណាម្នាក់រំឭកពី>ជំរឿន<>ដែលខ្ញុំបញ្ជាក់អម្បាញ់មិញនេះ<ទេ>?

**ឆ៖** សម្រាប់សាក្សីដែលខ្ញុំសម្ភាសបានគាត់អត់មានចាំ អត់មានដឹងពីរឿងជំរឿននោះទេ ហើយខ្ញុំសម្ភាសសុទ្ធតែអ្នកដែលដឹងក្តីនៅក្នុងឆ្នាំ៦២ គាត់ជាយុវជនហើយ គាត់មានប្រពន្ធហើយ មានកូនហើយនៅក្នុងឆ្នាំ៦២ ហ្នឹងហើយគាត់អត់ដឹងថា មានជំរឿនណាមួយជាក់លាក់ មានផ្សាយតាមវិទ្យុជាតិថាចាមមានចំនួនប៉ុណ្ណេះ ខ្មែរប៉ុណ្ណេះ មានបោះពុម្ពជាឯកសារណាមួយច្បាស់លាស់ ឲ្យគាត់បានឃើញគឺអត់មានទេ។

[១៤:៣១:៤៣]

**ស៖** តើលោកដឹងដែរទេ បើសិនបើមិនដឹង ក៏ឆ្លើយថាមិនដឹងទៅ។ <តើអ្នកតបសំណួររបស់លោកប្រាប់ថា>នៅក្នុងជំរឿន<នោះ> <គេ>មានសួរគាត់ថា "តើគាត់ជនជាតិអីទេ?" <>"គាត់ជាក្រុមជនជាតិអី" ឬក៏យើងសួរថា "តើគាត់ជាជនជាតិចិន ខ្មែរ ឬក៏ចាម" <តើលោកដឹងថាគេមានសួរសំណួរបែបហ្នឹងដែរឬទេ>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: <>Ёកែរ ... [2]
Deleted: ការЁន្តិច ... [3]
Deleted: <>
Deleted: គឺនៅក្នុងសតវត្សរ៍ទី១០ --
Deleted: <>
Deleted: ដល់
Deleted: <>
Deleted: នេះគឺនៅ
Deleted: <>
Deleted: គេមានធ្វើជំរឿនចំនួនប្រាំមួយដងមកទល់នឹងពេលនេះ
Formatted: Condensed by 0.2 pt
Deleted: <>
Deleted: ដែលតាមរយៈ
Deleted: <>
Deleted: ដែលបានធ្វើ
Deleted: <>
Deleted: ឬក៏ជំរឿននៅក្នុងឆ្នាំ១៩៣៦ហ្នឹង
Deleted: <>
Deleted: តើលោកមានចាំទេ ពាក់ព័ន្ធទៅនឹងЁំរឿន<>ឆ្នាំ ... [4]
Deleted: <>
Deleted: នេះЁ<គេ>តើអ្នកដែលផ្តល់ ... [5]
Deleted: <>
Deleted: ថាតើសំណួរហ្នឹងគេ យើង ... [6]
Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)
Formatted: Font: 6 pt, Complex Script Font: 6 pt

01393022

E1/388.1/Corr-1



**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ សាក្សីទើបតែបាននិយាយថា មិនមានអ្នកណាចងចាំថាមានការធ្វើជំរឿនអ្វីទេ ចំពោះអ្នកដែលគាត់សម្គាសនោះ។ អ៊ីចឹង ខ្ញុំគិតថា សហព្រះរាជអាជ្ញាដូចជាមិនមានមូលដ្ឋានអ្វីដើម្បីមកសួរសំណួរទេ ពីព្រោះសាក្សីបានបញ្ជាក់ហើយថា អ្នកដែលគាត់សម្ភាសហ្នឹង គឺថាមិនមានអ្នកណានិយាយអំពីបញ្ហាហ្នឹងទេ។ ដូច្នេះសំណួរនេះ គឺមិនត្រឹមត្រូវទេ។

**លោក នីកូឡាស គូមជែន៖**

បាទ អ៊ីចឹងខ្ញុំសូម លោកប្រធានខ្ញុំសូមសួរ ពីព្រោះវាពាក់ព័ន្ធ ហើយអ្វីដែលសំខាន់នោះ ខ្ញុំយល់ស្របថា សាក្សីគាត់មិនៗដឹងនោះទេ។ អ៊ីចឹង ខ្ញុំសូមបន្ត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អ៊ីចឹងលោកបានបញ្ជាក់ថា នៅពេលព្រឹកមិញតាមរយៈសក្ខីកម្មរបស់លោកហ្នឹង<។> គឺ<នៅពេល>លោកប្រធានក៏សួរលោក<>ពាក់ព័ន្ធនឹងជនជាតិ គឺលោកឆ្លើយថា លោកជាជនជាតិចាម ប៉ុន្តែនៅក្នុងអត្តសញ្ញាណប័ណ្ណរបស់លោក គឺបញ្ជាក់ថាលោកជាជនជាតិខ្មែរ<។> <តើ>ជនជាតិចាមនៅក្នុងប្រទេសកម្ពុជា<ទាំងអស់គ្នា កំណត់អត្តសញ្ញាណខ្លួនឯង> <>ថាជា<សញ្ជាតិ>ខ្មែរដែរ មិនអ៊ីចឹង?

[១៤:៣៣:៤២]

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** នៅក្នុងអត្តសញ្ញាណប័ណ្ណអត់មានដាក់ទេ ថាជាជនជាតិចាម អត់មានចន្លោះកន្លែងហ្នឹងទេ ប៉ុន្តែបើឯកសារផ្លូវការមួយចំនួនផ្សេងទៀត រដ្ឋាភិបាល របស់រដ្ឋាភិបាល បច្ចុប្បន្នហ្នឹងដាក់ស្តែងគាត់មានដាក់កាន់សាសនាអ្វី? អ៊ីចឹងកន្លែងហ្នឹងយើងអាចបង្ហាញពីសាសនា អាចបង្ហាញពីជាតិសាសន៍កំណើតរបស់យើងថាជាចាម ឬក៏ជាចិនឧទាហរណ៍។ ហើយម្យ៉ាងទៀត ខ្ញុំសូមរំឭកអំពីសម័យសម្តេចសីហនុ គាត់ដាក់ឈ្មោះចាមហ្នឹង គាត់ហៅថាខ្មែរអ៊ីស្លាម ហើយពាក្យនេះ គឺសព្វថ្ងៃនេះគឺមានប្រជាប្រិយភាពណាស់នៅតាមសហគមន៍សព្វថ្ងៃនេះគាត់ចូលចិត្តប្រើពាក្យខ្មែរអ៊ីស្លាមដែរ។ ប៉ុន្តែអ្នកដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: <>

Deleted: បានបញ្ជាក់ គឺខ្ញុំក៏បានសួរដែរ ប៉ុន្តែខ្ញុំភ្លេចសួរ -- បាទ

Deleted: ដែរថា

Deleted: <>

Deleted: គឺពាក់ព័ន្ធនឹង

Deleted: បើកាន់អ៊ីចឹងគឺគេអាចដឹង

Deleted: <>

Deleted: ជនជាតិ

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

បង្កើតពាក្យថាខ្មែរអ៊ីស្លាមនេះ គឺព្រះកុរណា សម្ដេចឪ។ អ៊ីចឹងហើយបានថាឈ្មោះថាជាចាមនេះ ចេះតែបាត់បន្តិចម្ដងៗ បាត់តាមឯកសារផ្លូវការណាមួយ គឺអត់សូវមានចន្លោះដាក់ថាជាជនជាតិចាមទេ គេដាក់ថាខ្មែរៗដូចគ្នា ឬក៏គេហៅថា ជាផ្លូវការថា គេហៅថា "ខ្មែរអ៊ីស្លាម"។

**សៈ** តើលោកដឹងអំពីមូលហេតុណាមួយទេថា នៅក្នុងឆ្នាំ១៩៦០ ឬក៏ ៦២ តើជនជាតិចាមនៅពេលនោះ អាចឆ្លើយថាខ្លួនជាខ្មែរ ឬក៏ខ្លួនជាកម្ពុជានោះបានទេ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប។ អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។ ខ្ញុំមិនដឹងថា តើសំណួរនេះជាសំណួរបន្តពីការសួរពាក់ព័ន្ធនឹងការធ្វើជំរឿនឬក៏អត់? សួរអ៊ីចឹង គឺសួរឱ្យសាក្សីស្មានហើយ ត្រូវសួរបញ្ជាក់ឱ្យច្បាស់សិនថាតើ មានមូលដ្ឋានអ្វី? អ៊ីចឹង កាលដែលសហព្រះរាជអាជ្ញាសួររបៀបនេះ គឺសួរមិនត្រឹមត្រូវទេ ខ្ញុំសូមជំទាស់។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំព្យាយាមរៀបសំណួរឡើងវិញលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**សៈ** អ្នកជំនាញលើកនេះ យើងផ្ដោតតែទៅឆ្នាំ១៩៦០ បានហើយ។ តើលោកដឹងមូលហេតុណាមួយថា ហេតុអ្វីបានជាវាមានសារប្រយោជន៍ដែលនាំឱ្យជនជាតិចាមឆ្លើយទៅប្រាប់គេថា "ខ្ញុំជាខ្មែរ"។ តើវាមានហេតុផលណាមួយដើម្បីជាប្រយោជន៍ដល់ជនជាតិចាម ដូចជាការទទួលបាននូវការអប់រំរៀនសូត្រអីទេ បានជានាំឱ្យខ្លួនឆ្លើយថាខ្លួនជាខ្មែរ?

[១៤:៣៧:០៤]

**លោក អ៊ីសា ឧស្មាន៖**

**ឆៈ** សម្រាប់ជនជាតិចាមខ្លួនឯង ទៅកន្លែងណាក៏ដោយយើងមានមោទនភាពជាចាម។ យើងមិនដែលលាក់មុខថាខ្លួនមិនមែនចាមទេ។ ប៉ុន្តែអ្វីដែលធ្វើឱ្យយើងបាត់បង់ គឺតាមរយៈឯកសារផ្លូវការគេប្រើពាក្យថា ខ្មែរអ៊ីស្លាម ឬក៏នៅក្នុងអត្តសញ្ញាណប័ណ្ណ គេអត់ឱ្យយើងចន្លោះដាក់ថាចាមទេ គេប្រើដាក់ថាអត្តសញ្ញាណប័ណ្ណជនជាតិខ្មែរ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**ស៖** យោងតាមបទពិសោធន៍របស់លោកពេញមួយជីវិតនេះ តើជនជាតិចាមគាត់ចង់ប្រាប់សហការីរបស់គាត់ថាជាជនជាតិចាម ឬក៏វាមានហេតុផលណាផ្សេងដែលមិនចង់ឱ្យគាត់ប្រាប់ថាជាចាមទេ?

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសដែលខ្ញុំត្រូវរំខានម្ដងទៀត។ ខ្ញុំដូចជាវង្វេងហើយ មិនដឹងថាសហព្រះរាជអាជ្ញានិយាយអំពីឆ្នាំណា<>ពីរបបសម្ដេច_សីហនុ_<ឬ>មុនរដ្ឋប្រហារ សូមសហព្រះរាជអាជ្ញាបញ្ជាក់រយៈកាលឱ្យបានច្បាស់ដើម្បីកុំឱ្យចម្លើយហ្នឹងវាឆ្លើយទៅវាមិនត្រឹមត្រូវ វាធ្វើឱ្យភាន់ច្រឡំ។

**លោក នីកូឡាស គូមជែន៖**

បាទ ត្រឹមត្រូវហើយ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកអ្នកជំនាញនិយាយអំពីឆ្នាំ១៩៦០ ឬក៏ទសវត្សរ៍១៩៣០ ឬក៏ជំរឿនឆ្នាំ១៩៦២? តើលោកមានបានដឹងថា មានជនជាតិចាមណាម្នាក់មិនចង់បញ្ជាក់ប្រាប់គេថា ខ្លួនជាជនជាតិចាមដែរទេ ឬក៏មិនចង់បង្ហាញថា ខ្លួនកាន់សាសនាអ៊ីស្លាមនោះដែរទេ?

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** ខ្ញុំពិបាកសន្និដ្ឋាន--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! អ្នកជំនាញកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអភ័យទោសម្ដងទៀតលោកប្រធាន។ ប្រសិនបើសហព្រះរាជអាជ្ញាគាត់យោងទៅលើកាលបរិច្ឆេទពីរ ដែលពាក់ព័ន្ធទៅនឹងការជំរឿននោះ ហើយលោក អ៊ីសា ឧស្មាន គាត់បានពន្យល់ច្បាស់ហើយថានៅសម័យនោះ គឺមិនដឹងច្បាស់ថាមានការធ្វើជំរឿន ឬក៏យ៉ាងម៉េចទេ។ អ៊ីចឹងគាត់អត់បានធ្វើការស្រាវជ្រាវពាក់ព័ន្ធនឹងចំណុចនេះទេ ដូច្នេះបើគាត់ឆ្លើយទៅវាដូចជាមិនមានមូលដ្ឋានអ្វីទេ ពេលដែលសហព្រះរាជអាជ្ញាសួរអ៊ីចឹង គឺឆ្លើយឱ្យគាត់ៗឆ្លើយស្មានហើយ គាត់មិនបានធ្វើការសិក្សាស្រាវជ្រាវ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: ? គាត់និយាយពីឥឡូវនេះ ឬក៏និយាយ

Deleted:

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ច្បាស់លាស់ទៅធ្វើប្រធានបទហ្នឹងទេ។ អ៊ីចឹង ខ្ញុំសូមជំទាស់។

[១៤:៤០:២៣]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំយល់ឃើញថា មេធាវីការពារក្ដីគាត់មានចំណុចរបស់គាត់ ដូច្នេះ ខ្ញុំសូមបន្តទៅមុខទៀតចុះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោក ខ្ញុំនិយាយអំពីការប៉ាន់ប្រមាណចំនួនប្រជាជនចាម លោកបានប៉ាន់ប្រមាណថា ចាមមានប្រហែលជា១០ភាគរយ នៃប្រជាជនខ្មែរទាំងអស់នៅក្នុងឆ្នាំ<១៩៧៥> គឺនៅពេលដែលលោកសរសេរលោកថា មានប្រហែលជា១០ភាគរយនៃជនជាតិខ្មែរទាំងអស់?

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន តើអនុញ្ញាតឲ្យខ្ញុំសួរបន្តទៅទៀត ឬក៏ឈប់សម្រាកសិន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ឥឡូវហ្នឹងដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសាក្សី ដល់អ្នកជំនាញរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

Deleted: មួយពាន់ប្រាំបួនរយ

Deleted: ចិតប្រាំ

Deleted: --

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៥:០១:៥១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

បាទ អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ពេលយើងឈប់សម្រាក ខ្ញុំនិយាយអំពីការប៉ាន់ប្រមាណចំនួនប្រជាជនចាមមុនសម័យកម្ពុជាប្រជាធិបតេយ្យក្នុងសៀវភៅរបស់លោក ឯកសារ E3/1822 "អ៊ូគូបះ" នៅត្រង់លេខយោងជើងទំព័រលេខ៥ លោកបានប៉ាន់ប្រមាណថា ប្រហែលជាមានចាម<៧០០.០០០នាក់>។ ហើយខ្ញុំក៏បានយកឯកសារយោងនៅក្នុងលេខជើងទំព័ររបស់លោក ហ្សាការីយ៉ា អាដាម, វេស ស្លា, <វ៉ាន់> ម៉ាត់, ម៉ាត់ លី, សុះ កំរី<ហៅថា កាមារូឌីន ប៊ីន យូសុះ>, <><នៃ ប៉េណា> ហើយនិង<លោក ទ្រីសសារ៉ុម ជាអធិការ នាយកដ្ឋានអធិការកិច្ច នៃ>ក្រសួង<ធម្មការ និងសាសនា>មកយោង។

តើត្រឹមត្រូវដែរទេ ដែលថា លោកបានយកប្រភពទាំងប្រាំពីរយកមកសំអាងថា មានប្រជាជនចាមសរុបទាំងអស់ <៧០០.០០០>នាក់ អ៊ីចឹងដែរទេ?

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ ខ្ញុំសូមកែសម្រួលត្រង់សៀវភៅរបស់ខ្ញុំ មិនមែន៧០.០០០នាក់ ទេ ខ្ញុំបានសរសេរថា ៧០០.០០០នាក់ បានន័យថា ៧០ម៉ឺននាក់។ ហើយផ្អែកទៅតាមសាក្សីដែលខ្ញុំបានសម្ភាសសុទ្ធតែផ្តល់តួលេខមកដូចៗគ្នា ឬក៏រួមទាំងឯកសារដែល ឯកសាររបស់ខាងធម្មការដែលផ្តល់ជូនដោយលោក ទ្រីសសារ៉ុម ក៏បានបង្ហាញថាចាមមាន៧០០.០០០នាក់ ទាំងសៀវភៅដែលចងក្រងដោយលោក នៃ ប៉េណា ក៏ថាចាមមុនខ្មែរក្រហម ៧០០.០០០នាក់។ ហើយចំពោះដូចលោក ហ្សាការីយ៉ា អាដាម នេះគាត់ក៏ប៉ាន់ប្រមាណដូចគ្នា ពីព្រោះគាត់ធ្វើការឲ្យចាងហ្វាងអ៊ីស្លាម គ្រប់គ្រងអ៊ីស្លាមទូទាំងប្រទេសនៅក្នុងសម័យ

Deleted: <>

Deleted:

Deleted: ៧.០០០គ្រួសារ

Deleted:

Deleted: <>

Deleted: បាន

Deleted: គឺថា

Deleted: ណៃ

Deleted: នី

Deleted: ត្រេស

Deleted: <>

Deleted: អធិការកិច្ចនៃឈ្មោះថា សារ៉ុម នោះ ក៏លោកយក

Deleted: <>

Deleted: ៧០.០០០

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សង្គមរាស្ត្រនិយម។ អ៊ីចឹងប្រភពនីមួយៗ គឺនិយាយគឺមិនជាខុសគ្នាប៉ុន្មានទេ ប្រហាក់ប្រហែល ៧០០.០០០នាក់ៗ គ្រប់ប្រភពដែលខ្ញុំបានដកស្រង់មកនេះ គឺនិយាយប្រហាក់ប្រហែលគ្នា។ ដូច្នេះហើយបានខ្ញុំយកមកប្រើប្រាស់នៅក្នុងសៀវភៅរបស់ខ្ញុំ ដែលខ្ញុំគិតថាអាចពឹងផ្អែកទៅលើចំនួននេះ វាជាការពិតមួយ ចំនួនមួយដែលពិត ឬក៏វាកៀកនឹងការពិតមែនទែន។

[១៥:០៦:០៣]

**ស៖** សូមអរគុណលោកអ្នកជំនាញ។ ក្នុងសៀវភៅរបស់លោកគឺ៧០០.០០០ គឺត្រឹមត្រូវហើយ ក្រែងលោខ្ញុំលើកតួលេខអំមិញខុស នូវលេខជើងទំព័រលេខ៥ លោកយោងប្រភពចំនួនប្រាំពីរ។ ហើយខ្ញុំសូមលើកឡើងតែមតិពីរបីនាក់ទេ គឺទី១ និយាយអំពី នៃ ប៉េណា។ អ៊ីចឹងសូមលោកពន្យល់បន្តិចមើល៍ៗ នៃ ប៉េណា នេះជាអ្នកណា?

**ឆ៖** នៃ ប៉េណា នេះខ្ញុំបានអានសៀវភៅរបស់គាត់ ហើយខ្ញុំជឿថាគាត់ជាមន្ត្រីជាន់ខ្ពស់ម្នាក់នៅក្នុងរដ្ឋាភិបាល ក្រោយឆ្នាំ១៩៧៩នេះ ក្រោយពីដួលរលំនៃរបបខ្មែរក្រហម។

**ស៖** ឥឡូវ សូមចាប់ផ្តើមជាមួយប្រភពទី១ គឺលោកយកឈ្មោះ ហ្សាការីយ៉ា អាដាម យកមកនិយាយលោកបានបញ្ជាក់ថា គាត់និយាយថា ស្ថិតិនិយាយអំពីចំនួនប្រជាជនចាមនៅក្នុងប្រទេសកម្ពុជាដែលរៀបចំឡើងដោយ វ៉ាយ៉ាធិបតី។ ចុះវ៉ាយ៉ាធិបតី -- រាជាធិបតី នេះជាអ្នកណា?

**ឆ៖** ឈ្មោះរបស់គាត់គឺ រ៉េស ឡោះ។ ហើយរាជាធិបតីនេះគឺជាងារមួយដែលព្រះករុណាបានប្រទានឲ្យគាត់ក្នុងនាមគាត់ជាអ្នកគ្រប់គ្រងជនជាតិចាមនៅទូទាំងប្រទេសក្នុងសម័យសង្គមរាស្ត្រនិយម។ ខ្ញុំប្រៀបធៀបដូចជាងារសព្វថ្ងៃ គេហៅថាឧកញ៉ាសម្រាប់បុគ្គលម្នាក់ ដែលគាត់គ្រប់គ្រងចាមខាងសាសនាអ៊ីស្លាមនៅទូទាំងប្រទេសហ្នឹង គឺឈ្មោះ សុះ កំរី គេហៅថា ឧកញ៉ា សុះ កំរី ដែលព្រះករុណាបានប្រទានងារហ្នឹងឲ្យ។ អ៊ីចឹង រ៉េស ឡោះ ហ្នឹងគឺងាររបស់គាត់ រាជាធិបតី រ៉េស ឡោះ។ គឺមានតួនាទីការទទួលខុសត្រូវដូចឧកញ៉ា សុះ កំរី សព្វថ្ងៃនេះ។

**ស៖** សូមអរគុណច្រើនណាស់លោក ដែលលោកបានកែតម្រូវហ្នឹង។ ខ្ញុំមានប្រភពពីរដោយឡែកទៀត ទី១ គឺហ្សាការីយ៉ា អាដាម ថាគាត់បាននិយាយជាមួយ រ៉េស ឡោះ <> -- ដែលទទួលងារជារាជាធិបតី។ ចំពោះដែលប្រាប់គាត់អំពីតួលេខនេះ។ តើអ៊ីចឹងដែរទេ?

Deleted: ដែលមានចំណងជើង

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** សូមអរគុណច្រើនលោក។ តើលោកដឹងថាស្ថិតិទាំងអស់នេះត្រូវបានធ្វើឡើងដោយរបៀប

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ណា គេធ្វើជំរឿន ឬក៏គេសួរថ្នាក់ដឹកនាំថ្នាក់ភូមិ ឬក៏កម្រិតលើថ្នាក់ភូមិនេះ សម្រាប់ស្ថិតិជនជាតិចាមហ្នឹង? បើលោកដឹងក៏ដឹង លោកមិនដឹងក៏ឆ្លើយថាមិនដឹងទៅ។

[១៥:០៩:៤៤]

**ឆ៖** លោករាជាធិបតី រ៉េស ឡោះ ក្នុងនាមគាត់ជាចាងហ្វាងអ៊ិស្លាម គេហៅថា ឬក៏ពាក្យមួយទៀតគេហៅថា "មូហ្វទីអ៊ិស្លាម"។ បានន័យថា អ្នកគ្រប់គ្រងសាសនាអ៊ិស្លាម អ្នកគ្រប់គ្រងជនជាតិចាមនៅទូទាំងប្រទេស គាត់មានបណ្តាញរបស់គាត់។ មិនខុសពី ម៉ូហ្វទី សព្វថ្ងៃនេះទេ គឺមានបណ្តាញនៅគ្រប់មូលដ្ឋានដែលជនជាតិចាមរស់នៅ មានរចនាសម្ព័ន្ធថ្នាក់ខេត្ត ថ្នាក់ស្រុក ហើយនិងថ្នាក់ភូមិដែលព្រឹកមិញ ខ្ញុំនិយាយពីរឿងហាគីមនេះ ហាគីមនេះគឺជាបុគ្គលទទួលខុសត្រូវនៅក្នុងភូមិ ហើយនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មូហ្វទី អ៊ីចឹងរបាយការណ៍អំពីចំនួន ឬក៏របាយការណ៍អ្វីៗដែលកើតឡើងនៅតាមសហគមន៍នេះ គឺហាកឹមដែលប្រចាំនៅភូមិហ្នឹងជាអ្នកធ្វើរបាយការណ៍ ជាអ្នកស្រង់តួលេខផ្ញើមកឱ្យមូហ្វទីជាន់ទាបនៅថ្នាក់ខេត្ត ហើយថ្នាក់ខេត្តបូកសរុបបញ្ជូនមកថ្នាក់ជាតិ ដែលពេលហ្នឹងមានលោករាជាធិបតី រ៉េស ឡោះ។ អ៊ីចឹងហើយចំនួនប្រជាជនចាមដែលចងក្រងដោយ រ៉េស ឡោះ មិនមែនតាមរយៈប្រធានភូមិចៅហ្វាយស្រុក ចៅហ្វាយខេត្តទេ គឺតាមរចនាសម្ព័ន្ធរបស់គាត់។ មិនខុសពីមូហ្វទីសព្វថ្ងៃនេះទេ គឺគាត់មានតួលេខ មានរបាយការណ៍ជាក់លាក់របស់គាត់តាមរយៈក្រុមការងាររចនាសម្ព័ន្ធរបស់គាត់ផ្ទាល់ខុសពីរចនាសម្ព័ន្ធដែលរដ្ឋាភិបាលរៀបចំ។

**សៈ** សូមអរគុណច្រើន។ ខ្ញុំចង់ត្រឡប់ទៅក្រោយបន្តិចគឺឯកសារ E3/9680 គឺឯកសារដែលពាក់ព័ន្ធទៅនឹងលិខិតរបស់លោកផ្ញើជូនទៅភ្នំពេញប៉ុស្តិ៍ ខែមីនា ២០០៦ លោកនិយាយនៅត្រង់ទំព័រទី២ពេញមួយកថាខណ្ឌតែម្តង និយាយអំពីឈ្មោះ សែន ម៉ាត់ -- "សែន ម៉ាត់ អាយុ៩២ឆ្នាំ <ធ្វើការជាមួយបារាំងនៅចម្ការកៅស៊ូមេមត់> កំពង់ចាម គាត់បានប្រាប់ថា គាត់ឃើញបារាំងហ្នឹងកត់ត្រាកម្មករនៅចម្ការកៅស៊ូជាង៣០០កន្លែង គឺថាភាគច្រើនជាជនជាតិចាម។ <បារាំងចុះឈ្មោះអ្នកទាំងនោះថាជាខ្មែរចៀរជ័រកៅស៊ូ>។ តើលោកនៅចាំទេ លោកសម្ភាសលោក សែន ម៉ាត់ ហ្នឹងនៅពេលណាដែរ?

**ឆ៖** លោក សែន ម៉ាត់ នេះខ្ញុំសម្ភាសសម្រាប់សរសេរអត្ថបទនោះ។ សែន ម៉ាត់ នេះ កាលកិច្ចសម្ភាសន៍របស់គាត់អត់មានបញ្ចូលនៅក្នុងសៀវភៅណាមួយរបស់ខ្ញុំទេ។ ដើម្បីបញ្ជាក់ថាតើគាត់ជាអ្នកចាស់ទុំ គាត់ជាអ្នកមានការងារធ្វើនៅខាងចម្ការកៅស៊ូហ្នឹង តើគាត់បានឃើញអំពីការជំរឿនរបស់បារាំងមែនអត់? អ៊ីចឹងហើយចម្លើយរបស់គាត់ហ្នឹង ដកស្រង់ចម្លើយរបស់គាត់ហ្នឹង ខ្ញុំបានសរសេរជាអត្ថបទ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** <>

**Deleted:** គឺជាអ្នកទទួលខុសត្រូវផ្នែកខាងចម្ការកៅស៊ូនៅ

**Deleted:** <>

**Deleted:** យើង -- គឺជាអ្នកដែល គឺអ្នកធ្វើការសម្រាប់ដែលត្រងជ័រកៅស៊ូ

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ហ្នឹងមក។

[១៥:១៤:០៣]

**ស៖** បាទ សូមអរគុណច្រើន។ ឥឡូវនោះ ខ្ញុំសូមសួរលោកអំពីផ្នែកមួយនៃសៀវភៅរបស់លោក "អ៊ីគូបះ"នេះ –យុត្តិធម៌នេះ– នៅត្រង់ទំព័រ១២០ នៃសៀវភៅរបស់លោកគឺឯកសារ E3/1822 ERN ជាភាសាបារាំង 00758331 ដល់ 2 នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅរបស់លោកនេះ លោកបានរៀបជាបញ្ជីនៅអ្នកភូមិផ្សេងៗ ក៏ដូចជាចំនួនគ្រួសារនៅក្នុងភូមិទាំងនោះនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។ ខ្ញុំសូមសួរលោកអំពីចំណុចទាំងអស់នេះ និងបន្ថែមតួលេខនេះផង។

លោកប្រធាន ខ្ញុំយល់ឃើញថា វាមានសារប្រយោជន៍ដល់ភាគីទាំងអស់ក្នុងការតាមដានចំណុចទាំងអស់នេះ។ ខ្ញុំក៏បានផ្តល់ទៅដល់មេធាវីការពារក្តីដែរ មិនដឹងថាតើការគណនាលេខនព្វន្តរបស់ខ្ញុំយ៉ាងណានោះទេ គឺខ្ញុំបានបន្ថែមកូឡោនមួយ និយាយអំពីចំនួនមនុស្សដែលត្រូវបានស្លាប់ចន្លោះពីឆ្នាំ១៩៧៥ ដល់៧៩។ ដូច្នេះ សំណួរដំបូងរបស់ខ្ញុំបើអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំមិនដឹងសុំសូមសួរ វាវែងបន្តិចដែរ ប៉ុន្តែខ្ញុំមិនបានស្នើសុំឲ្យទទួលយកទៅធ្វើជាភស្តុតាងនោះទេ។ នេះគ្រាន់តែជាការគណនាបែបលេខនព្វន្តរបស់ខ្ញុំតែប៉ុណ្ណោះ។ ដូច្នេះ សូមការអនុញ្ញាតពីអង្គជំនុំជម្រះ។

ខ្ញុំគិតថាខ្ញុំបានថតចម្លងច្រើនច្បាប់ដែរ អាចចែកជូនគ្រប់ភាគីទាំងអស់បាន។

[១៥:១៥:០៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកសហព្រះរាជអាជ្ញា លោកចង់ធ្វើការគណនាចេញពីតួលេខដែលអ្នកជំនាញបានធ្វើនៅក្នុងសៀវភៅគាត់ ឬក៏លោកផ្អែកទៅលើតួលេខរបស់អ្នកជំនាញ ហើយលោកធ្វើការបូកសរុបដោយខ្លួនឯង ឬក៏យ៉ាងម៉េច?

**លោក នីកូឡាស គូមជែន៖**

បាទ លោកចៅក្រម ខ្ញុំសូមជម្រាបដោយស្មោះត្រង់ជាមួយនឹងលោក លោកស្រីចៅក្រម។ ទី១ ខ្ញុំសួរសាក្សី ដោយមិនទាំមុខ មិនសួរផ្តល់តម្រុយអីទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

01393030



**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី -- លោកអ្នកជំនាញ លោកព្រឹកមិញនិយាយពីការប៉ាន់ប្រមាណចំនួនគ្រួសារចាម នៅពេលដែលយើងនិយាយពីចន្លោះពីពេល១៩៧៥។ តើលោកយល់យ៉ាងដូចម្ដេចដែរ ដែលថានៅពេលនោះ គឺសមាជិកគ្រួសារនីមួយៗមានចំនួនប៉ុន្មាននាក់ដែរ ហើយតើគេរាប់បញ្ចូលតាំងពីជីដូនជីតា ឪពុកម្ដាយ និងកូនៗ ឬក៏យ៉ាងដូចម្ដេច?

[១៥:១៧:២៤]

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** ទម្លាប់នៅស្រុកខ្មែរ មិនថាចាម មិនថាខ្មែរទេ ភាគច្រើនភូមិមួយគេរាប់ចំនួនគ្រួសារ។ ដូច្នេះនៅតាមភូមិមួយចំនួន យើងអត់ដឹងចំនួនប្រជាជនជាក់លាក់ទេ។ ចំនួនគ្រួសារ គឺបានន័យថាផ្ទះមួយ គ្រួសារមានប្ដីប្រពន្ធមានកូន គេហៅថាគ្រួសារមួយ។ ហើយខ្លះមក គ្រួសារខ្លះ មានដល់ទៅចៅទៀត អត់ទាន់បំបែកផ្ទះទេ ក៏គេនៅតែហៅថាជាគ្រួសារមួយដែរ។ អ៊ីចឹង ខ្ញុំគ្រាន់ថាឲ្យតួរលេខប្រហាក់ប្រហែល មិនជាខុសប៉ុន្មានទេ។ ក្នុងមួយៗគ្រួសារ ចំនួនមនុស្សប្រហែលជាពីប្រាំ ទៅប្រាំមួយនាក់ នៅក្នុងគ្រួសារមួយៗ។ មិនៗៗខុសច្រើនទេ គឺប្រហាក់ប្រហែលហ្នឹង។

**ស៖** តើគ្រួសារយើងនិយាយសំដៅទៅលើដំបូលផ្ទះ គឺអ្នកដែលរស់នៅក្រោមដំបូលផ្ទះតែមួយអ៊ីចឹងឬ?

**ឆ៖** បាទ ក្រោមដំបូលផ្ទះតែមួយ ពីព្រោះទម្លាប់ដែលហៅគ្រួសារនេះ ខ្ញុំគិតថាមកពី ដើម្បីទទួលអំណោយ។ មកដល់សព្វថ្ងៃនេះក៏ដោយ ការបែងចែកអំណោយដែលរដ្ឋាភិបាលមាន សង្គមមុនក៏ខ្ញុំជឿថាមិនខុសគ្នាដែរ គឺគេរាប់ចំនួនថាគ្រួសារ អ៊ីចឹងមួយគ្រួសារបានអង្ករម្នាក់មួយបាវ ឬក៏បាន មួយគ្រួសារបានសារុងម្នាក់មួយ ប៊ីចេងម្នាក់មួយ។ អ៊ីចឹងគេគិតជាគ្រួសារ គេអត់រាប់ចំនួនមនុស្សទេ។ ដូច្នេះរកចំនួនជាក់លាក់នៅក្នុងភូមិមួយហ្នឹង ទាល់តែប្រធានភូមិ បានគាត់មានកត់លេខច្បាស់លាស់ បើសួរអ្នកភូមិគាត់ដឹងថាភូមិរបស់គាត់មានចំនួនប៉ុណ្ណេះគ្រួសារ ប៉ុណ្ណោះគ្រួសារ។ ភាគច្រើនគឺទម្លាប់ដែលចេញពីការរង់ចាំទទួលអំណោយ ដែលគេផ្ដល់ឲ្យ។

[១៥:២០:០០]

**ស៖** សូមអរគុណ។ ចុះក្នុងស្ថានភាពដែលមានជីដូនជីតា <u><ឬក៏ជីទួតផង></u>រស់នៅជាមួយកូនជាមួយចៅ គេរាប់ថាមួយគ្រួសារដែរឬ?

*<u>ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។</u>*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

**ឆ៖** បាទ ត្រឹមត្រូវហើយ ហៅថាគ្រួសារមួយ។

**ស៖** សូមអរគុណលោកអ្នកជំនាញ។

ដូច្នេះ លោកចៅក្រម ឡាវ៉ែន៍ គឺថា អ្នកជំនាញបានឆ្លើយទៅនឹងសំណួររបស់លោកចៅក្រមហើយ។ ពាក់ព័ន្ធទៅនឹងតួលេខដែលខ្ញុំធ្វើគណនាលេខពន្លត្តហ្នឹង គឺខ្ញុំគុណចំនួនគ្រួសារ យកចំនួនគ្រួសារទៅគុណនឹងប្រាំ រកឃើញចំនួនមនុស្សសរុប។ ហើយអ្នកជំនាញក៏ថា ដែរថាក្នុងមួយគ្រួសារគិតជាមធ្យមគឺប្រាំ ទៅប្រាំមួយនាក់ មិនតិច មិនច្រើនពេក។ ដូច្នេះ អ្វីដែលខ្ញុំគណនានេះ គឺខ្ញុំយកតួលេខដែលអ្នកជំនាញបាន -- ដែលសាក្សីបានប្រាប់ចំនួនគ្រួសារនៅក្នុងភូមិនីមួយៗមកអ្នកជំនាញនៅក្នុងឆ្នាំ -- ពីឆ្នាំ១៩៧៥ ដល់៧៩ ដែលយើងឃើញថា មានប្រាំមួយនាក់រស់នៅក្នុងផ្ទះនីមួយៗ។ ខ្ញុំយកចំនួនគ្រួសារទៅគុណនឹងប្រាំ។ ដូចអ្នកជំនាញបានលើកដែរថា ជាមធ្យមគឺ មានប្រាំទៅប្រាំមួយនាក់។ អ៊ីចឹងខ្ញុំគុណតែជាមួយនឹងប្រាំ<ជាមធ្យម>ទេ <ហើយខ្ញុំបូកចំនួនទាំងអស់បញ្ចូលគ្នា>។

**<ចៅក្រម ក្លូឌា ហ្វេនស័៖>**

ខ្ញុំសូមបន្ថែមបន្តិច។ បើសិនណាជាមិនមានសំណើឲ្យដាក់ឯកសារនេះចូលក្នុងសំណុំរឿងទេ អ៊ីចឹងលោកយកតួលេខនេះមកសួរដើម្បី គឺបញ្ហានេះសម្រាប់តែបេតិចារឹកតែប៉ុណ្ណោះមែនទេ? ពីព្រោះថា បើមិនដូច្នេះទេ អង្គជំនុំជម្រះមិនសម្រេចពិចារណាថាត្រូវដាក់ចូលក្នុងសំណុំរឿងទេ។ ហើយលោកចំណាយពេលប្រហែល១០នាទីទៅមុខទៀតដើម្បីកុំឲ្យយើងមានការច្របូកច្របល់ លោកសុំឲ្យអង្គជំនុំជម្រះ ក៏ដូចភាគីទាំងអស់តាមដានស្តាប់ទាំងអស់នេះ ហើយនិងឲ្យអ្នកជំនាញឆ្លើយដើម្បីឆ្លុះបញ្ចាំងនូវអ្វីដែលលោកសរសេរនេះ។

**<លោក នីកូឡាស គូមជែន៖>**

<បាទ ប្រាកដហើយ លោកស្រីចៅក្រម។ ខ្ញុំពិតជាមិនជំទាស់អ្វីដែលនឹងកើតឡើងទៅនឹងសំណុំរឿងទេ>អាស្រ័យទៅលើអង្គជំនុំជម្រះ តើពិចារណាគួរយកដាក់ចូលសំណុំរឿង ឬក៏អត់នោះទេ។ ប៉ុន្តែបើសហការីរបស់ខ្ញុំ ភាគីមេធាវីការពារមិនចង់បានទេ មិនជាអ្វីទេ។ ហើយខ្ញុំគ្រាន់តែចង់ឲ្យ<លោកសាក្សី និងអង្គជំនុំជម្រះ>ថាតើការគណនាបែបលេខពន្លត្តរបស់ខ្ញុំនេះវាយ៉ាងណាដែរ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ អង់តា ហ្គីសសេ!

[១៥:២២:៣៩]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Deleted:** ¶

**Deleted:** <>

**Deleted:** មានការយកចិត្តទុកដាក់

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានសូមអរគុណ។ ខ្ញុំយល់អំពីចំណុចនេះ ខ្ញុំយល់ពីចេតនារបស់សហព្រះរាជអាជ្ញា ក៏ប៉ុន្តែគាត់យកឯកសារខ្លួនគាត់ផ្ទាល់ជាអ្នកគណនាផ្ទាល់ ហើយយកមកដាក់នៅក្នុងសំណុំរឿង ខ្ញុំគិតថាវាមិនត្រឹមត្រូវទេ។ ខ្ញុំយល់អំពីភាពសមហេតុផលរបស់គាត់ ទោះបីជាខ្ញុំមិនដឹងថា តើដំណើរការនៃការគិតលេខរបស់គាត់ហ្នឹងយ៉ាងម៉េចក៏ដោយ។ ក៏ប៉ុន្តែមុនពេលបន្តទៅទៀតពាក់ព័ន្ធទៅនឹងតួលេខនេះ គាត់គួរតែសួរទៅអ្នកជំនាញអំពីមូលដ្ឋាននៃការគណនារបស់អ្នកជំនាញ តើក្នុងមួយគ្រួសារមានចំនួនសមាជិកប្រាំនាក់នេះ គាត់បានប្រភពមកពីណាសួរអ្នកជំនាញទៅមើល ប្រភពជាក់លាក់មកពីណា ម៉េចបានជាគាត់ហ៊ានអះអាងថា មួយគ្រួសារមានសមាជិកប្រាំនាក់ ហើយយកមកគុណនឹងប្រាំ? អ៊ីចឹង ខ្ញុំមិនយល់អំពីមូលដ្ឋានហ្នឹងទេ។ អ៊ីចឹងសុំឱ្យសហព្រះរាជអាជ្ញាសួរឱ្យច្បាស់ពីចំណុចនេះ។ នេះជាចំណុចទី១។ ច្បាស់ណាស់ ពាក់ព័ន្ធទៅនឹងគោលការណ៍នៃការសុំដាក់ឯកសារនៅក្នុងសំណុំរឿងនោះ គឺខ្ញុំសូមជំទាស់ព្រោះនេះជាឯកសារផ្ទាល់ខ្លួនរបស់គាត់ គាត់គួរតែរៀបចំសំណួរតាមរបៀបផ្សេង ដើម្បីធ្វើយ៉ាងម៉េចឱ្យគាត់អាចយោងទៅលើឯកសាររបស់អ្នកជំនាញវិញ គឺឯកសារ E3/1822 កុំយកឯកសាររបស់គាត់យកមកយោង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ តើខ្ញុំអាចមានឯកសារនេះមួយច្បាប់បានទេដើម្បីឱ្យខ្ញុំអាចតាមដាននៃការពិភាក្សាដេញដោលនេះ យើងខ្ញុំអត់ទាន់មានទេ ឯកសារហ្នឹង។

[១៥:២៤:៤៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមនិយាយពាក់ព័ន្ធទៅនឹងប្រតិចារឹក ពីព្រោះជាងកន្លះឆ្នាំ<ទៀត> គឺថាយើងមិនដឹងថា តើយើងកំពុងនិយាយគ្នាអំពីអ្វីដែរ។ លោក បើសិនណាជាលោកសួរដើម្បីតែបញ្ចូលប្រតិចារឹកទេ គឺមិនជាថ្មីទេ ប៉ុន្តែទៅតាមលំដាប់លំដោយ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំព្យាយាមរៀបចំទៅតាមរចនាសម្ព័ន្ធឱ្យបានស្រួលបួល។ សាក្សី -- អ្នកជំនាញក៏បានឆ្លើយពាក់ព័ន្ធទៅនឹងចំនួនគ្រួសារ ចំនួនសមាជិកជាមធ្យមដែរ។ ខ្ញុំក៏នឹងសួរគាត់ទៅលើមូលដ្ឋាននៃតួលេខទាំងអស់នេះដែរ ដើម្បីអនុញ្ញាតឱ្យភាគីនីមួយៗអាចតាមដានទៅនឹងការគណនាតួលេខបែបលេខនព្វន្តនេះ ហើយ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

Formatted: ECCC Talker

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ក៏អាចដើម្បីឲ្យប្រតិចារឹកទៅថ្ងៃមុខហ្នឹងក៏ធ្វើរបៀបនេះផងដែរ ដោយគណនាតាមរបៀបនេះឯង។ តើដូច្នេះ អនុញ្ញាតឲ្យខ្ញុំផ្តល់ឯកសារដែលខ្ញុំរៀបចំនេះទៅអ្នកជំនាញមួយច្បាប់បានទេ ដើម្បីឲ្យគាត់អាចតាមនូវសំណួររបស់ខ្ញុំបាន?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីសហព្រះរាជអាជ្ញាជូនទៅអ្នកជំនាញ!

[១៥:២៦:១៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមទោស បើសិនណាជាផ្តល់ទៅឲ្យអ្នកជំនាញ ហ្នឹងត្រូវតែដាក់ចូលក្នុងសំណុំរឿងហើយ។ អ៊ីចឹងសូមៗ តើយើងអាចឈប់សម្រាកបន្តិចពិភាក្សាក្នុងចំណោមចៅក្រមបន្តិចសិនបានទេ?

**សួរដោយលោក នីកូឡាស គូមជែន៖**

ខ្ញុំមានបំណងអានតែអ្វីដែលខ្ញុំបន្ថែម ដើម្បីបញ្ជាប្រតិចារឹក។ អ៊ីចឹងប្រតិចារឹក គឺវាពាក់ព័ន្ធទៅនឹងការគណនាតាមបែបគណិតវិទ្យា ដើម្បីសរសេរចូលទៅក្នុងប្រតិចារឹកតែប៉ុណ្ណោះ។

**ស៖** បាទ សូមអរគុណ។ លោកសាក្សីនៅត្រង់ទំព័រ១២០ នេះ ដែលនិយាយអំពី "អ៊ំគូបះ–យុត្តិធម៌"នោះ លោកនិយាយបញ្ជីចំនួនភូមិ ហើយក្នុងសៀវភៅរបស់លោក លោកក៏រៀបរាប់<នូវ> ចំនួនប្រជាពលរដ្ឋក្នុងឆ្នាំ១៩៧៥ ដល់ ៧៩ ប៉ុន្តែត្រង់នេះ ខ្ញុំបន្ថែមកូឡោនមួយទៀត មួយបន្ទាត់ទៀតសម្រាប់ហេតុផលនៃការបាត់បង់ចំនួនមនុស្សចន្លោះពីឆ្នាំ៧៥ ទៅ ៧៩។ ដូច្នេះ ដំបូង តើលោកទទួលបានតួលេខនៅទំព័រ១២០នៃសៀវភៅរបស់លោកសរសេរថា "អ៊ំគូបះ – យុត្តិធម៌" នេះ បានទទួលដោយរបៀបណា?

[១៥:២៧:៤៦]

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** នៅក្នុងសៀវភៅចំណុចនីមួយៗសុទ្ធតែមានយោង ហើយយោងនេះ គឺសំដៅទៅលើការសម្ភាសរបស់ខ្ញុំជាមួយអ្នកភូមិនោះផ្ទាល់ដែលនៅរស់រានមានជីវិត ដែលគាត់បានប្រាប់ខ្ញុំថា ចំនួនពីមុន ៧៥ប៉ុណ្ណោះ ដល់ពេលក្រោយ៧៩មក នៅសល់ប៉ុណ្ណោះ គឺសុទ្ធតែមានឈ្មោះសាក្សីទាំងអស់។ សៀវភៅរបស់ខ្ញុំនៅទំព័រ១២០នេះ ជាក់ស្តែងដូចនៅភូមិអកមោក លោកឧញ្ញាសុះ កំរី គាត់ប្រាប់ខ្ញុំអ៊ីចឹង។ ហើយ

Deleted: នៅ

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01393034





នៅជ្រោងចង្វាក្រោមនេះ ខ្ញុំបានទទួលព័ត៌មានពីលោក ហ្សាការីយ៉ា ពិន អះម៉ាត់ ហើយនៅភូមិផ្សេងទៀត ដូចគ្នាអ៊ីចឹងដែរ។ ខ្ញុំបានសម្ភាសសាក្សី ហើយខ្ញុំរើសសាក្សីណាដែលគាត់ដឹង ដែលយើងអាចជឿជាក់បាន។ អ៊ីចឹងយើងដកស្រង់ចំនួននេះ គឺពីអ្វីដែលសាក្សី ដែលខ្ញុំបានសម្ភាសប្រាប់ខ្ញុំ។

[១៥:២៩:០៨]

**ស៖** សូមអរគុណ។ ដំបូងខ្ញុំនិយាយអំពីអ្នកភូមិដែលលោកនិយាយពីចំនួនគ្រួសារ <មិនមែនជាចំនួនមនុស្សរាយឡើយ។ មានតែភូមិ កោះផល និងភូមិប៉ើស តែប៉ុណ្ណោះដែលលោកស្រង់ជាចំនួនមនុស្សរាយ>។ គឺនិយាយពីឆ្នាំ១៩៧៥ នៅភូមិអកមោកហ្នឹង គឺមាន១.១០០គ្រួសារ។ ដល់ឆ្នាំ១៩៧៩ មានមានប្រជាជនរស់នៅតែ១០០គ្រួសារទេ។ បើអ៊ីចឹងយើងឃើញថាបាត់១.០០០គ្រួសារ។ សម្រាប់ភូមិជ្រោយចង្វាក្រោម នៅកន្លែងយើងហៅថា អែតក្រាសៃ – វិហារអែតក្រាសៃ លោកថា មានជាង១.០០០គ្រួសារហ្នឹងនៅក្នុងឆ្នាំ១៩៧៥ ហើយនៅសល់តែ -- មានតែ៣០គ្រួសារទេនៅក្នុងឆ្នាំ១៩៧៩។ អ៊ីចឹងឃើញថាបាត់អស់៩៧០គ្រួសារ។ សម្រាប់ដូនពេញ នៅក្នុងឆ្នាំ១៩៧៥ មាន១៥០គ្រួសារ។ ៧៩ មានតែ១០០គ្រួសារ អ៊ីចឹងបាត់អស់៥០គ្រួសារ។ នៅសំរោងមាន៤០គ្រួសារហ្នឹង ឆ្នាំ១៩៧៥ ដល់៧៩ សល់តែបួនគ្រួសារ អ៊ីចឹងបាត់អស់៣៦គ្រួសារ។ ស្វាយឃ្លាំង មាន១២៤០គ្រួសារ ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មានតែ១២០គ្រួសារ។ នេះជាភូមិកំណើតរបស់លោកហើយ។ គឺអ៊ីចឹងឃើញថា បាត់អស់ <>-- ១.២២០គ្រួសារ។ នៅភូមិត្រពាំងឈូក ក្នុងឆ្នាំ១៩៧៥ មាន២៥៤គ្រួសារ ដល់ឆ្នាំ១៩៧៩ សល់តែ១៩២គ្រួសារ អ៊ីចឹងឃើញថាបាត់អត់៦២គ្រួសារ។ នៅភូមិទ្រា លោកបានសរសេរថា មានប្រហែលជា១.០០០គ្រួសារក្នុងឆ្នាំ៧៥។ ដល់៧៩មានតែ៥០០គ្រួសារ អ៊ីចឹងបាត់អស់៥០០គ្រួសារ។ អ៊ីចឹងចំនួនគ្រួសារពីភូមិទាំងអស់ហ្នឹង សរុបទៅមាន៣.៨៣៨គ្រួសារ។ ហើយខ្ញុំគិតឃើញថា ក្នុងមួយគ្រួសារមានសមាជិកប្រហែលជាប្រាំនាក់ អ៊ីចឹងខ្ញុំគុណជាមួយមេគុណប្រាំនេះ ឃើញលទ្ធផលទៅ ១៩.១២០ <នាក់>។ បាទ អ៊ីចឹង តើមានការយល់ឃើញយ៉ាងដូចម្តេចដែរ?

**ឆ៖** ផ្អែកទៅលើការស្រាវជ្រាវរបស់ខ្ញុំ ដោយយោងទៅៗលើព័ត៌មានដែលផ្តល់ដោយអ្នកដែលខ្ញុំសម្ភាសគឺ ខ្ញុំគិតថាចំនួនដែលបាត់មាន១៩.១២០នាក់នេះ មិនជាខុសប៉ុន្មានទេ ព្រោះយើងគិតវាយតម្លៃប្រាំនាក់នេះ គឺៗតិចហើយ គឺយើងវាយតិចបំផុតមួយគ្រួសារហ្នឹងប្រាំនាក់។ ពីព្រោះយើងដឹងហើយ ជនជាតិចាមគាត់មានជំនឿថា មិនអាចការពារកូនបានទេ អ៊ីចឹងជាក់ស្តែង គឺគ្រួសារនីមួយៗធំណាស់ ចំនួនប្រាំនាក់នេះ គឺយើងវាយទាបហើយ ទាបបំផុតហើយ។ គ្រួសារចាមពីដើម មានលើសពីប្រាំមួយនាក់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: ។

Deleted: <>

Deleted: គឺកោះផល ភូមិកោះផល

Deleted: មួយរយ

Deleted:

Deleted: <>

Deleted: គ្រួសារ

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ភាគច្រើន នៅក្នុងគ្រួសារមួយៗ។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។ ផ្អាកបន្តិចសិន លោកសហព្រះរាជអាជ្ញាអន្តរជាតិ។

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៥:៣៣:២១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំមានសំណួរមួយសូមឲ្យបំភ្លឺ។ លោកនិយាយអំពីការបាត់បង់ចំនួនមនុស្ស អ៊ីចឹងខ្ញុំយល់ថាវាជាសំណល់ប្រជាជនយ៉ាងម៉េច ព្រោះថាបើមានន័យថាបាត់បង់ហ្នឹង មានន័យថាអ្នកទាំងអស់ហ្នឹង គឺប្រាកដជាស្លាប់។ ក៏ប៉ុន្តែក្នុងករណីយើងនេះ វាមិនប្រាកដថាស្លាប់ ឬមិនស្លាប់ទេ អ៊ីចឹងមានន័យថាគ្រាន់តែជាសំណល់ បើយើងបូកដកលេខទៅ គឺគ្រាន់តែជាសំណល់ ឃើញប៉ុណ្ណឹង។ អ៊ីចឹងខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ ព្រោះថាអាចថា អ្នកហ្នឹងមិននៅកន្លែងហ្នឹង មិនមែនបានន័យថាស្លាប់ទេ គាត់អាចភៀសខ្លួនទៅបរទេស ឬក៏ទៅបោះទីតាំង ឬក៏ទៅតាំងទីលំនៅនៅកន្លែងណាមួយផ្សេង?

**លោក នីកូឡាស គូមជែន៖**

នេះជាចំណុចត្រឹមត្រូវហើយលោកចៅក្រម ខ្ញុំនឹងសួរទៅតាមនេះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកអ្នកជំនាញ យើងនិយាយអំពីចំនួនខុសគ្នានៃចំនួនគ្រួសារ ចន្លោះពីឆ្នាំ៧៥ ដល់៧៩។ ដូចដែលលោកចៅក្រមទើបលើកឡើង គឺត្រឹមត្រូវហើយថា អ្នកដែលលោកសម្ភាសនេះ និយាយតែពីចំនួនគ្រួសារទេ គឺចំនួនគ្រួសារដែលរស់នៅក្នុងភូមិរបស់គាត់ ក្នុងឆ្នាំ១៩៧៩។ អ៊ីចឹងមែនទេ?

[១៥:៣៤:៤៦]

**លោក អ៊ីសា ឧស្មាន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកមានព័ត៌មានណាមួយដែរទេ ឬក៏គ្រាន់តែជាការប៉ាន់ប្រមាណ ឬក៏មានការប៉ាន់ប្រមាណណាទេ ថាហេតុអ្វីបានជាគ្រួសារដទៃទៀតមិនត្រឡប់មករស់នៅក្នុងភូមិរបស់ខ្លួនវិញ ឬក៏មានមូលហេតុណាផ្សេង?

**ឆ៖** ចំនួនគ្រួសារដែលបាត់នេះ គឺ៩៩ភាគរយហើយ គឺបាត់ដោយសារការស្លាប់។ ស្លាប់ដោយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ការសម្លាប់ ស្លាប់ដោយសារការអត់អាហារ ដោយសារជំងឺផ្សេងៗ។ ចំនួនភាគរយដែលទៅរស់នៅក្រៅប្រទេសនេះគឺតិចណាស់ យើងដឹងហើយ៧៥ គឺតំបន់ភូមិទាំងឡាយដែលខ្ញុំដាក់ជូននេះ គឺខ្មែរក្រហមគ្រប់គ្រងតាំងពីមុន៧៥ម្ល៉េះ អ៊ីចឹងដល់ពេល៧៥ នេះឱកាសនៃការភៀសខ្លួនទៅនៅក្រៅប្រទេសរបស់គាត់ហ្នឹង គឺចំនួនតិចបំផុត ស្ទើរតែគ្មាន។ ហើយបើនិយាយពីរឿងគាត់អត់ត្រឡប់មកនៅភូមិកំណើតវិញគាត់ទៅនៅភូមិផ្សេង មិនអាចទេ។ អ្នកដែលរស់រានមានជីវិតតែងតែត្រឡប់មកភូមិវិញ ដើម្បីចង់ដឹងថាមានបងប្អូន អ៊ំពូមាមីងយើងនៅរស់អត់ អីអត់ ផ្ទះសម្បែងយើងនៅកន្លែងហ្នឹងហើយ មុខរបរយើងពីដើម ស្រែចម្ការយើងពីដើមនៅកន្លែងហ្នឹង បងប្អូនយើងនៅកន្លែងហ្នឹង។ អ៊ីចឹងនៅពេលដែលខ្មែរក្រហមដួលរលំ៧៩ នេះមិនអាចមាននរណាម្នាក់ដែលចេញពីភូមិរបស់គាត់ហើយ គាត់មិនត្រឡប់មកវិញ គាត់នៅភូមិហ្នឹង គឺមិនអាចទេ។

[១៥:៣៧:០៣]

**សៈ** ក្រោយពីការដួលរលំនៃរបបនោះនៅឆ្នាំ១៩៧៩ យោងតាមការសម្ភាសរបស់លោកជាមួយជនជាតិចាមនោះ តើលោកមានសួរថា ពួកគាត់ហ្នឹងមានបំណងមករស់នៅជាមួយនឹងជនជាតិចាមនៅក្នុងភូមិរបស់គាត់ដដែលហ្នឹងវិញដែរឬទេ ឬក៏ពួកគាត់មិនបានមកដោយហេតុផលណាទេ?

**ឆៈ** ខ្ញុំដូចជាអត់ដែលជួបអ្នកណាមួយដែលខ្មែរក្រហមជម្លៀស បញ្ជូនចេញពីភូមិ ហើយគាត់អត់ត្រឡប់ទៅភូមិវិញ គឺអត់មានករណីហ្នឹងទេ។ ជាទូទៅ គឺបុគ្គលហ្នឹង គ្រួសារហ្នឹង តែងតែត្រឡប់ទៅវិញដើម្បីជួបជុំបងប្អូន ក្រុមគ្រួសារ មុខរបរ ផ្ទះសម្បែងរបស់ខ្លួននៅកន្លែងហ្នឹង។ ទាល់តែគាត់បានទៅជួបជុំគ្នាហើយ ដូចជាឆ្នាំ៨០, ៨១, ៨២ អាហ្នឹងបានគាត់អាចថាផ្លាស់ទីលំនៅទៅនៅកន្លែងនេះដោយសារមានស្រែចម្ការច្រើនជាង ឬក៏គាត់កន្លែងហ្នឹងស្លាប់បងប្អូនគាត់អស់ហើយ អត់មានបងប្អូនសាច់ញាតិជិតស្និទ្ធជាមួយគាត់ទេ គាត់អាចទៅរស់នៅភូមិមួយផ្សេងទៀត អាហ្នឹងមាន។ ប៉ុន្តែដល់ពេលបែក៧៩នេះ គឺម្នាក់ៗតែងតែត្រឡប់ទៅរកភូមិកំណើតរបស់ខ្លួនវិញ។

**សៈ** កត្តាមួយទៀតពាក់ព័ន្ធទៅនឹងការគណនា<តួ>លេខនេះ ដូចលោកនិយាយ លោកលើកឡើងអំពីភូមិស្វាយឃ្លាំង។ លោកថាមានប្រហែលជា<>១២០គ្រួសារ<ត្រឡប់មកវិញក្នុងឆ្នាំ១៩៧៩។> ហើយលោកថាសមាជិកគ្រួសារទាំងអស់ហ្នឹងគឺថា នេះនៅស្វាយឃ្លាំងនេះដែលមាន <១២០>គ្រួសារហ្នឹង គឺ<សមាជិកទាំងមូល>មិនបានត្រឡប់មកវិញទាំងអស់ទេ។ អ៊ីចឹងមែនទេ?

**ឆៈ** បាទ នេះជាស្រុករបស់ខ្ញុំផ្ទាល់។ ខ្ញុំសម្រាប់គ្រួសារខ្ញុំក៏ត្រឡប់ទៅវិញដែរ ហើយយើងទៅ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: ទូរ

Formatted: Condensed by 0.2 pt

Deleted:

Deleted: ១.១០០គ្រួសារ -- ហើយ --

Deleted: <>

Deleted: ១.២៤០

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ជាក់ស្តែង ពេលហ្នឹងខ្ញុំដឹងក្តីហើយ គឺឃើញតែផ្ទះទទេទេ បាត់ម្ចាស់ផ្ទះអស់រលីងហើយ ភាគច្រើន គឺតិចណាស់ដែល ផ្ទះដែលម្ចាស់ផ្ទះហ្នឹងគាត់ត្រឡប់ទៅវិញនោះ គឺមានតិចតួចបំផុត។ ហើយយើងនាំគ្នារាប់ កាលពេលហ្នឹងគឺខ្ញុំនៅក្មេងណាស់ ប៉ុន្តែចាស់ៗគាត់នាំគ្នារាប់ ឥឡូវគ្នាយើងនៅសល់ប៉ុន្មានគ្រួសារ។ ដល់តែរាប់ចុះ រាប់ឡើងនៅពេលដែលដឹងថាមកជួបជុំគ្នាអស់ហើយ យើងរាប់ទៅ យើងឃើញតែ ១២០ គ្រួសារ ហើយចំនួនមុន៧៥ហ្នឹងគឺ១២៤០គ្រួសារ។ ដូច្នេះវាបាត់១.១២០គ្រួសារ មិនមែន១.២២០តាមលោកគណនាទេ។

[១៥:៤០:៣៤]

**សៈ** វាឆ្លើយតបទៅនឹងកូឡោនទី៣ដែលខ្ញុំបាន -- បន្ទាត់ទី៣ដែលខ្ញុំបានរៀបចំហើយ។ ដូច្នេះលោកអ្នកជំនាញ ខ្ញុំសូមចូលទៅនិយាយភូមិពីរ ដែលលោករៀបរាប់ពីចំនួន<មនុស្ស> ដើម្បីប្រតិចារឹកសូមអាន គឺទី១កោះផល។ នៅឆ្នាំ១៩៧៥ គឺថាមាន១.៨៦៤នាក់ ដល់ឆ្នាំ១៩៧៩មានតែ១៨០នាក់ អ៊ីចឹងយើងដកមើលទៅឃើញបាត់មនុស្សអស់១.៦៨៤នាក់។ នៅភូមិ<ប៉ើស> នៅក្នុងឆ្នាំ១៩៧៥ មាន១.០០៥នាក់ ហើយនៅក្នុងឆ្នាំ១៩៧៩ មានតែ៥៥៨នាក់គឺភូមិប៉ើស។ អ៊ីចឹងដកមើលទៅឃើញបាត់អស់៤៤៧នាក់។ អ៊ីចឹងភូមិទាំងពីរនេះបូកចូលគ្នា បូកអ្នកបាត់ខ្លួន <កោះផលចំនួន១៦៨៤ និងប៉ើស៤៤៧> -- យើងឃើញ<បាត់> ២.១៣១នាក់។ អ៊ីចឹងតួលេខចំនួន ២.១៣១នាក់ពីភូមិកោះផល និងភូមិប៉ើសនេះ ដែលលោករៀបជាគ្រួសារ យើងឃើញថាបាត់ -- បាត់ សរុបទាំងជាគ្រួសារវិញ គឺបាត់១៩.១២០នាក់ ហើយដល់តែពីរភូមិនេះបាត់ជាចំនួនមនុស្សវិញ គឺបាត់អស់<២១.២៥១នាក់>។ តើៗអ្នកដែលសម្ភាស លោកសម្ភាសហ្នឹង តើគេប្រាប់លោកយ៉ាងម៉េចដែរពាក់ព័ន្ធទៅនឹងការបាត់បង់ចំនួនមនុស្សនេះ?

**ឆៈ** នៅភូមិកោះផល ហើយនិងភូមិប៉ើស មនុស្សដែលខ្ញុំបានជួបសម្ភាសហ្នឹងគាត់ឲ្យតួលេខជាចំនួនមនុស្សជាក់លាក់ មិនមែនជាចំនួនគ្រួសារទេ។ ដូច្នេះហើយខ្ញុំយកមកសរសេរនៅក្នុងសៀវភៅក៏ដាក់តាមអ្វីដែលគាត់បានប្រាប់ខ្ញុំ គឺចំនួនមនុស្ស។ វាខុសពីភូមិផ្សេងៗដែលគាត់ប្រាប់ជាចំនួនគ្រួសារ ខ្ញុំក៏សរសេរជាចំនួនគ្រួសារ ខ្ញុំមិនហ៊ានទាំងគណនាគុណនឹងប្រាំ ឬក៏គុណនឹងប្រាំមួយផង ក្រែងលោវាលម្អៀងពីអ្វីដែលខ្ញុំបានទទួលព័ត៌មានពីអ្នកដែលខ្ញុំសម្ភាសនោះ។

[១៥:៤៣:២៥]

**សៈ** បាទ សូមអរគុណលោកអ្នកជំនាញ។ ខ្ញុំសូមបញ្ចប់ការនិយាយគ្នាអំពីចំនួនប្រជាពលរដ្ឋនៅត្រង់ទំព័រ១២០ទៅចុះ ហើយឯកសារនេះលែងត្រូវការទៀតហើយ។ ប៉ុន្តែយ៉ាងណាក៏ដោយនៅត្រង់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: <>
Deleted: គ្រួសារដែរ
Deleted: <>
Deleted: ភាគ
Deleted: បូកអ្នកនៅសេសសល់៧៩
Deleted: <>
Deleted: មាន
Deleted: <>
Deleted: ២.១៣១
**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)
**Formatted:** Font: 6 pt, Complex Script Font: 6 pt

ទំព័រ១២០នេះដដែល ត្រង់កថាខណ្ឌបន្ទាប់ លោកបាននិយាយដូចតទៅ៖ បន្ថែមទៅលើចំនួនប្រជាជននៅក្នុងតារាងនីមួយៗគឺថាខ្មែរក្រហមសម្លាប់<ប្រជាជនស្ទើរតែទាំងអស់ពី១០ភូមិចាម។ ភូមិខ្លះមានអ្នករស់រានតែបួន ឬប្រាំនាក់តែប៉ុណ្ណោះ គេមិនអាចបន្តរស់នៅ គេក៏ចេញពីភូមិកំណើតទៅរស់នៅទីកន្លែងផ្សេងអស់ទៅ។> ហើយទំព័រ១២១វិញ លោកបានរៀបរាប់ភូមិចំនួន១០ បាទខ្ញុំចង់លើកយកភូមិទាំង១០មក តើត្រឹមត្រូវដែរទេតាមដែលខ្ញុំយល់ភូមិ -- អ្នកភូមិទាំងអស់នេះ នៅត្រង់ទំព័រ១២១នេះ គឺអ្នកដែលលោកលើកមកនិយាយនៅទំព័រមុនដែរ គឺនិយាយអំពីប្រជាជនចាមស្ទើរតែទាំងអស់គឺត្រូវបានបោសសម្អាតតែម្តង។ អ៊ីចឹងសូមលោកពន្យល់ជូនតុលាការបន្តិចមើល?

**ឆ៖** បាទ ត្រឹមត្រូវហើយលោកសហព្រះរាជអាជ្ញា។ មានភូមិចាមចំនួន១០ ដែលបានរៀបរាប់ដូចនៅក្នុងទំព័រ១២១ នេះ ដែលភូមិនៅខេត្តកំពង់ចាម កំពង់ធំ ហើយនិងខេត្តកណ្តាល គឺប្រជាជនចាមដែលរស់នៅក្នុងភូមិហ្នឹងពីដើម គឺសុទ្ធតែភូមិធំៗ ប៉ុន្តែយើងអត់ដឹងចំនួនជាក់លាក់ប៉ុន្មានទេ។ អ៊ីចឹងអត់ហ៊ានដាក់ថាចំនួនប៉ុន្មានទេ។ ប៉ុន្តែក្រោយពីរបបខ្មែរក្រហម ភូមិខ្លះគឺស្លាប់អស់ អត់មានអ្នកត្រឡប់ទៅវិញទេ ហើយភូមិខ្លះមាន បួន ប្រាំគ្រួសារ គាត់ត្រឡប់ទៅវិញចាំ រង់ចាំក្រែងលោអ្នកផ្សេងៗទៀតត្រឡប់ទៅ អត់ឃើញទេ ស្លាប់អស់ហើយ។ អ៊ីចឹងហើយ គាត់ក៏បោះបង់ភូមិកំណើតរបស់គាត់ ទៅរស់ជ្រកកោនជាមួយអ្នកភូមិដទៃទៀត ហើយភូមិទាំង១០ហ្នឹង គឺលែងមានជាភូមិចាមទៀតហើយ ការពិតជាភូមិប្រវត្តិសាស្ត្រដែលចាមមកតាំងទីលំនៅតាំងពីរត់ពីប្រទេសចម្ប៉ាមកដូចគ្នាហ្នឹង។ ប៉ុន្តែដល់ពេលអស់សមាជិករបស់ខ្លួន ក៏នាំគ្នាបោះបង់ចោលភូមិរបស់ខ្លួន ហើយសព្វថ្ងៃនេះ ក៏លែងមានឈ្មោះជាភូមិចាមទៀតហើយនៅទីនោះ គឺបងប្អូនខ្មែរទៅរស់នៅជំនួសវិញ។

[១៥:៤៦:៣៤]

**ស៖** អរគុណ។ ខ្ញុំចង់ពិនិត្យទៅលើបញ្ជីទាំងអស់នេះដើម្បីយើងបានយល់ថាតើវាមានទីតាំងនៅទីណាខ្លះ ហើយរចនាសម្ព័ន្ធការគ្រប់គ្រងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង វាមានលក្ខណៈយ៉ាងដូចម្តេច? ឥឡូវយើងពិនិត្យ ផ្តើមពីឈ្មោះភូមិមួយចំនួន បាទ គឺភូមិបាយកាយ នៅក្នុងស្រុកល្វាឯម នៅក្នុងខេត្តកណ្តាល។ តើត្រឹមត្រូវឬទេ វាស្ថិតនៅក្នុងភូមិភាគនិរតី?

**ឆ៖** នៅល្វាឯមនេះ តាមភូមិសាស្ត្រដែលខ្ញុំបានឃើញផែនទីខ្មែរក្រហម ដូចជានៅភូមិភាគបូព៌ាទេ មិនមែននិរតីទេ បើសិនជាខ្ញុំចាំមិនខុស ហើយភូមិនេះគឺការពិតភូមិចាមមែន មានបងប្អូនរបស់ខ្ញុំផ្ទាល់បានរស់នៅកន្លែងហ្នឹង។ ឪពុកខ្ញុំតែងតែដំណាលប្រាប់នៅពេលដែលគាត់មកលេងខ្ញុំនៅភ្នំពេញម្តងៗ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**Deleted:** <>

**Deleted:** ៗទាំង១០ភូមិ ពីមុនគឺថាប្រជាជនរស់រានមានជីវិត ក្រោយមកគឺថាមិនបានឃើញត្រឡប់មករស់នៅក្នុងភូមិរបស់ខ្លួនវិញទេ។

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt

ហ្នឹង គាត់ប្រាប់ថាបងប្អូនយើងច្រើនណាស់នៅភូមិបាយកាយនេះ អត់ឆ្ងាយពីកូនទេ ឆ្លងទន្លេទៅដល់ហើយ ប៉ុន្តែបាត់អស់ហើយ អត់ឃើញទេលែងឃើញបងប្អូនយើងហើយ។ ហើយយើងជាក់ស្តែងគឺអ៊ីចឹងមែន បាយកាយនេះលែងជាភូមិចាមទៀតហើយ នៅល្វាឯមនៅឆ្លងទន្លេទៅខាងអរិយក្សត្រនេះ អត់មានភូមិចាមទេសព្វថ្ងៃនេះ។

**សៈ** អ៊ីចឹងភូមិបាយកាយ ស្ថិតនៅក្នុងខេត្តកណ្តាល។ ថាតើវាស្ថិតនៅក្នុងភូមិភាគបូព៌ា តើត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទ តាមខ្ញុំចាំបាន នៅត្រើយខាងទៅខាងល្វាឯម ខាងនោះ គឺនៅភូមិភាគបូព៌ា។

[១៥:៤៩:០៦]

**សៈ** ហើយភូមិមួយទៀត គេហៅថាភូមិទន្លេដែលស្ថិតនៅក្នុងកោះធំ ស្រុកកោះធំ តើត្រឹមត្រូវទេ? តើវាស្ថិតនៅក្នុងតំបន់២២ នៅក្នុង គេហៅថា ស៊ុំទោស៤២ តំបន់៤២ នៅក្នុងភូមិភាគកណ្តាល?

**ឆៈ** អត់ទេ។ ភូមិពោធិ៍ទន្លេនេះនៅក្នុងស្រុកកោះធំ តំបន់សៃ -- ២៥ មិនមែនតំបន់៤២ទេ ហើយនៅក្នុងភូមិភាគពិសេស ដែលក្រោយមក ដូចជាចាត់ចូលទៅក្នុងភូមិភាគនិរតីដែរ។

**សៈ** ខ្ញុំនឹងរំលងវាពាក់ព័ន្ធនឹងចំណុចនេះបន្តិច។ សូមរំលងប្រាំភូមិ។ ឥឡូវខ្ញុំចូលទៅដល់<លេខរៀងទី៨> ភូមិខ្វាវ និងព្រៃឈរនៅក្នុងខេត្តកំពង់ចាម តើស្ថិតនៅក្នុងតំបន់ណា ឬភូមិភាគណាដែរ នៅក្នុងភូមិដែលខ្ញុំជម្រាបនេះ?

**ឆៈ** ភូមិខ្វាវ ពីដើមគេហៅថាតំបន់៤១ ភូមិភាគខាងជើង។ ប៉ុន្តែនៅឆ្នាំ១៩៧៧ គេដាក់តំបន់៤១ ហ្នឹងទៅក្នុងភូមិភាគកណ្តាលវិញ។

**សៈ** ហើយភូមិបន្តមកទៀត<លេខរៀងទី៩> គេហៅថាភូមិចំការលើនៅក្នុងស្រុកក្រូចឆ្មារ ថាតើវាស្ថិតនៅក្នុងតំបន់៤១ នៅក្នុងភូមិភាគខាងបូព៌ា -- ស៊ុំទោសនៅក្នុងតំបន់២១?

**ឆៈ** បាទត្រឹមត្រូវ តំបន់២១ ភូមិភាគបូព៌ា។

**សៈ** អ៊ីចឹងភូមិមួយទៀត គឺទួលល្វៀង នៅក្នុងស្រុកបារាយណ៍ តើស្ថិតនៅក្នុងភូមិភាគកណ្តាល នៅក្នុងតំបន់៤៣ ឬយ៉ាងណា?

**ឆៈ** នៅទួលល្វៀងនេះ ទឹកដីនេះ គឺនៅក្នុងតំបន់៤២ ហើយ៤២នេះ ដូច៤១ដែរ។ ដំបូងគេហៅថា ភូមិភាគខាងជើង ដល់ពេលឆ្នាំ៧៧ ដើមឆ្នាំ៧៧ហ្នឹង គេហៅថា ភូមិភាគកណ្តាល។

**សៈ** បើអ៊ីចឹងខ្ញុំសូមរំលងភូមិទាំងហ្នឹង។ គឺយើងឃើញមានភូមិប្រាំ ពីស្រុកកំពង់សៀម, កោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ប្រាក់ ចម្ការ_៣០ ក្រគរ កោះរកា។ <>ថាតើ<ភូមិទាំងនេះ>ស្ថិតនៅក្នុងតំបន់ណា ភូមិភាគណាដែរ?

**ឆ៖** បាទ ខ្ញុំសូមបន្ថែមភូមិមួយទៀតដែលខ្ញុំបានសរសេរ គឺល្អាង។ បន្ថែមពីលើភូមិដែលលោកបានរៀបរាប់មិញហ្នឹង នៅក្នុងស្រុកកំពង់សៀម។ ហើយភូមិសាស្ត្រស្រុកកំពង់សៀមនេះ គេចាត់ចូលទៅក្នុងតំបន់៤១ ពីដើមភូមិភាគខាងជើង ហើយដើម៧៧ គេហៅថា ភូមិភាគកណ្ដាល។

[១៥:៥៣:៣១]

**ស៖** សូមអរគុណសម្រាប់ការកែពាក់ព័ន្ធទៅនឹងភូមិចំនួនប្រាំមួយ ដែលលោកបានបញ្ជាក់នៅក្នុងឯកសារនេះ។ ខ្ញុំសូមអានឯកសារមួយពីលោក យៀវនិន ពាក់ព័ន្ធទៅនឹងស្រុកកំពង់សៀម គឺ <E3/1593> គឺជាភាសាអង់គ្លេសនៅក្នុងទំព័រ២៦០ <ភាសាបារាំង>នៅ<ទំព័រ>លេខ<៣៣៦> <មិនមានបកប្រែជាភាសាខ្មែរទេ>បានបញ្ជាក់ថា គឺនៅក្នុងស្រុកកំពង់សៀម គឺស្ថិតនៅក្នុងតំបន់៤១ <។> ហើយនៅឆ្នាំ១៩៤០ <មាន>ប្រជាជនចាមហ្នឹង<រស់នៅ>ចំនួន<៣.៨០០នាក់។ ឆ្នាំ១៩៧៥ មានចាម> ២.០០០គ្រួសារនៅក្នុងភូមិចំនួនប្រាំពីរ ហើយលោកក៏បានដកស្រង់ថា គឺរដ្ឋាភិបាលថ្មីក៏បានបញ្ជាក់ថា វានៅក្នុងឆ្នាំ១៩៨០ គឺបានបញ្ជាក់ច្បាស់ដែលមាន មួយបញ្ជាក់នៅក្នុងស្រុកកំពង់សៀម នៅក្នុងភូមិ ច្រនៀងនេះ គឺមានជនជាតិខ្មែរ១២<នាក់> ត្រូវបានគេសម្លាប់នៅឆ្នាំ៧៥ ទៅដល់៧៨ <ក្នុងនោះមានប្រាំបីនាក់ជាប្រជាជនថ្មី>។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៧<តែមួយប៉ុណ្ណោះ> មាន<ចាម១៣គ្រួសារសរុបប្រហែលជាង៨០នាក់>ត្រូវបានសម្លាប់។ អ៊ីចឹងលោកសាក្សី តាមរយៈអ្វីដែលបានបញ្ជាក់ ការប៉ាន់ប្រមាណរបស់លោក យៀវនិន បានបញ្ជាក់នៅក្នុងឆ្នាំ១៩៧៥ នៅក្នុងស្រុកកំពង់សៀមហ្នឹង គឺមានគ្រួសារចាមចំនួន២.០០០<>។ តើលោកយល់យ៉ាងណាដែរពាក់ព័ន្ធនឹងអ្វីដែលខ្ញុំបញ្ជាក់ទាំងអស់នេះ?

**ឆ៖** បាទ ខ្ញុំមិនហ៊ានសន្និដ្ឋានថា ចំនួន២.០០០គ្រួសារនៅកំពង់សៀមត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវទេ ពីព្រោះខ្ញុំអត់បានស្រាវជ្រាវចំនួនគ្រួសារនៅក្នុងកំពង់សៀមទេ។ គ្រាន់តែដឹងថា នៅក្នុងកំពង់សៀមនេះ គឺមានបាត់បង់ភូមិចាមមួយចំនួន ប៉ុន្តែតាមដែលអ្នកដែលខ្ញុំបានជួបសម្ភាស គឺកំពង់សៀមនេះ គឺជាមូលដ្ឋានរបស់ប្រជាជនចាមរស់នៅច្រើន។ ស្រុកដែលបន្ទាប់ពីក្រូចឆ្មារហ្នឹង គឺមានស្រុកមួយចំនួនទៀតដែលប្រជាជនរស់ច្រើន ប្រហែលប្រហាក់នឹងក្រូចឆ្មារដែរ មាននៅកំពង់សៀម មាននៅកងមាស មាននៅស្ទឹងត្រង់ សុទ្ធស្រុកដែលជាប់មាត់ទន្លេ។ អ៊ីចឹងលោក ប៉ែន យៀវនិន គាត់ដាក់ថាចំនួន២.០០០គ្រួសារនេះ ខ្ញុំមិនហ៊ាននិយាយថា តើវាពិត ឬក៏មិនពិតទេ ត្រូវធ្វើការស្រាវជ្រាវឡើងវិញ។ អាចមានអ្នកកំពង់សៀមមួយចំនួនអាចនៅដឹង។ ខ្ញុំសូមបន្ថែមបន្តិច សព្វថ្ងៃកំពង់សៀមនៅសេសសល់ភូមិមួយ នៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

Deleted: គោករកា ហ្នឹង

Deleted: <

Deleted: >

Deleted: 1

Deleted: >

Deleted: ៥

Deleted: គឺរហូតទៅដល់ឆ្នាំ១៩៧៥

Deleted: <>

Deleted: គឺមាន

Deleted: ><

Deleted: ៨

Deleted: <>

Deleted: គ្រួសារ ១៣គ្រួសារជនជាតិចាមគឺ

Deleted:

Deleted: ត្រូវបាន -- ២.០០០

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ភូមិក្រគរ ក្នុងឃុំកំពង់ក្របី ដែលនៅសេសសល់ភូមិចាមមួយ ក្រៅពីហ្នឹង គឺបាត់បង់ភូមិចាមអស់ហើយ គឺសល់តែមួយ ហើយមួយនេះគឺចំនួននៅសល់នេះ មកដល់សព្វថ្ងៃនេះក៏ដោយ គឺចំនួនគ្រួសារ ចំនួនប្រជាជនដែលនៅសេសសល់នេះ គឺគាត់កើតកូនកើតចៅរយៈពេលយូរអង្វែងណាស់ហើយ តាំងពី៧៩ មកដល់បច្ចុប្បន្ននេះ គឺមើលទៅនៅតែចំនួនតិចជាងចំនួនពីរដើម។ ហើយភូមិមួយចំនួនក៏អ៊ីចឹងដែរ នៅក្នុងស្រុកកងមាស ដូចជាខាងអង្គរបានជាដើម។ ទោះមកដល់សព្វថ្ងៃក៏ដោយ គាត់បែកគ្រួសារមានកូនមានចៅក៏ដោយ ប៉ុន្តែបើប្រៀបធៀបចំនួនមុនខ្មែរក្រហមហ្នឹង ក៏នៅតែតិចជាងនៅឡើយ។ តិចជាងៗច្រើនណាស់ គឺបាត់បង់កំពង់សៀម កងមាសនេះ គឺបាត់បង់ច្រើន។

[១៥:៥៨:០៩]

**ស៖** សូមអរគុណ។ នៅក្នុងសៀវភៅរបស់លោក ដែលពាក់ព័ន្ធនឹងការរើបម្រះរបស់ពួកចាមនេះ គឺតាមរយៈពីខេត្ត -- ពីស្រុកកំពង់សៀមនុ៎ង គឺពួកគាត់ដែលរស់នៅទីនោះ គឺបាត់ខ្លួន ហើយជាពិសេសតាមរយៈការផ្តល់បទសម្ភាសន៍របស់លោក ម៉ាត់ សារិន គឺតាមរយៈឯកសារ<ភាសាអង់គ្លេស> 00219193, ខ្មែរគឺ <00904414> គឺមិនមានជាភាសាបារាំងទេ គឺលោកបានដកស្រង់បានបញ្ជាក់ថា "នៅក្នុងឆ្នាំ១៩៧៨ គឺគេបានចាប់ផ្តើមសម្លាប់ជនជាតិចាម ហើយនៅពេលនោះគឺការសម្លាប់នោះ គឺអនុវត្តជាសាធារណៈ មិនសម្លាប់យ៉ាងសម្ងាត់ដូចពីមុននោះទេ។ គឺគេសម្លាប់ជនជាតិចាមគ្រប់ភូមិនៅក្នុងស្រុកកងមាស<និង>ស្រុកកំពង់សៀម ហើយមានអ្នក<ខ្លះនៅរស់រានមានជីវិត គឺជាអ្នក>ដែល<> ត្រូវបានគេជម្លៀសចេញទៅទី<កន្លែងផ្សេង>ឆ្ងាយ<>នោះ។ ដូច្នេះ តើលោកមានចាំទេ ពាក់ព័ន្ធទៅនឹងអ្វីលើកឡើងពាក់ព័ន្ធទៅនឹង ម៉ាត់ សារិន នេះ?

**ឆ៖** បាទ ពីព្រោះរឿងសាក្សីម្នាក់នេះ មិនខុសពីសាក្សីមនុស្សផ្សេងទៀតដែលបានបានផ្តល់ព័ត៌មានឲ្យខ្ញុំទេ។ គឺពិតជាមានការសម្លាប់ធ្ងន់ធ្ងរៗ ជាងដើមទី ធ្ងន់ធ្ងរជាង៧៥-៧៦។ គឺចាប់ផ្តើមពី ៧៧-៧៨នេះ គឺចាមនៅកំពង់សៀមក្តី នៅកងមាស នៅក្រូចឆ្មារ នៅស្ទឹងត្រង់ នៅតាមភូមិដ្ឋានមួយចំនួនទៀត គេត្រូវបោសសម្អាតសម្លាប់របៀបកៀរ ប្រមូលផ្តុំ រើសយកចាម យកទៅសម្លាប់ទាំងហ្វូងៗ ឲ្យតែចាម គឺមិនរួចខ្លួនទេ។

**ស៖** នៅក្នុងចំណុចមួយដែលលោកបានបញ្ជាក់ គឺនៅក្នុងស្រុកកំពង់សៀម នៅក្នុងឯកសារជាខ្មែរ គឺ<00904408> ហើយនៅក្នុងភាសា -- ឯកសារអង់គ្លេសគឺ 00219210 លោកបានដកស្រង់សម្តីរបស់<លោក អ៊ីស្មាឯល ប៊ីន សាមះ>ដែលមកពីឃុំ<គគរ> នៅក្នុងស្រុកកំពង់សៀម "នៅក្នុងឆ្នាំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**Formatted:** Condensed by 0.1 pt
**Deleted:** <
**Deleted:** >
**Deleted:** <>
**Deleted:** -- សូមទោស នៅក្នុង
**Deleted:** ខ្លះទៀត
**Deleted:** <>
**Deleted:** តាំង
**Deleted:** ទៅទៀត
**Deleted:** <>
**Deleted:** 0048
**Deleted:** <>
**Deleted:** ឧស្ម័ន
**Deleted:** ក
**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)
**Formatted:** Font: 6 pt, Complex Script Font: 6 pt

១៩៧៨ គឺខ្មែរក្រហមបានប្រកាសថា មានប្រជាជន២.០០០ដែលបញ្ជាក់ថាជាខ្មាំងនៅក្នុងឃុំនុំង ហើយគឺមានការបញ្ជាក់។ ហើយប៉ុន្មានថ្ងៃក្រោយមកទៀត គឺពួកកម្មាភិបាលបានមកដល់ ហើយបានកត់ឈ្មោះជាពិសេស ឈ្មោះជនជាតិចាមទាំងអស់នៅក្នុងឃុំទាំងអស់នោះ ដែលជាចំនួនអ្នកសង្ស័យ ហើយគឺមានគេបញ្ជាក់ថា ជនជាតិចាម២.០០០ ដែលគេកំណត់ថាជាខ្មាំង ដែលគេមានការគណនាជាមុនហើយប្រកាស។ បន្ទាប់មកទៀត គេបានជ្រើស គេបានយកពួកទាំងនោះទៅសម្លាប់។ បន្ទាប់ពីមានការកំណត់ ហើយគេប្រមូលទាំងស្ត្រី និងបុរស ដើម្បីសម្លាប់កុមារអីជាដើម ដើម្បីសម្លាប់។ អ៊ីចឹងតើលោកចាំទេ ពាក់ព័ន្ធនឹងសម្ដីរបស់លោក អាល់ប៊ុន អះម៉ាត់ ហ្នឹង?

**ឆ៖** បាទ ខ្ញុំនៅចាំបាន ពីព្រោះការសម្លាប់។

**ស៖** នៅក្នុងការស្រាវជ្រាវរបស់លោកដែលបញ្ជាក់ថា ជនជាតិចាមដែលជាគោលដៅសម្រាប់សម្លាប់នៅក្នុងសម័យប៉ុលពតហ្នឹង តើស្ត្រីបុរសក៏មាន គឺកុមារហ្នឹង ក៏ត្រូវបានគេសម្លាប់ដែរ ឬមួយយ៉ាងណា?

[១៦:០២:២២]

**ឆ៖** គេសម្លាប់អត់រើសមុខទេ គេរើសថា អ្នកណាជាជនជាតិចាម។ ខ្ញុំសូមបញ្ជាក់ជូនអង្គសវនាការថា នៅឆ្នាំ៧៧នេះ ខ្មែរក្រហមពិបាកស្គាល់ថាអ្នកណាជាចាម អ្នកណាជាខ្មែរណាស់ ពីព្រោះចាមត្រូវបានជម្លៀសឲ្យទៅរស់នៅជាមួយប្រជាជនខ្មែរ នៅចុង៧៥ បានន័យថាក្រោយពេលបះបោររួចគេជម្លៀសឲ្យទៅរស់នៅជាមួយបងប្អូនខ្មែរ។ ហើយចាមមួយចំនួនហ្នឹងក៏ធ្វើរបៀបរបបជាខ្មែរទៅហើយ ដោយខ្លាចស្លាប់ ហូបសាច់ជ្រូកហើយ ឈប់ថ្វាយបង្គំព្រះលះបង់សាសនាអីទាំងអស់ហើយ។ ហើយបើចាមយុវជន គាត់រស់នៅជាមួយបងប្អូនខ្មែរ មានមិត្តភក្តិជាខ្មែរ គាត់និយាយខ្មែរបានស្ទាត់ហើយ បើកុមារហ្នឹង គាត់ភ្លេចនិយាយចាមទៅហើយ។ អ៊ីចឹង៧៧, ៧៨នេះ ខ្មែរក្រហមពិបាកៗសម្គាល់ណាស់ថាអ្នកណាចាម អ្នកណាខ្មែរ ពីព្រោះរស់នៅលាយឡំច្របូកច្របល់ចូលគ្នាអស់ហើយ។ កុមារនៅកងកុមារ យុវជននៅកងចល័ត មនុស្សចាស់នៅមនុស្សចាស់ ប្រុសនៅប្រុស ស្រីនៅស្រី។ អ៊ីចឹងហើយ ខ្មែរក្រហម មាននយោបាយមួយ គេថាឲ្យអ្នកណាក៏ដោយ ឲ្យជាចាម នៅសហករណ៍ណាក៏ដោយ នៅអង្គភាពណាក៏ដោយ ឲ្យមកជួបជុំបងប្អូនវិញ។ ឥឡូវនេះគេរំដោះហើយ យើងមានសេរីភាពហើយ សូមបងប្អូនចាមគ្រប់កន្លែងទាំងអស់ ទាំងកុមារ ទាំងយុវជន ទាំងមនុស្សចាស់ ត្រឡប់មកជួបជុំគ្រួសារ មកកន្លែងកំណើតវិញ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

ពេលនុ៎ង ចាម បងប្អូនចាមម្នាក់ៗអរណាស់ អរមែនទែន ហើយក៏បានត្រឡប់មកដើម្បីមកជួបជុំក្រុមគ្រួសារ ត្រឡប់។ បើនៅក្រូចឆ្មារវិញ ត្រឡប់មកដល់ភូមិរបស់ខ្លួនទៀត។ ហើយនៅកងមាសនៅកំពង់សៀមនេះក៏អ៊ីចឹងដែរ ត្រឡប់ វត់មករកឪពុកម្ដាយក្រុមគ្រួសារ។ នៅពេលដែលមកជុំឃើញសម្គាល់ថាហ្នឹងហើយជាគ្រួសារចាម គេៗប្រមូលៗគ្រប់គ្រួសារទាំងអស់យកទៅសម្លាប់។ អត់រើសទេ អត់រើសថា អ្នកនេះជាក្មេង ជាចាស់អីទេ គឺថាឲ្យតែចាម គេយកទៅសម្លាប់ ប៉ុន្តែមានចាមមួយចំនួនដែលបន្តរស់នៅជាមួយបងប្អូនខ្មែរ អត់ត្រឡប់មកទេ ឬក៏បងប្អូនខ្មែរគាត់ដឹងសភាពការណ៍ គាត់មានមនោសញ្ចេតនាអាណិតស្រឡាញ់ថា កុំអាលទៅអី ចាំមើលសភាពការណ៍សិន។ មានបងប្អូនខ្មែរចិត្តល្អណាស់ ហើយគាត់បានប្រាប់អ៊ីចឹងទៅក៏រស់នៅជាមួយបងប្អូនខ្មែរហ្នឹង អ្នកហ្នឹងនៅរស់ ប៉ុន្តែអ្នកដែលត្រឡប់មកវិញ មកស្រុកកំណើតវិញហ្នឹង គឺកម្របានរស់រានមានជីវិតណាស់ គឺប្រមូលយកទៅសម្លាប់ទាំងអស់។ នៅស្រុកក្រូចឆ្មារ គេបញ្ជូនយកទៅសម្លាប់នៅភូមិទ្រា សម្លាប់នៅវណ្ដៅ នៅភូមិទ្រា ឬក៏សម្លាប់ទម្លាក់នៅក្នុងទឹកទន្លេមេគង្គ។ ហើយបើនៅខាងកំពង់សៀម គេមានសម្លាប់ផ្សេង ខ្ញុំមិនអាចនិយាយបានទេ ដែលនៅកងមាស វាមានកន្លែងសម្លាប់មួយឈ្មោះវត្តអូរត្រកួន អ៊ីចឹងហើយថាការសម្លាប់នេះគឺអ៊ីចឹង។ ហើយចំពោះយុវជនដែលមិនបានត្រឡប់ទៅទេ ទៅជួបជុំគ្រួសារអត់បានទទួលព័ត៌មានហ្នឹងទេ យុវជនហ្នឹងគេហៅប្រមូលផ្ដុំមួយកន្លែងទៀត ហើយគេសួរចម្លើយថា អ្នកឯងជនជាតិអី? អ្នកខ្លះឆ្លើយការពិតថាជាចាម។ អ្នកខ្លះបារម្ភពីសុវត្ថិភាពខ្លួនឯង ឆ្លើយថាខ្មែរ មិនដឹងថាឆ្លើយមួយណារស់ មួយណាស្លាប់ទេ។ អ្នកខ្លះឆ្លើយថាកូនកាត់ ឪពុកចាម ឬក៏ម្ដាយចាមអ៊ីចឹងទៅ។ អ៊ីចឹងហើយការសម្លាប់ហ្នឹងគេដកយកអ្នកណាដែលថាកូនកាត់ អ្នកណាដែលថាជាជនជាតិចាម គេប្រមូលឲ្យដាក់មួយគុំ ខ្មែរឲ្យដាក់គុំ ហើយគេសម្លាប់តែអ្នកណាដែលសាច់ឈាម ជាប់សាច់ឈាមជាចាម។ អានេះករណីនេះកើតឡើងនៅភូមិទ្រា ដែលគេហៅទៅៗដើម្បីសួរឲ្យចង់ដឹងថាជនជាតិអីសិន បានគេសម្លាប់ ហើយមានអ្នកនៅរស់មកដល់សព្វថ្ងៃនេះ រស់ដោយសារគាត់កុហកថាគាត់ជាខ្មែរ។

[១៦:០៧:២១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណអ្នកជំនាញ។ ឥឡូវនេះ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកបន្តទៅធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងឌូបកប្រែ និងឌូបកប្រែបន្ត។

Formatted: Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

Formatted: Font: 6 pt, Complex Script Font: 6 pt

អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់អ្នកជំនាញ អ៊ីសា ឧស្មាន ហើយសូមភាគីជ្រាប និងអញ្ជើញចូលរួមតាមកាលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក អ៊ីសា ឧស្មាន ដំណើរការសវនាការស្តាប់សក្ខីកម្មលោកក្នុងឋានៈជាអ្នកជំនាញនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកស្រី ហ្សូលី បាដេស ដែលជាមន្ត្រីច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតអន្តរជាតិនាពេលនេះ លោកស្រីអាចសម្រាកបានហើយ។ អង្គជំនុំជម្រះក៏សូមអញ្ជើញលោកស្រីមកចូលរួមសវនាការនៅថ្ងៃស្អែកទៀតដែរ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក អ៊ីសា ឧស្មាន ទៅកាន់លំនៅរបស់គាត់ និងអញ្ជើញគាត់ចូលរួមសវនាការនៅថ្ងៃស្អែកដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីរនាក់ត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៨ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**Formatted:** Plain Text, Justified, Border: Top: (Single solid line, Auto, 0.5 pt Line width)

**Formatted:** Font: 6 pt, Complex Script Font: 6 pt